**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# នីតិវិធី
# ក្នុងបទជួញដូរដោយខុសច្បាប់នូវ
# សារធាតុញៀន

ស្រាវជ្រាវចាប់ពីថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៨


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **អ៊ឹង មួយអេង**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ប៊ុនធី**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាញ នីតិឯកជន ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# នីតិវិធី
# ក្នុងបទជួញដូរដោយខុសច្បាប់នូវ
# សារធាតុញៀន

ស្រាវជ្រាវចាប់ពីថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៨

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **អ៊ឹង មួយអេង**

សាស្ត្រាចារ្យណែនាំ
លោក **ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាញ នីតិឯកជន ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេរសារណា ២០១៨

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **អ៊ឹង មួយអេង** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

## សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូន

លោកឪពុក **អ៊ឹង ឈួងហ៊ត់** និងអ្នកម្ដាយ **លី វណ្ណលាំង** ដែលលោកអ្នកមានគុណទាំងពីរបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សានាងខ្ញុំ ព្រមទាំងឧបត្ថមគ្រប់បែបយ៉ាងទាំងផ្នែកថវិកា សំភារៈ និងស្មារតី ជាពិសេសទៅទៀតនោះ លោកទាំងពីរតែងតែនៅចាំលើកទឹកចិត្ត និងផ្ដល់ដំបូន្មានឲ្យនាងខ្ញុំគ្រប់ពេលវេលាទាំងការសិក្សា និងកិច្ចការផ្សេងៗទៀត តាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង** ព្រមទាំង**សាស្ត្រាចារ្យ មន្ត្រី** ទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន និងគាំទ្រដល់ការសិក្សារបស់នាងខ្ញុំរហូតដល់នាងខ្ញុំទទួលបានចំណេះដឹងដូចសព្វថ្ងៃនេះ ។

**លោក ហេង ម៉េងហួ** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ដែលបានផ្ដល់ការណែនាំបង្ហាត់បង្រៀន និងផ្ដល់យោបល់នាងខ្ញុំ អំពីនីតិវិធីព្រហ្មទណ្ឌ ។

ជាពិសេសទៅទៀតនោះ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **លោកសាស្ត្រាចារ្យ ជួន ម៉ុនធី** ដែលលោកជាសាស្ត្រាចារ្យណែនាំដ៏មានទេពកោសល្យ ហើយលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ បង្ហាត់បង្រៀន ផ្ដល់យោបល់ និងបង្ហាញវិធីសាស្ត្រក្នុងការសរសេរសារណានេះឡើង ព្រមទាំងជួយកែតម្រូវនូវចំណុចខ្វះខាតដែលមាននៅក្នុងសារណានាងខ្ញុំឲ្យបានល្អប្រសើរ និងសម្រេចជាស្ថាពរ ។

ជាទីបញ្ចប់នាងខ្ញុំ សូមប្រសិទ្ធិពរជ័យគោរពជូនដល់ **លោកឪពុក អ្នកម្ដាយ ឯកឧត្តម លោក លោកស្រី** និង**សាស្ត្រាចារ្យ មន្ត្រី** ទាំងអស់ សូមជួបប្រទះនូវតែពរទាំងបួនប្រការ គឺអាយុវណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ជាដំបូង នាងខ្ញុំមានអារម្មណ៍សែនត្រេកអរណាស់ ដែលនាងខ្ញុំមានឱកាសបានសរសេរសារណាក្រោមប្រធានបទ **នីតិវិធីក្នុងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដែលជា បទល្មើសកំពុងតែរីករាលដាល និងកំពុងតែកកើតមានឡើងយ៉ាងច្រើនក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ។ ហើយបទល្មើសនេះផងដែរ មិនត្រឹមតែធ្វើអោយប៉ះពាល់ដល់សុខភាពរូបវន្តបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ព្រោះថាវាបានបង្ក និងជម្រុញឲ្យមានអំពើល្មើសផ្សេងៗជាច្រើនដូចជា អំពើលួច ឃាតកម្មជាដើម ។ ដោយសង្កេតឃើញការប៉ះពាល់យ៉ាងធ្ងន់ធ្ងរបែបនេះហើយ ទើបនាងខ្ញុំធ្វើការលើកយកប្រធានបទ **នីតិវិធីក្នុងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** មកធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំឡើងសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

មួយវិញទៀត គោលបំណងដែលនាងខ្ញុំធ្វើការស្រាវជ្រាវ និងចងក្រងនូវប្រធានបទនេះឡើង គឺដើម្បីចូលរួមជាវិភាគទានដ៏សំខាន់ក្នុងការបង្ការ ទប់ស្កាត់មិនឲ្យគ្រឿងញៀនបង្កឥទ្ធិពលញាំញី បំផ្លិតបំផ្លាញសង្គមជាតិកម្ពុជា ជាពិសេសប្រឹងប្រែងសម្រេចការប្តេជ្ញាចិត្តថា កម្ពុជាជាប្រទេសគ្មានគ្រឿងញៀន និងរក្សាគ្រួសារនីមួយៗជា ***គ្រួសារស្អាតស្អំគ្មានគ្រឿងញៀន*** តាមទស្សនវិស័យ "***ចូលរួមទាំងអស់គ្នាដើម្បីជីវិត និងសហគមន៍គ្មានគ្រឿងញៀន***"។ បន្ថែមពីនេះ គឺនាងខ្ញុំចង់រក្សាទុកឯកសារនេះសម្រាប់បំពេញនូវតម្រូវការរបស់និស្សិតជំនាន់ក្រោយ និងជួយដល់លោកអ្នកទាំងអស់ ដែលមានបំណងធ្វើការសិក្សាស្រាវជ្រាវលើការអនុវត្តនីតិវិធីក្នុងបទល្មើសជាក់លាក់មួយជាពិសេសនោះ នាងខ្ញុំផ្ទាល់ក៏ចង់ដឹង និងចង់សិក្សាឲ្យស៊ីជម្រៅបន្ថែមទៀតអំពីខ្លឹមសារ និងអន្តរន័យរវាងក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ផងដែរ ។

នៅក្នុងការស្រាវជ្រាវ និងចងក្រងឯកសារនេះឡើង ប្រាកដជាមាននូវចំណុចខ្វះខាតខាងផ្នែកខ្លឹមសារ និងកំហុសឆ្គងខាងអក្ខរាវិរុទ្ធជាក់ជាមិនខាន ។ ដូច្នេះ នាងខ្ញុំសង្ឃឹមថា រាល់កំហុសឆ្គងទាំងឡាយណា ដែលកើតមានឡើងក្នុងឯកសារនេះនឹងទទួលបាននូវការអធ្យាស្រ័យ និងការអភ័យទោសពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋានជាក់ជាមិនខាន ។

នាងខ្ញុំសូមទទួលរង់ចាំនូវការរិះគន់ និងកែតម្រូវ ក្នុងន័យស្ថាបនា ពីសំណាក់អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់គ្រប់ពេលវេលា ។

ជាទីបញ្ចប់នាងខ្ញុំ សូមជូនពរដល់អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ជួបប្រទះនូវតែពរទាំងបួនប្រការ គឺអាយុវណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........................................................................................................ ១

## ជំពូកទី១

## ស្ថាប័នប្រយុទ្ធប្រឆាំងគ្រឿងញៀន

ផ្នែកទី១ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ) ........................................ ៥

កថាខណ្ឌទី១ តួនាទី និងភារកិច្ច ........................................................................ ៥

កថាខណ្ឌទី២ រចនាសម្ព័ន្ធ ................................................................................ ៦

ផ្នែកទី២ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ........................ ៦

កថាខណ្ឌទី១ តួនាទី និងមុខងារ ........................................................................ ៦

កថាខណ្ឌទី២ រចនាសម្ព័ន្ធ ................................................................................ ៧

ផ្នែកទី៣ មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ............. ៩

កថាខណ្ឌទី១ តួនាទី និងភារកិច្ច ........................................................................ ៩

កថាខណ្ឌទី២ រចនាសម្ព័ន្ធ ................................................................................ ៩

ផ្នែកទី៤ ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត.... ១០

កថាខណ្ឌទី១ តួនាទី និងភារកិច្ច ........................................................................ ១០

កថាខណ្ឌទី២ រចនាសម្ព័ន្ធ ................................................................................ ១១

## ជំពូកទី ២

## ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌

ផ្នែកទី១ ការចាប់យកបទល្មើសគ្រឿងញៀន............................................................ ១៤

កថាខណ្ឌទី១ បទល្មើសជាក់ស្តែង ........................................................................ ១៤

កថាខណ្ឌទី២ ការប្រើប្រាស់កម្លាំងសម្ងាត់ ........................................................ ១៥

ក/. អំពីការប្រគល់ដោយមានការឃ្លាំមើល ................................................ ១៦

ខ/. អំពីការញុះញង់ឲ្យលក់ដោយខុសច្បាប់................................................ ១៧

ផ្នែកទី២ ការស៊ើបអង្កេតបទល្មើសគ្រឿងញៀន.................................................... ១៨

**កថាខណ្ឌទី១ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង** ........ **១៨**
ក/. ការស្រាវជ្រាវបទល្មើស ........ **១៨**
ខ/. ការឆែកឆេរ ........ **១៨**
ខ១. កម្មវត្ថុនៃការឆែកឆេរ ........ **១៩**
ខ២.ដំណើរការនៃការឆែកឆេរ ........ **២០**
ខ២.១ លក្ខខណ្ឌ ........ **២០**
ខ២.២ នីតិវិធី ........ **២០**
ខ២.៣ សមាសភាពចូលរួមឆែកឆេរ ........ **២១**
គ/. ការបិទស្លាកបោះត្រាលើវត្ថុតាង ........ **២១**
ឃ/. ការស្តាប់ចម្លើយ ........ **២២**
ង/. ការធ្វើតេស្ត និងការវេចខ្ចប់ ........ **២២**
ង១.ការធ្វើតេស្តបឋម ........ **២២**
ង២. ការវេចខ្ចប់ ........ **២៤**
ច/. ការឃាត់ខ្លួន ........ **២៥**
ច១. លក្ខខណ្ឌនៃការឃាត់ខ្លួន ........ **២៦**
ច២. រយៈពេលនៃការឃាត់ខ្លួន ........ **២៦**
ច៣. ការធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួន ........ **២៨**
ឆ/. ការបញ្ជូនខ្លួន ........ **២៨**
ឆ១. ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ........ **២៨**
ឆ២. រយៈពេលនៃការបញ្ជូនខ្លួន ........ **២៩**
**កថាខណ្ឌទី២ ការស៊ើបអង្កេតបឋម** ........ **២៩**
ក/. ការឆែកឆេរ ........ **៣០**
ខ/. ការបិទស្លាកលើវត្ថុតាង ........ **៣១**
គ/. ការបញ្ជាឲ្យចូលខ្លួន ........ **៣១**
ឃ/. ការឃាត់ខ្លួន និងបញ្ជូនខ្លួន ........ **៣១**

## ជំពូកទី៣
## ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលអយ្យការ


**ផ្នែកទី១ ការចោទប្រកាន់របស់ព្រះរាជអាជ្ញា** ..... ៣២

**កថាខណ្ឌទី១ ការបើកការស៊ើបសួរ** ..... ៣៣

**កថាខណ្ឌទី២ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់** ..... ៣៣

**កថាខណ្ឌទី៣ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម** ..... ៣៣

**ផ្នែកទី២ ការបើកការស៊ើបសួរ** ..... ៣៤

**កថាខណ្ឌទី១ លក្ខខណ្ឌនៃការបើកការស៊ើបសួរ** ..... ៣៤

**កថាខណ្ឌទី២ នីតិវិធីនៃការបើកការស៊ើបសួរ** ..... ៣៤

**កថាខណ្ឌទី៣ ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ** ..... ៣៦


## ជំពូកទី៤
## ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលចៅក្រមស៊ើបសួរ


**ផ្នែកទី១ ដំណើរការនៃការបើកការស៊ើបសួរ** ..... ៣៧

**កថាខណ្ឌទី១ ការបើកការស៊ើបសួរ** ..... ៣៧

**កថាខណ្ឌទី២ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ..... ៣៨

ក/. ការដាក់ឲ្យស្ថិតក្រោមការពិនិត្យ ..... ៣៨

ខ/. ការសួរចម្លើយជនត្រូវចោទ ..... ៣៩

ខ.១. ការពិភាក្សាដេញដោលចំពោះមុខ ..... ៣៩

ខ.២ ការសួរចម្លើយជនត្រូវចោទ ..... ៤០

គ/. ការស្តាប់ចម្លើយសាក្សី ..... ៤១

ឃ/. ការឃុំខ្លួន ..... ៤១

ឃ១. ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ..... ៤២

ឃ២. ដីកាបង្គាប់ឲ្យឃុំខ្លួន ..... ៤៣

ឃ៣. រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ..... ៤៣

ឃ.៣.១. រយៈពេលនៃការឃុំខ្លួននីតិជន ..... ៤៣

ឃ.៣.២. រយៈពេលនៃការឃុំខ្លួនអនីតិជនមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ ..... ៤៤

ឃ.៣.៣. រយៈពេលនៃការឃុំខ្លួនអនីតិជន ............ ៤៥
ង/. ការស៊ើបសួរចំពោះបក្ខពួក ............ ៤៥
ង១. ការចាត់ឲ្យស៊ើបសួរជំនួស ............ ៤៥
ង២. ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ............ ៤៦
ច/. ការដកយកសំណាក ............ ៤៩
ច១. ការចូលរួមដកសំណាក ............ ៤៩
ច២. នីតិវិធីនៃការដកយកសំណាកសម្រាប់ធ្វើកោសលវិច័យ ............ ៥០
ច៣. ការបញ្ចប់នីតិវិធីនៃការដកយកសំណាកសម្រាប់ធ្វើកោសលវិច័យ ............ ៥០
ឆ/. ការធ្វើកោសលវិច័យ ............ ៥១
ឆ១. ការចាត់តាំងអ្នកជំនាញ ............ ៥១
ឆ២. លទ្ធផលនៃកោសលវិច័យ ............ ៥២
ឆ៣. ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ ............ ៥៣
**ផ្នែកទី២ ដំណើរការនៃការបិទការស៊ើបសួរ ............ ៥៣**
**កថាខណ្ឌទី១ ការជូនដំណឹងអំពីការបិទស៊ើប ............ ៥៣**
**កថាខណ្ឌទី២ ការបញ្ជូនសំណុំរឿងទៅអយ្យការពិនិត្យ ............ ៥៣**
**កថាខណ្ឌទី៣ ការចេញដីកាដំណោះស្រាយ ............ ៥៤**
**កថាខណ្ឌទី៤ ការរក្សាជនជាប់ចោទឲ្យនៅក្នុងឃុំបណ្តោះអាសន្ន ............ ៥៤**
**កថាខណ្ឌទី៥ ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ............ ៥៥**

**ជំពូកទី៥**

**ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលជំនុំជម្រះ**

**ផ្នែកទី១ ដំណើរការនៃការជំនុំជម្រះ ............ ៥៦**
**កថាខណ្ឌទី១ ការចាត់តាំងចៅក្រមជំនុំជម្រះ ............ ៥៦**
**កថាខណ្ឌទី២ ការចូលរួមសវនាការ ............ ៥៧**
**កថាខណ្ឌទី៣ ការបើកសវនាការ ............ ៥៧**
**កថាខណ្ឌទី៤ ការចេញសាលក្រមសម្រេច ............ ៥៩**
**ផ្នែកទី២ ការអនុវត្តទោស ............ ៥៩**
**កថាខណ្ឌទី១ ពន្ធនាគារ និង ពិន័យ ............ ៥៩**

ក/. ការកម្រិតទោស ........................................................................................................................................ ៥៩
ខ/. ការប្រកាសមូលទោស ................................................................................................................................ ៦១
គ/. ការហាមឃាត់មិនឲ្យប្រើទោសជំនួស និងទោសបន្ថែមជំនួសឲ្យមូលទោស .................. ៦២
**ផ្នែកទី៣ ការចាត់ចែងចំពោះវត្ថុរឹបអូសដែលពាក់ព័ន្ធនឹងបទល្មើស** ............................ **៦២**
**កថាខណ្ឌទី១ ការរឹបអូសបំផ្លាញចោល** ....................................................................................... **៦៣**
**កថាខណ្ឌទី២ ការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ** ............................................................................ **៦៤**
**កថាខណ្ឌទី៣ ការប្រគល់វត្ថុចាប់យកទៅម្ចាស់ដើមវិញ** ............................................................ **៦៤**
**សេចក្តីសន្និដ្ឋាន** ........................................................................................................................ **៦៧**
**អនុសាសន៍** ................................................................................................................................. **៧០**
**ឯកសារយោង**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

ស្ថិតក្នុងស្ថានភាពដែលពិភពលោក និងតំបន់កំពុងតែប្រឈមទៅនឹងនិន្នាការកើតឡើងនូវការផលិត ការចរាចរណ៍ និងតម្រូវការទីផ្សារប្រើប្រាស់គ្រឿងញៀននោះ ព្រះរាជាណាចក្រកម្ពុជាក៏ជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើនទៀត ដែលទទួលរងគ្រោះដោយសារឥទ្ធិពលនៃគ្រឿងញៀនផងដែរ ។ នៅដំណាក់កាលចុងក្រោយនេះ ការប្រើប្រាស់គ្រឿងញៀនបានរីករាលដាលគួរឲ្យព្រួយបារម្ភជាពិសេសក្នុងស្រទាប់យុវវ័យ ដោយបង្កឲ្យមានក្តីកង្វល់ជារួមក្នុងសង្គមកម្ពុជា ។ ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍គ្រឿងញៀនដែលកំពុងមានការព្រួយបារម្ភនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (ហៅកាត់ថា អ.ជ.ប.គ.ញ) នៅក្នុងឆ្នាំ ១៩៩៥ ដើម្បីធ្វើជាស្ថាប័នសម្របសម្រួល និងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យគ្រឿងញៀន ។ ស្របពេលជាមួយគ្នានេះដែរ នៅក្នុងឆ្នាំ ១៩៩៧ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនត្រូវបានប្រកាសឲ្យប្រើ ហើយច្បាប់នេះត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៥ ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជានៅតែពុំអាចធ្វើការគ្រប់គ្រង និងទប់ស្កាត់សភាពការណ៍គ្រឿងញៀនបានល្អនៅឡើយ ដោយសារតែការវិវត្តយ៉ាងឆាប់រហ័សនៃបទល្មើសគ្រឿងញៀន ដូច្នេះដើម្បីទប់ស្កាត់ទៅនឹងការវិវត្តថ្មីៗនៃសភាពការណ៍គ្រឿងញៀននេះ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនថ្មីមួយទៀតត្រូវបានរៀបចំតាក់តែងឡើងវិញ និងប្រកាសឲ្យប្រើនៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដើម្បីធ្វើការដោះស្រាយ បង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនគ្រប់ប្រភេទឲ្យកាន់តែមានប្រសិទ្ធិភាព និងធានាការអនុវត្តកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ដែលជាភាគីនៃអនុសញ្ញា និងពិធីសាររបស់អង្គការសហប្រជាជាតិដែលទាក់ទងនឹងគ្រឿងញៀន ព្រមទាំងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងកាត់បន្ថយភាពក្រីក្រ ។

ជាការពិតណាស់ គ្រឿងញៀនជាសារធាតុដែលបណ្តាលអោយខូចសុខភាព និងបំផ្លិតបំផ្លាញសង្គមជាតិទាំងមូល យើងឃើញថា និន្នាការចរាចរ និងជួញដូរគ្រឿងញៀនមិនមានការថយចុះទេជាក់ស្តែងនៅឆ្នាំ ២០១៦ កន្លងទៅ នគរបាល និងកងរាជអាវុធហត្ថ បង្ក្រាបបាន ៤.១៩១ករណី (បទល្មើសប្រើប្រាស់គ្រឿងញៀន ១.១១២ករណី), ចាប់ជនសង្ស័យសរុប ៩.៨០២នាក់ (អ្នកប្រើប្រាស់គ្រឿងញៀន ៣.៦១១នាក់) និងរឹបអូសគ្រឿងញៀនជាង ១៧៥គីឡូក្រាម៧៩៦ក្រាម ។ បញ្ហាគ្រឿងញៀន ក៏បានជះឥទ្ធិពលដល់សកម្មភាពប្រព្រឹត្តបទល្មើសដែលកាន់តែមានចរិតសាហាវព្រៃ

ផ្សេងគិតទាំងករណីគ្រោះថ្នាក់ចរាចរណ៍ ដែលបណ្តាលមកពីអ្នកបើកបរប្រើប្រាស់គ្រឿងញៀន ។ ដោយពិនិត្យឃើញថា ឥទ្ធិពលនៃការផលិត ការចរាចរ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់បែបនេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវផែនការស្តីពីយុទ្ធនាការប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ ដែលមានរយៈពេល ៦ខែ (ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧) កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ។ គោលបំណងនៃយុទ្ធនាការនេះ គឺបន្តចាត់តាំងអនុវត្តឲ្យមានប្រសិទ្ធភាពនូវច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ និងបទបញ្ជាស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់រាជរដ្ឋាភិបាល កាលពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដែលមានគោលដៅដើម្បីបង្ការ ទប់ស្កាត់មិនឲ្យគ្រឿងញៀនបង្កឥទ្ធិពលញាំញី បំផ្លិតបំផ្លាញសង្គមជាតិកម្ពុជា ជាពិសេសប្រឹងប្រែងសម្រេចការប្តេជ្ញាចិត្តថា កម្ពុជាជាប្រទេសគ្មានគ្រឿងញៀន និងរក្សាគ្រួសារនីមួយៗជា ***គ្រួសារស្អាតស្អំគ្មានគ្រឿងញៀន*** តាមទស្សនវិស័យ "***ចូលរួមទាំងអស់គ្នាដើម្បីជីវិត និងសហគមន៍គ្មានគ្រឿងញៀន***"។

ក្នុងរយៈពេលនៃការអនុវត្តយុទ្ធនាការខាងលើ យើងឃើញថា ការចាប់យកបទល្មើសជួញដូរគ្រឿងញៀនមានភាពលំបាកជាងបទល្មើសដទៃទៀត ដោយហេតុថា បទល្មើសនេះមានភាពស្មុគស្មាញហើយជនល្មើសមានល្បិចគេចកល់ច្រើន ។ លក្ខណៈពិសេសនៃបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុនេះ គឺមន្ត្រីនគរបាលយុត្តិធម៌មិនអាចចាប់យកបទល្មើសនេះដោយជាក់ស្តែងដូចអត្ថន័យក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ទេ មានន័យថាក្នុងករណីមួយចំនួនដើម្បីបង្ក្រាបបទល្មើសនេះអោយមានប្រសិទ្ធភាព មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រើប្រាស់បញ្ញត្តិពិសេសដែលមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ដែលបញ្ញត្តិនេះអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់វិធីសាស្ត្រញុះញង់ឲ្យជនល្មើសលក់ដោយខុសច្បាប់នូវសារធាតុញៀន ឬប្រើប្រាស់កម្លាំងសម្ងាត់តាមរយៈការប្រគល់ដោយមានការឃ្លាំមើល ។

## ២.ចំណោទបញ្ហា

ដោយមើលឃើញពីបញ្ហា និងលក្ខណៈពិសេសនៃបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀនបែបនេះហើយ ទើបជំរុញឲ្យនាងខ្ញុំមានបំណងធ្វើការសិក្សាស្រាវជ្រាវអំពី "នីតិវិធីក្នុងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ថា តើមានស្ថាប័នណាខ្លះអាចធ្វើការបង្ក្រាបបទល្មើសនេះបាន ? តើការអនុវត្តវិធីសាស្ត្រញុះញង់ឲ្យជនល្មើសលក់ដោយខុសច្បាប់នូវសារធាតុញៀន ឬ ប្រើប្រាស់កម្លាំងសម្ងាត់តាមរយៈការប្រគល់ដោយមានការឃ្លាំមើលនេះប្រព្រឹត្តទៅយ៉ាងដូចម្តេច ?

ហើយតើការអនុវត្តនីតិវិធីរបស់បទល្មើសនេះ មានភាពខុសប្លែកពីបទល្មើសដទៃទៀតយ៉ាងដូចម្តេចដែរ ?

## ៣.គោលបំណង និងអត្ថប្រយោជន៍

ការសិក្សាលើប្រធានបទនេះ នាងខ្ញុំមានគោលបំណងចម្បងសិក្សា និងកំណត់ឲ្យបានច្បាស់អំពីការអនុវត្តនីតិវិធីតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ក្នុងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។

តាមរយៈការស្រាវជ្រាវលើសារណានេះ នាងខ្ញុំសង្ឃឹមថាខ្លឹមសារដែលត្រូវបានរំលេចឡើងក្នុងសារណានេះនឹងអាចធ្វើឲ្យអ្នកអនុវត្ត ក៏ដូចជាអ្នកសិក្សាក្នុងវិស័យច្បាប់អាចយល់បានកាន់តែច្បាស់អំពីការអនុវត្តនីតិវិធីក្នុងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលជាបទល្មើសកំពុងមានការរីករាលដាលយ៉ាងខ្លាំងនៅប្រទេសកម្ពុជា ។

## ៤.វិសាលភាព

ខ្លឹមសារនៃសារណានេះ នាងខ្ញុំបង្ហាញតែអំពី "នីតិវិធីក្នុងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ចាប់ពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដល់ដំណាក់កាលជំនុំជម្រះនៅតុលាការជាន់ទាបដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។

## ៥.វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវចងក្រងសារណានេះឡើង នាងខ្ញុំធ្វើការស្រាវជ្រាវដោយផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ជាមូលដ្ឋាន ។ បន្ថែមពីនេះ នាងខ្ញុំក៏បានប្រមូលនូវព័ត៌មានទាក់ទងទៅនឹងនីតិវិធីក្នុងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពីប្រភពផ្សេងៗទៀតដូចជា លិខិតបទដ្ឋានគតិយុត្ត អត្ថបទមេរៀននានា សៀវភៅ ឯកសារផ្សេងៗ ការសាកសួរសាស្ត្រាចារ្យ មន្ត្រីអនុវត្តច្បាប់ និងគ្រូដឹកនាំសារណាដែលមានបទពិសោធន៍ផងដែរ ។

## ៦.រចនាសម្ព័ន្ធសារណា

ដើម្បីឆ្លុះបញ្ចាំងពីខ្លឹមសារ ក៏ដូចជាការឆ្លើយតបនឹងចំណោទបញ្ហាដែលបានរៀបរាប់ខាងលើ

សារណានេះត្រូវបានបែងចែកជា ៥ជំពូកគឺ **ជំពូកទី១ "ស្ថាប័នប្រយុទ្ធប្រឆាំងគ្រឿងញៀន"** នឹងបង្ហាញអំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នៃស្ថាប័នពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដូចជាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានអគ្គលេខាធិការដ្ឋានជាសេនាធិការ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនជាខ្សែបណ្តោយ, មន្ទីរប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ។ **ជំពូកទី២ "ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌"** នឹងបង្ហាញអំពីការស៊ើបអង្កេត និងកសាងសំណុំរឿងរបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងបឋម ក៏ដូចជាការប្រើប្រាស់កម្លាំងសម្ងាត់របស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការចាប់យកបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ **ជំពូកទី៣ "ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលអយ្យការ"** នឹងបង្ហាញអំពីការចោទប្រកាន់របស់ព្រះរាជអាជ្ញាទៅចៅក្រមស៊ើបសួរ ។ **ជំពូកទី៤ "ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលចៅក្រមស៊ើបសួរ"** នឹងបង្ហាញអំពី ដំណើរការនៃការបើកការស៊ើបសួរ និងដំណើរការបិទការស៊ើបសួរ និងជំពូកចុងក្រោយជា **ជំពូកទី៥ "ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលជំនុំជម្រះ"** នឹងបង្ហាញអំពីដំណើរការនៃការជំនុំជម្រះ , ការអនុវត្តទោស និងការចាត់ចែងចំពោះវត្ថុរឹបអូសដែលពាក់ព័ន្ធនឹងបទល្មើស ។

# ជំពូកទី១

# ស្ថាប័នប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ផ្នែកទី១ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ) ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៥។[1] អ.ជ.ប.គ.ញ គឺជាស្ថាប័នអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។[2]

### កថាខណ្ឌទី១ តួនាទី និងភារកិច្ច

**អ.ជ.ប.គ.ញ** មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- អនុវត្តបទប្បញ្ញត្តិអនុសញ្ញាទោលស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ដែលបានធ្វើវិសោធនកម្ម ដោយពីធីសារឆ្នាំ ១៩៧២ អនុសញ្ញាស្តីពីសារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ១៩៧១ និង អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និងសារធាតុដែលធ្វើឲ្យប៉ះពាល់សរសៃប្រសាទឆ្នាំ១៩៨៨ និង បទដ្ឋានគតិយុត្តិអន្តរជាតិនានាស្តីពីគ្រឿងញៀន
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីទប់ស្កាត់ ការដាំដុះ ការផលិត ការចរាចរ ការជួញដូរគ្រឿងញៀន និងសារធាតុគីមីផ្សំគ្រឿងញៀន
- អប់រំ ផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងអំពីបញ្ហាគ្រឿងញៀនដល់សាធារណៈជនដើម្បីកាត់បន្ថយ និងឈានទៅលុបបំបាត់តម្រូវការគ្រឿងញៀន ការផ្គត់ផ្គង់គ្រឿងញៀន និងការប្រើបំពានគ្រឿងញៀន
- គ្រប់គ្រង និងបង្កើតមជ្ឈមណ្ឌលអប់រំ ព្យាបាល និងស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មអ្នកជាសះស្បើយពីគ្រឿងញៀនចូលក្នុងសហគមន៍ និងគ្រួសារវិញ
- ទំនាក់ទំនងសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ដើម្បីស្វែងរកមូលនិធិសម្រាប់សកម្មភាពបង្ការទប់ស្កាត់បទល្មើសគ្រឿងញៀន

[1] ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, លេខ នស/រកត/០៩៩៥/៦៥, ០៧ កញ្ញា ១៩៩៥។

[2] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, លេខ នស/រកម/០១១២/០០១, ០២ មករា ២០១២, មាត្រា ៧ (ពីពេលនេះតទៅហៅថាច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន)។

- ដឹកនាំ សម្របសម្រួល និងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រៀបចំ តាក់តែងអត្ថបទច្បាប់ និងបទដ្ឋានគតិយុត្ត ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ
- លើកទឹកចិត្តដល់អ្នកផ្តួចផ្តើមគំនិតក្នុងការប្រយុទ្ធប្រឆាំងនឹងជំនួញគ្រឿងញៀន សារធាតុសម្រាប់ផ្សំគ្រឿងញៀន និងការសំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់
- អាជ្ញាធរជាតិ ត្រូវធានាអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងអនុសញ្ញាអន្តរជាតិស្តីពីគ្រឿងញៀនព្រមទាំងដាក់ឲ្យអនុវត្តនូវយន្តការជាតិ និងអន្តរជាតិ ដើម្បីធានានិរន្តរភាពសម្រាប់ការត្រួតពិនិត្យគ្រឿងញៀន
- និង អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។[3]

### កថាខណ្ឌទី២ រចនាសម្ព័ន្ធ

**អ.ជ.ប.គ.ញ** មានអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ មួយជា សេនាធិការ និងមានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ជាខ្សែបណ្តោយ ។[4] អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវស្ថិតនៅក្នុងរចនាសម្ព័ន្ធ នៃក្រសួងមហាផ្ទៃ ដែលស្ថិតក្រោមការដឹកនាំដោយផ្ទាល់របស់ប្រធាន អ.ជ.ប.គ.ញ ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវបានដឹងនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងជាជំនួយ ។[5]

## ផ្នែកទី២ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

### កថាខណ្ឌទី១ តួនាទី និងមុខងារ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ គឺជាមជ្ឈមណ្ឌលកណ្តាលក្នុងការសម្របសម្រួលសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងក្របខ័ណ្ឌនៃការអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់អាជ្ញាធរជាតិ

[3] ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, លេខ នស/រកត/០៥០៩/៦០៨, ៣០ ឧសភា ២០០៩, មាត្រា ២ (ពីពេលនេះតទៅហៅថាព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន)។

[4] ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា ៣។

[5] ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា ៨។

ប្រយុទ្ធប្រឆាំងគ្រឿងញៀន ។[6] អគ្គលេខាធិការដ្ឋាននេះ មានតួនាទីដ៏សំខាន់ក្នុងការប្រមូលពត៌មាន និងចូលរួមប្រតិបត្តិការប្រឆាំងនឹងការដាំដុះ ការផលិត ការជួញដូរគ្រឿងញៀនខុសច្បាប់ និង សម្របសម្រួលរាល់សកម្មភាពត្រួតពិនិត្យគ្រឿងញៀនរបស់អង្គភាពប្រតិបត្តិដទៃទៀត ដើម្បីធានាប្រសិទ្ធភាព និងសុវត្ថិភាពនៃការបង្ក្រាបគ្រឿងញៀនខុសច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។ នៅក្នុងតួនាទីនេះ អគ្គលេខាធិការដ្ឋានមានមុខងារសំខាន់ៗ ដូចតទៅ ៖

- រៀបចំជូន អ.ជ.ប.គ.ញ និងរាជរដ្ឋាភិបាល នូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព បង្ក្រាបការដាំដុះ ការផលិត ការជួញដូរគ្រឿងញៀនខុសច្បាប់ និងការប្រើបំពានគ្រឿងញៀន ដោយសម្របសម្រួលឲ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់ក្រសួង-ស្ថាប័ន និង អង្គការពាក់ព័ន្ធដទៃទៀត
- រ៉ាប់រងការអនុវត្តគោលនយោបាយ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងអ.ជ.ប.គ.ញ
- ជម្រុញ និង សម្របសម្រួលវិធានការត្រួតពិនិត្យគ្រឿងញៀន ដែលរៀបចំឡើងដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ
- រៀបចំជូន អ.ជ.ប.គ.ញ និងរាជរដ្ឋាភិបាល នូវគោលនយោបាយជាតិស្តីពីវិធានការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- ធ្វើទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាលបរទេស និង អង្គការអន្តរជាតិនានា ក្នុងការត្រួតពិនិត្យគ្រឿងញៀន ។[7]

### កថាខណ្ឌទី២ រចនាសម្ព័ន្ធ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ មានរចនាសម្ព័ន្ធជានាយកដ្ឋាន និងអង្គភាពដែលមានថ្នាក់ស្មើនាយកដ្ឋានរួមមាន៖[8]

- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ៖ មានភារកិច្ចគ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន, គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ ធ្វើបញ្ជី

[6] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៧។

[7] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, លេខ ១៣ អនក្រ.បក, ២២ កុម្ភៈ ២០០៧, មាត្រា ២ (ពីពេលនេះតទៅហៅថាអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន)។

[8] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា ៥។

សារពើភ័ណ្ឌរបស់អគ្គលេខាធិការដ្ឋាន ។[9]

- នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល ៖ មានភារកិច្ចរៀបចំយុទ្ធសាស្ត្រ និង លើកផែនការគោលនយោបាយក្នុងការបង្ក្រាបការដាំដុះ ការផលិត ការជួញដូរ ការនាំចេញ និងនាំចូលការដឹកជញ្ជូននូវគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។[10]
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ៖ មានភារកិច្ចទំនាក់ទំនងនឹងរដ្ឋាភិបាលបរទេស និងអង្គការអនុតំបន់ ឬ អន្តរជាតិនានា, ចូលរួមក្នុងសកម្មភាពប្រចាំអនុតំបន់នានា ឬអន្តរជាតិជាដើម ។[11]
- នាយកដ្ឋានអនុវត្តច្បាប់ ៖ មានភារកិច្ចតាមដាន និងអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសាលក្រមតុលាការដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។[12]
- នាយកដ្ឋាន នីតិកម្ម អប់រំ និងស្តារនីតិសម្បទា ៖ មានភារកិច្ចរៀបចំ និងអនុវត្តកម្មវិធីអប់រំ បង្ការ ទប់ស្កាត់ និងកាត់បន្ថយការប្រើបំពានគ្រឿងញៀនក្នុងប្រទេសដោយសម្របសម្រួល និងសហការឲ្យបានល្អជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។[13]
- នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យ ៖ មានភារកិច្ចស្រាវជ្រាវ ក្តាប់សភាពការណ៍ ប្រមូលពត៌មានទូទៅដែលពាក់ព័ន្ធនឹងសារធាតុគីមី និង សារធាតុទាំងឡាយដែលប្រើប្រាស់សម្រាប់ផ្សំគ្រឿងញៀន ព្រមទាំងសារធាតុដែលធ្វើអោយប៉ះពាល់សរសៃប្រសាទ ។[14]
- មន្ទីរពិសោធន៍គ្រឿងញៀន ៖ មានភារកិច្ចធ្វើការវិភាគ ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ លើលក្ខណ:គិមី និងលក្ខណ:រូបនៃសារធាតុគ្រឿងញៀន និងគីមីផ្សំគ្រឿងញៀន, ធ្វើការវិភាគរកគុណភាពបរិមាណសារធាតុញៀន និងគីមីផ្សំគ្រឿងញៀន ដែលក្រសួង-ស្ថាប័នមាន

[9] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា ៧។

[10] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា ៨។

[11] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា ៩។

[12] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា ១០។

[13] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា ១១។

[14] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា ១២។

សមត្ថកិច្ចប្រគល់ជូន និងផ្តល់ជូននូវលទ្ធផលនៃការវិភាគទាំងនេះវិញ ។[15]

## ផ្នែកទី៣ មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

### កថាខណ្ឌទី១ តួនាទី និងភារកិច្ច

មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន មានតួនាទីធ្វើជាសេនាធិការក្នុងការសិក្សារៀបចំគោលការណ៍ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀនដែលមានភារកិច្ចដូចខាងក្រោម៖[16]

- ប្រមែប្រមូលព័ត៌មាន វិភាគបទល្មើសគ្រឿងញៀនគ្រប់ប្រភេទ ដើម្បីផ្តើមស្នើវិធានការ បង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសស្របតាមច្បាប់ជាតិ និងអន្តរជាតិ
- ប្រមែប្រមូលព័ត៌មាន សម្របសម្រួលការស្រាវជ្រាវស៊ើបអង្កេត និងបង្ក្រាបបទល្មើសគ្រឿងញៀនខុសច្បាប់នៅក្នុងផ្ទៃប្រទេស និងអន្តរជាតិ
- សម្របសម្រួលជាមួយព្រះរាជអាជ្ញា តុលាការ សំដៅធានាការអនុវត្តនីតិវិធីកិច្ចប្រតិបត្តិការ និងការអនុវត្តសាលក្រម សាលដីកា
- ទទួលអនុវត្តភារកិច្ច និង សិទ្ធិផ្សេងៗទៀតដែលប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ប្រគល់ឲ្យ ។ល។

### កថាខណ្ឌទី២ រចនាសម្ព័ន្ធ

អគ្គស្នងការដ្ឋាននគរបាលជាតិ ជាសេនាធិការនៃក្រសួងមហាផ្ទៃ ដែលមានរចនាសម្ព័ន្ធដូចខាងក្រោម ៖[17]

**ក-នាយកដ្ឋានបុគ្គលិក**

**ខ-សេនាធិការដ្ឋាន ៖** មាន ៩នាយកដ្ឋានគឺ នាយកដ្ឋានរដ្ឋបាលទូទៅ, នាយកដ្ឋានសរុប

[15] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា ១៣។

[16] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ, លេខ ១០៩ អនក្រ.បក, ១៩ សីហា ២០១៥, មាត្រា ២៨។

[17] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ, លេខ ១០៩ អនក្រ.បក, ១៩ សីហា ២០១៥, មាត្រា ២៥។

ផែនការ, នាយកដ្ឋានវិទ្យុទាក់ទង, នាយកដ្ឋានអក្សរសម្ងាត់, អង្គភាពអន្តរាគមន៍, ស្នងការដ្ឋានហិរញ្ញកិច្ច និងភស្តុភារ, អង្គភាពតម្រួតបញ្ជា, នាយកដ្ឋាននគរបាលការពារ និងនាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល ។

**គ-នាយកដ្ឋានកណ្តាលនគរបាលព្រំដែន ៖** មាន៣នាយកដ្ឋានគឺ នាយកដ្ឋាននគរបាលព្រំដែនគោក, នាយកដ្ឋាននគរបាលព្រំដែនទឹក និងនាយកដ្ឋាននគរបាលបច្ចេកទេសព្រំដែន ។

**ឃ-នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ៖** មាន៥នាយកដ្ឋានគឺ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ, នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច, នាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ, នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងមន្ទីរប្រឆាំងគ្រឿងញៀន ។

**ង-នាយកដ្ឋានកណ្តាលសន្តិសុខ ៖** មាន៦នាយកដ្ឋានគឺ នាយកដ្ឋានសន្តិសុខផ្ទៃក្នុង, នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន, នាយកដ្ឋានអង្គរក្ស, នាយកដ្ឋានចារកម្ម, នាយកដ្ឋានស៊ើបការណ៍ខាងក្រៅ និងបច្ចេកទេស និងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកទេស ។

**ច-នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ៖** មាន៥នាយកដ្ឋានគឺ នាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ, នាយកដ្ឋាននគរបាលទេសចរណ៍, នាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ, នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងនាយកដ្ឋាននគរបាលបង្ការពន្លត់អគ្គីភ័យ និងសង្គ្រោះ ។

**ឆ-ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ។**

## ផ្នែកទី៤ ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត

### កថាខណ្ឌទី១ តួនាទី និងភារកិច្ច

ការិយាល័យប្រឆាំងគ្រឿងញៀន មានតួនាទីធ្វើជាសេនាធិការជូនស្នងការដ្ឋានលើការងារប្រឆាំងគ្រឿងញៀនដែលមានភារកិច្ចដូចខាងក្រោម៖[18]

[18] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត, លេខ ១៣៣០០ ប្រក, ២៩ វិច្ឆិកា ២០១៦, ប្រការ ៩។

- ចាត់វិធានការជំនាញបង្ការ និងបង្ក្រាបការប្រើប្រាស់ ការដឹកជញ្ជូន ការធ្វើជំនួញគ្រឿងញៀនគ្រប់ប្រភេទ
- ស្រាវជ្រាវតាមដានបុគ្គល យានជំនិះ ទីកន្លែងគោលដៅ និងប្រមូលព័ត៌មានពាក់ព័ន្ធសកម្មភាពអត្តសញ្ញាណជនសង្ស័យ
- ស្រាវជ្រាវស្វែងរកច្រកផ្លូវធ្វើសកម្មភាព និងសមាសភាពក្រុមឧក្រិដ្ឋជនគ្រឿងញៀនមានការចាត់តាំងជាប្រព័ន្ធជួញដូរ ដឹកជញ្ជូន និងផលិតគ្រឿងញៀន
- សហការជាមួយអង្គភាពពាក់ព័ន្ធប្រមូលព័ត៌មានអំពីសកម្មភាពជំនួញសារធាតុញៀន សារធាតុគីមីផ្សំហាមឃាត់ និងការផលិតកែច្នៃគ្រឿងញៀនខុសច្បាប់ ការដាំដុះរុក្ខជាតិញៀន ការជួញដូរ ការចរាចរ ការដឹកជញ្ជូន ការរក្សាទុក ការស្តុកទុកគ្រឿងញៀនខុសច្បាប់
- សិក្សាល្បិចកលការលាក់បំពួន ការដឹកជញ្ជូន និងសហការត្រួតពិនិត្យស្វែងរកការនាំចេញនាំចូល ដឹកជញ្ជូន ការផលិតស្តុកទុកសារធាតុញៀន សារធាតុគីមីផ្សំហាមឃាត់ ឪសថមានផ្ទុកសារធាតុញៀនដែលច្បាប់កំណត់ និងការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ទៅជាការផលិតគ្រឿងញៀនខុសច្បាប់
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ដើម្បីបម្រើការងារជំនាញតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀតដែលស្នងការប្រគល់ឲ្យ ។ -ល- ។

### កថាខណ្ឌទី២ រចនាសម្ព័ន្ធ

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ស្ថិតនៅក្រោមឪវាទអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងស្ថិតនៅក្រោមការបញ្ជាដឹកនាំជំនាញរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ មានសមត្ថកិច្ចការពារ និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនប្រជាពលរដ្ឋនៅក្នុងរាជធានី ខេត្ត ។[19] ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានរចនាសម្ព័ន្ធដូចខាងក្រោម ៖[20]

**ក-ផែនគ្រប់គ្រងធនធានមនុស្ស** ៖ មាន២ការិយាល័យគឺ ការិយាល័យបុគ្គលិក និងការិយាល័យបណ្តុះបណ្តាល ។

[19] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត, លេខ ១៣៣០០ ប្រក, ២៩ វិច្ឆិកា ២០១៦, ប្រការ ១។

[20] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត, លេខ ១៣៣០០ ប្រក, ២៩ វិច្ឆិកា ២០១៦, ប្រការ ៣។

**ខ-ផែនសេនាធិការ៖** មាន៦ការិយាល័យគឺ ការិយាល័យរដ្ឋបាល, ការិយាល័យសរុប ផែនការ, ការិយាល័យវិទ្យុទាក់ទង, ការិយាល័យអក្សរសម្ងាត់, ការិយាល័យកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល និងការិយាល័យអន្តរាគមន៍ និងតម្រួតបទបញ្ជា ។

**គ-ផែននគរបាលព្រហ្មទណ្ឌ** ៖ មាន៣ការិយាល័យគឺ ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់, ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល និងការិយាល័យនគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ ។

**ឃ-ផែនប្រឆាំងបទល្មើស ៖** មាន៣ការិយាល័យគឺ ការិយាល័យនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច, ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការិយាល័យប្រឆាំងគ្រឿងញៀន ។

**ង-ផែនសន្តិសុខ ៖** មាន៥ការិយាល័យគឺ ការិយាល័យសន្តិសុខផ្ទៃក្នុង, ការិយាល័យប្រឆាំងភេរវកម្ម និង ឧក្រិដ្ឋកម្មឆ្លងដែន, ការិយាល័យគ្រប់គ្រងសន្តិសុខឯកជន[21], ការិយាល័យប្រឆាំងបទល្មើសបច្ចេកទេស[22] និងការិយាល័យអង្គរក្ស[23] ។

**ច-ផែនសណ្តាប់ធ្នាប់៖** មាន៥ការិយាល័យគឺ ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក, ការិយាល័យនគរបាលចរាចរណ៍ផ្លូវទឹក[24], ការិយាល័យសណ្តាប់ធ្នាប់, ការិយាល័យនគរបាលទេសចរណ៍[25] និងការិយាល័យនគរបាលការពារបេតិកភណ្ឌ[26] ។

**ឆ-ផែនគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងអគ្គីភ័យ ៖** មាន២ការិយាល័យគឺ ការិយាល័យនគរបាលបង្ការពន្លត់អគ្គីភ័យ និងសង្គ្រោះ និងការិយាល័យគ្រប់គ្រង់អាវុធគ្រឿងផ្ទុះ និងជាតិពុល ។

[21] មាននៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ កណ្តាល កំពង់ស្ពឺ ព្រះសីហនុ និងខេត្តសៀមរាប។

[22] មាននៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

[23] មាននៅស្នងការដ្ឋាននគរបាលខេត្តសៀមរាប។

[24] មាននៅស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដែលមានផ្លូវទឹក។

[25] មាននៅស្នងការដ្ឋាននគរបាលខេត្តមួយចំនួន។

[26] មាននៅស្នងការដ្ឋាននគរបាលខេត្តមួយចំនួន។

**ជ-ផែនអន្តោប្រវេសន៍** ៖ មាន២ការិយាល័យគឺ ការិយាល័យគ្រប់គ្រងជនបរទេស និងការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី ។

**ឈ-ផែនអត្តសញ្ញាណកម្ម** ៖ មាន២ការិយាល័យគឺ ការិយាល័យគ្រប់គ្រងស្នាក់នៅ និងការិយាល័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

**ញ-ផែនភស្តុភារ និងហិរញ្ញវត្ថុ** ៖ មាន៤ការិយាល័យគឺ ការិយាល័យផ្សព្វផ្សាយអប់រំ, ការិយាល័យភស្តុតាង, ការិយាល័យគណនេយ្យ និងការិយាល័យសុខាភិបាល ។

**ដ-វរសេនាតូចនគរបាលការពារព្រំដែនគោក,**

**ឋ-អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ**

**ឌ-ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ។**

# ជំពូកទី ២

# ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌

## ផ្នែកទី១ ការចាប់យកបទល្មើសគ្រឿងញៀន

បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន[27] ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ជនល្មើសដែលប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺប្រកបទៅដោយល្បិចកលខ្ពស់ និងធ្វើសកម្មភាពក្រោមរូបភាពខុសប្លែកៗគ្នាជាច្រើន ។ ដូច្នេះការចាប់យកបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀននេះ អាចស្តែងឡើងក្នុងរូបភាពជា ការចាប់យកបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែង ឬការចាប់យកដោយប្រើប្រាស់កម្លាំងសម្ងាត់តាមរយៈការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់គ្រឿងញៀន ។[28]

### កថាខណ្ឌទី១ បទល្មើសជាក់ស្តែង

បទល្មើសខាងក្រោមនេះជាបទល្មើសជាក់ស្តែង ដែលត្រូវបានអាជ្ញាធរមានសមត្ថកិច្ចចុះបង្ក្រាបដើម្បីចាប់គ្រឿងញៀនដែលខុសច្បាប់គឺ ៖

- បទល្មើសដែលកំពុងប្រព្រឹត្ត
- បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម
- ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រភីង

[27] សូមមើលតារាងសារធាតុញៀន ដែលមានក្នុងឧបសម្ព័ន្ធខាងក្រោយ។

[28] កញ្ញា អ៊ី ម៉ាណូកា, *"ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"* (សីហា ២០១៦), ៤ (ពីពេលនេះតទៅហៅថាចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។[29]
- បទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ។[30]

### កថាខណ្ឌទី២ ការប្រើប្រាស់កម្លាំងសម្ងាត់

បទល្មើសជួញដូរគ្រឿងញៀន គឺជាបទល្មើសដែលពិបាកនឹងធ្វើការបង្ក្រាបដើម្បីឈានទៅរកការចាប់បានទាំងជនល្មើស និងគ្រឿងញៀន ដោយសារតែមានករណីជាច្រើនបទល្មើសនេះមិនអាចចាប់បានដោយនគរបាលប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអាជ្ញាធរដែលមានសមត្ថកិច្ច ។ កត្តាទាំងនេះបណ្តាលឲ្យមានការបង្កើតជាបទបញ្ញត្តិពិសេស ដែលអនុញ្ញាតឲ្យមានការប្រើប្រាស់កម្លាំងសម្ងាត់ដើម្បីជាជំនួយការក្នុងការស៊ើបអង្កេត និងចាប់បាននូវបទល្មើសនេះ ។[31] ការប្រើប្រាស់កម្លាំងសម្ងាត់នេះត្រូវបានធ្វើឡើងក្រោមរូបភាពជា ការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់គ្រឿងញៀន ដែលវាជាវិធានការពិសេស ដែលអនុញ្ញាតឲ្យមានការប្រើប្រាស់កម្លាំងសម្ងាត់សម្រាប់ធ្វើជាផ្ទាក់ចាប់ជនល្មើសដែលប្រព្រឹត្តបទល្មើស ។ ក្នុងករណីចាំបាច់ដើម្បីបម្រើឲ្យការស៊ើបអង្កេតបទល្មើសគ្រឿងញៀន មន្ត្រីមានសមត្ថកិច្ចតាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬរបស់មន្ត្រីប្រតិភូរបស់ក្រសួងយុត្តិធម៌ អាចសម្រេចអនុញ្ញាតឲ្យប្រើវិធីប្រគល់ដោយមានការឃ្លាំមើល ឬប្រើវិធីញុះញង់ឲ្យលក់ដោយខុសច្បាប់នូវសារធាតុញៀន ។ ការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់គ្រឿងញៀននេះ អាចធ្វើឡើងដោយមន្ត្រីដែលមានសមត្ថកិច្ចដោយផ្ទាល់ ឬតាមរយៈជនណាម្នាក់ដែលអនុវត្តតាមបញ្ជារបស់មន្ត្រីមានសមត្ថកិច្ចនោះ ។ ការសម្រេចឲ្យប្រើវិធីប្រគល់ដោយមានការឃ្លាំមើល ឬ ប្រើវិធីញុះញង់ឲ្យលក់គ្រឿងញៀនត្រូវធ្វើសម្រាប់ករណីនីមួយៗ ហើយបើសិនជាត្រូវធ្វើជាលក្ខណៈអន្តរជាតិ គឺផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងជាមួយប្រទេសឯទៀតដែលមានប្រយោជន៍ក្នុងរឿងនេះ ។ សេចក្តីសម្រេចឲ្យប្រើវិធីប្រគល់ដោយមានការ

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨៦ (ពីពេលនេះតទៅហៅថាក្រមនីតិវិធីព្រហ្មទណ្ឌ) ។

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៨៨។

[31] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ៥។

ឃ្លាំមើលត្រូវជូនដំណឹងភ្លាមទៅស្ថាប័នមានសមត្ថកិច្ចនៃកន្លែងដែលសន្មតថាជាកន្លែងបញ្ជូនចេញ ឬកន្លែងបញ្ជូនចូលមកលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ម្យ៉ាងទៀត ត្រូវជូនដំណឹងភ្លាមផង ដែរទៅស្ថាប័នមានសមត្ថកិច្ចនៃកន្លែងដែលសន្មតថាជាកន្លែងដែលប្រគល់ ឬ កន្លែងបញ្ចេញ ។ សេចក្តីសម្រេចអនុញ្ញាតឲ្យប្រើវិធីញុះញង់ឲ្យលក់ ត្រូវជូនដំណឹងភ្លាមទៅតុលាការដែលមានសមត្ថកិច្ចនៃកន្លែងដែលសន្មតថាជាកន្លែងលក់ ។[32]

យោងទៅតាមប្រកាសលេខ **០៩ កយ.ប្រក/០៦** ស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់ដោយខុសច្បាប់ ត្រង់ប្រការ១ បានប្រគល់តួនាទីជាអាជ្ញាធរដែលត្រូវសម្រេចអំពីការប្រើប្រាស់នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល ឬ ញុះញង់ឲ្យលក់ ជូនមហាអយ្យការអមសាលាឧទ្ធរណ៍ ។ ក្នុងករណីបន្ទាន់ដែលចាំបាច់ត្រូវប្រើប្រាស់នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល ឬ ការញុះញង់ឲ្យលក់ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចលើទីតាំងដែលត្រូវអនុវត្តនីតិវិធីនោះ អាចសម្រេចឲ្យមានការប្រើប្រាស់នីតិវិធីនេះបាន ក្នុងនាមមហាអយ្យការអមសាលាឧទ្ធរណ៍ ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាដែលចេញសេចក្តីសម្រេចត្រូវជូនដំណឹងភ្លាមទៅមហាអយ្យការអមសាលាឧទ្ធរណ៍ ។[33]

### ក/. អំពីការប្រគល់ដោយមានការឃ្លាំមើល

ក្នុងការអនុវត្តនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើលទៅលើបទល្មើស អាជ្ញាធរអាចសម្រេចឲ្យប្រើប្រាស់ ៖

- គ្រឿងញៀន
- ឧបករណ៍ បរិក្ខារ ឬសម្ភារៈដទៃៗទៀត ដែលជនល្មើសប៉ុនប៉ងយកទៅប្រើប្រាស់ ឬកំពុងប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស
- មូលនិធិ ឬវត្ថុមានតម្លៃដទៃៗទៀត ដែលពាក់ព័ន្ធទៅនឹងបទល្មើស

[32] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៧៩។

[33] ប្រកាសស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់ដោយខុសច្បាប់, លេខ ០៩.កយ.ប្រក/០៦, ០៨ កុម្ភៈ ២០០៦, ប្រការ២ (ពីពេលនេះតទៅហៅថាប្រកាសស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់ដោយខុសច្បាប់)។

ការប្រើប្រាស់វិធីខាងលើនេះ គឺក្នុងគោលបំណងដើម្បីសម្រួលដល់ការស៊ើបអង្កេតឲ្យមានប្រសិទ្ធភាពដោយអនុញ្ញាតឲ្យមន្ត្រីមានសមត្ថកិច្ចចូលរួមក្នុងបទល្មើសទាំងឡាយដូចជា ការទំនាក់ទំនង ការឃុបឃិត ការប៉ុនប៉ង ឬការសមគំនិតជាមួយជនល្មើសក្នុងអំពើណាមួយដើម្បីកំណត់ឲ្យបានច្បាស់អំពីបទល្មើសនោះ និងជនពាក់ព័ន្ធដែលត្រូវធ្វើការចោទប្រកាន់។ មន្ត្រីអនុវត្តច្បាប់នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល អាចបញ្ជាឲ្យធ្វើអន្តរាគមន៍នៅគ្រប់ដំណាក់កាលទាំងអស់នៃប្រតិបត្តិការរបស់ខ្លួនប្រសិនបើត្រូវការទប់ស្កាត់ភាពអសន្តិសុខភ្លាមៗ ឬមានការផ្លាស់ប្តូរទិសដៅនៃការបញ្ជូនដែលមិនបានរំពឹងទុកជាមុនបាន ឬមានកាលៈទេសៈផ្សេងៗទៀតដែលជាឧបសគ្គដល់ការរឹបអូសវត្ថុបញ្ជូន ឬឲ្យធ្វើសកម្មភាពស្របច្បាប់ណាមួយសម្រាប់តទល់នឹងជនល្មើស ។[34]

### ខ/. អំពីការញុះញង់ឲ្យលក់ដោយខុសច្បាប់

អាជ្ញាធរអាចសម្រេចប្រគល់សិទ្ធិដល់មន្ត្រីអនុវត្តច្បាប់ណាមួយឲ្យធ្វើការញុះញង់ជនទាំងឡាយណាដែលមានមូលហេតុធ្ងន់ល្មមសង្ស័យថាបានប្រព្រឹត្ត កំពុងប្រព្រឹត្ត ឬ រៀបចំប្រព្រឹត្តបទល្មើសទាក់ទងទៅនឹងគ្រឿងញៀន ដើម្បីអោយជននោះលក់ដោយខុសច្បាប់នូវ ៖

- គ្រឿងញៀន ឬ សារធាតុដទៃៗទៀត ដែលមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ឧបករណ៍ បរិក្ខារ ឬសម្ភារៈដទៃៗទៀត ដែលជនល្មើសមានចេតនាយកទៅប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ។

ការប្រើប្រាស់វិធីខាងលើនេះ គឺក្នុងគោលបំណងដើម្បីសម្រួលដល់ការស៊ើបអង្កេតឲ្យមានប្រសិទ្ធភាព ដោយអនុញ្ញាតឲ្យមន្ត្រីមានសមត្ថកិច្ចចូលរួមក្នុងបទល្មើសទាំងឡាយដូចជា ការទំនាក់ទំនង ការឃុបឃិត ការប៉ុនប៉ង ឬការសមគំនិតជាមួយជនល្មើសក្នុងអំពើណាមួយ ដើម្បីកំណត់ឲ្យបានច្បាស់អំពីបទល្មើសនោះ និងជនពាក់ព័ន្ធដែលត្រូវធ្វើការចោទប្រកាន់ ។ នៅពេលសម្រេចឲ្យប្រើប្រាស់វិធីនេះ អាជ្ញាធរត្រូវពិចារណាឲ្យបានហ្មត់ចត់ មួយផ្នែកទៅលើភស្តុតាងដែលបានប្រមូល និងមួយផ្នែកទៀតទៅលើលទ្ធភាពផ្សេងៗ ដែលជាការប្រថុយប្រថានទៅនឹងគ្រោះថ្នាក់របស់បុគ្គលដែលមានការពាក់ព័ន្ធក្នុងសកម្មភាពល្មើស ដែលតាមធម្មតាប្រសិនជាយើងមិនញុះញង់ទេគេពុំធ្វើដូច្នោះឡើយ ។ វិធីដូចកំណត់ខាងលើនេះ អាចអនុវត្តបានដោយបុគ្គលឯកជនធម្មតាក្រោមបញ្ជា និងក្រោមការត្រួតពិនិត្យផ្ទាល់របស់មន្ត្រីអនុវត្តច្បាប់ដែលបានចាត់តាំង ។ មន្ត្រីអនុវត្តច្បាប់ ឬបុគ្គល

[34] ប្រកាសស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់ដោយខុសច្បាប់, ប្រការ៣។

ធម្មតាដែលបានទទួលការចាត់តាំងឲ្យអនុវត្តវិធីញុះញង់ឲ្យលក់ដោយខុសច្បាប់ មិនត្រូវទទួលការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ការដាក់ទណ្ឌកម្មផ្នែករដ្ឋបាល ឬផ្នែករដ្ឋប្បវេណី ចំពោះសកម្មភាពទាំងឡាយដែលខ្លួនបានធ្វើក្នុងវង្វង់សិទ្ធិដែលបានអនុញ្ញាតឡើយ ។[35]

## ផ្នែកទី២ ការស៊ើបអង្កេតបទល្មើសគ្រឿងញៀន

### កថាខណ្ឌទី១ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង

#### ក/. ការស្រាវជ្រាវបទល្មើស

វិធានដំបូងនៃបទល្មើសនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ។[36]មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុ[37]ស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។[38]

#### ខ/. ការឆែកឆេរ

មន្ត្រីនគរបាលយុត្តិធម៌ ដែលមាននីតិសម្បទាត្រូវបានអនុញ្ញាតឲ្យឆែកឆេរ[39]នៅតាមព្រំដែន លើខ្លួនបុគ្គល យានជំនិះ សម្ភារៈ ជាអាទិ៍ កាលបើមានសញ្ញានាំឲ្យមានការសង្ស័យថា នៅលើខ្លួនបុគ្គល យានជំនិះ សម្ភារៈទាំងនោះមានផ្ទុកនូវសារធាតុញៀន ។ ការឆែកឆេរខ្លួនបុគ្គល ត្រូវធ្វើឡើងដោយបុគ្គលដែលមានភេទដូចគ្នា តាមបញ្ញាជាធរមាន ។[40]

---

[35] ប្រកាសស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់ដោយខុសច្បាប់, ប្រការ៥។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៨៩។

[37] កំណត់ហេតុ គឺជាធាតុមូលដ្ឋាននៃនីតិវិធីដែលសរសេរលាយលក្ខអក្សរ និងចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ម្នាក់ដែលធ្វើសកម្មភាពស្របតាមវិធានសមត្ថកិច្ចខ្លួន និងក្នុងក្របខ័ណ្ឌបេសកកម្ម នគរបាលយុត្តិធម៌ (អំណោយស្ថានទូតបារាំង, *នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល* (២០០៩), ៥៦។

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៩០។

[39] ឆែកឆេរ ៖ គឺជាការស្វែងរក រុករក ពិនិត្យយ៉ាងម៉ត់ចត់ ដើម្បីរកឃើញនូវអ្វីមួយដែលគេលាក់ (អំណោយស្ថានទូតបារាំង , *នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល* (២០០៩), ១២៨។

[40] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៧៥ ។

### ២១. កម្មវត្ថុនៃការឆែកឆេរ

កម្មវត្ថុនៃការឆែកឆេរ ត្រូវបានធ្វើការបែងចែកជា ៣ ប្រភេទគឺៈ[41]

- វត្ថុដែលជាកម្មវត្ថុគ្រឿងញៀន ៖ វត្ថុដែលជាកម្មវត្ថុនៃការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាសារធាតុដែលបង្កឲ្យញៀនជាអាទិ៍ ដូចដែលមានក្នុងតារាងឧបសម្ព័ន្ធនៃតារាងទី១ (រុក្ខជាតិ និងសារធាតុដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយដែលពុំមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ), តារាងទី២ (រុក្ខជាតិ និងសារធាតុដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប៉ុន្តែមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ), តារាងទី៣ (រុក្ខជាតិ និងសារធាតុដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប៉ុន្តែមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ) និងតារាងទី៤ (សារធាតុគិមីផ្សំទាំងឡាយដែលបានចាត់ថ្នាក់ក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៨៨ ឬក្នុងការអនុវត្តអនុសញ្ញានេះប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់) ។[42]
- វត្ថុផ្ទាល់ខ្លួន ៖ វត្ថុដែលមានមន្ទិលសង្ស័យជាប់ពាក់ព័ន្ធនឹងបទល្មើស ជាទូទៅវត្ថុផ្ទាល់ខ្លួនរបស់ជនល្មើសដែលត្រូវបានឆែកឆេរ និងចាប់យកមានដូចជាទូរស័ព្ទ ឬលុយកាក់ដែលមាននៅជាប់ខ្លួន ។ បន្ថែមលើសពីនេះ ករណីខ្លះសូម្បីតែគ្រឿងអលង្ការដែលពាក់ជាប់ខ្លួនក៏ត្រូវបានដកទុក ជាបណ្តោះអាសន្នផងដែរ ។[43]
- វត្ថុកើតចេញពីបទល្មើស ៖ វត្ថុដែលកើតចេញពីផលនៃបទល្មើសដូចជា រថយន្ត ម៉ូតូ ជាអាទិ៍ ។

[41] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ១៣។

[42] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៥។

[43] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ១៣។

## ១២.ដំណើរការនៃការឆែកឆេរ

### ១២.១ លក្ខខណ្ឌ

បទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាបទល្មើសពិសេសហើយវាជាបដិបញ្ញត្តិនឹងលក្ខខ័ណ្ឌនៃការឆែកឆេរ ដោយមិនទាមទារឲ្យគោរពទៅនឹងលក្ខខណ្ឌពេលវេលានៃការចុះឆែកឆេរនោះទេ មានន័យថា មន្ត្រីនគរបាលយុត្តិធម៌អាចចុះឆែកឆេរនៅពេលណាក៏បាន ដោយអាចធ្វើការឆែកឆេរមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ៦ល្ងាច[44]ដែលវាមានលក្ខណៈខុសប្លែកពីបទល្មើសទូទៅដែលទាមទារឲ្យធ្វើការគោរពពេលវេលានៃការឆែកឆេរ ។

### ១២.២ នីតិវិធី

ក្នុងករណីបទល្មើសជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងដែលទទួលបាននូវការអនុញ្ញាតពីព្រះរាជអាជ្ញា បើទោះបីជាមានការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ។ ការឆែកឆេរ ត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ ។ សាក្សីត្រូវតែចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលសាក្សីនោះមិនអាចជា នគរបាល ឬក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះទេ[45]ដែលវាមានភាពខុសប្លែកពីការឆែកឆេរ ចំពោះករណីបទល្មើសមិនជាក់ស្តែង ដែលមន្ត្រីនគរបាលយុត្តិធម៌អាចឆែកឆេរបាន លុះត្រាតែមានការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ។[46]

បន្ទាប់ពីបានធ្វើការឆែកឆេររួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលនៅក្នុងនោះត្រូវមានចុះដូចខាងក្រោម ៖

- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ពីថ្ងៃ និងម៉ោងនៃការអនុញ្ញាត

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៩១ កថាខណ្ឌទី ៣។

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៩១ កថាខណ្ឌទី ១ និង ២។

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១១៣។

– និងអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ ។[47]

**១២.៣ សមាសភាពចូលរួមឆែកឆេរ**

ការចុះទៅឆែកឆេរ ដែលដឹកនាំដោយព្រះរាជអាជ្ញា តែងតែមានការចូលរួមពីអាជ្ញាធរដែលមានជាប់ពាក់ព័ន្ធ ដែលជាទូទៅមានដូចជា ៖

– អគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

– អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន

– នាយការិយាល័យផ្សព្វផ្សាយអប់រំ

– អធិការរងនគរបាល

– ចៅសង្កាត់

– នាយប៉ុស្តិ៍នគរបាល

– មេភូមិ[48]

**គ/. ការបិទស្លាកបោះត្រាលើវត្ថុតាង**

មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាង ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងទាំងនោះ ។ ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការចាប់យក ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់ ។ កំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់ ។[49]

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៩១ កថាខណ្ឌទី ៥។

[48] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ១៥។

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៩២។

**ឃ/. ការស្តាប់ចម្លើយ**

មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្តាប់ចម្លើយជនទាំងនោះ។ ការស្តាប់ចម្លើយនីមួយៗ ត្រូវតែមានកំណត់ហេតុ ហើយកំណត់ហេតុត្រូវដកស្រង់តាមដោយត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ ។ ក្នុងករណីចាំចាច់ មន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែដែលស្បថថា និយាយតែការពិតស្របតាមជំនឿសាសនារបស់ខ្លួន ។ អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នាបានទេ ។ ទំព័រនីមួយៗនៃកំណត់ហេតុត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយបុគ្គលដែលបានឆ្លើយ ។ មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំឡេងខ្លាំងៗនូវខ្លឹមសារក្នុងកំណត់ហេតុ ។ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែបាន ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។[50]

**ង/. ការធ្វើតេស្ត និងការវេចខ្ចប់**

គ្រឿងញៀនដែលបានចាប់បាន ត្រូវតែធ្វើការវេចខ្ចប់ឲ្យបានត្រឹមត្រូវ ដើម្បីការពារកុំឲ្យមានការខូចខាតនូវទ្រង់ទ្រាយ និងសារធាតុរបស់វា ។ បន្ទាប់ពីវេចខ្ចប់រួច និងចាប់ផ្តើមឈានទៅរកការធ្វើតេស្ត ដើម្បីអាចកំណត់បានថា តើវាពិតជាគ្រឿងញៀនពិតប្រាកដមែនដែរ ឬទេ ?

**ង១.ការធ្វើតេស្តបឋម**

ដើម្បីដឹងថាវត្ថុតាងដែលបានចាប់យកជាគ្រឿងញៀនមែន ឬ អត់ គឺទាមទារឲ្យធ្វើការធ្វើតេស្តពីលទ្ធផលនៃគ្រឿងញៀន ហើយទើបអាចបន្តនីតិវិធីតាមផ្លូវច្បាប់បន្តទៀត ។ គ្រឿងញៀនដែលចាប់បាន ត្រូវធ្វើការត្រួតពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រ ដែលមានការចូលរួមដោយ ៖

- នាយកាវិយាល័យវិទ្យាសាស្ត្រ
- នាយកាវិយាល័យស្រាវជ្រាវប្រឆាំងគ្រឿងញៀន

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៩៣។

- នាយរងការិយាល័យស្រាវជ្រាវគ្រឿងញៀន
- ជំនួយការនានា

ដំណាក់កាលដំបូង ដើម្បីស្វែងរកតម្រុយពិរុទ្ធភាពនៃបទល្មើសដែលមានសារធាតុញៀន ឬអត់ គឺទាមទារឲ្យធ្វើការធ្វើតេស្តពណ៌សម្រាប់ជំហានដំបូងបំផុត នៅពេលដែលសមត្ថកិច្ចចាប់វត្ថុតាងដែលជាគ្រឿងញៀនបាន ។ ជាទូទៅវត្ថុតាងដែលចាប់បាន ត្រូវយកទៅធ្វើតេស្តនៅការិយាល័យកណ្តាលប្រឆាំងគ្រឿងញៀន ។[51] ចំពោះតេស្តពណ៌ ដែលមន្ត្រីអនុវត្តច្បាប់ប្រើសម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូងគឺ៖[52]

- ម៉ាគ្វី តេស្ត (Marquis Test)
- ស៊ីម៉ុន តេស្ត (Simon Test)
- ស្កុត តេស្ត (Scott Test)
- ហ្វាសប្លូ ប៊ីសាល់ តេស្ត (Fast Blue B Salt Test)
- ចិនការ តេស្ត (Chenkao Test)[53]

ការធ្វើតេស្តជំហានដំបូងមិនសូវជាស្មុគស្មាញ និងមិនចាំបាច់ចំណាយពេលវេលាយូរទេ ដោយការធ្វើតេស្តនេះអាចដឹងបានលទ្ធផលភ្លាមៗ ។ លទ្ធផលធ្វើតេស្តជំហានដំបូងលើសារធាតុសង្ស័យគ្រឿងញៀននឹងធ្វើការបញ្ជាក់ពីការិយាល័យនគរបាលប្រឆាំងគ្រឿងញៀនដោយបញ្ជាក់ពីប្រភេទនៃសារធាតុធ្វើតេស្ត និងធ្វើសេចក្តីសន្និដ្ឋានចំពោះផលវិជ្ជមាន ។ ឧទាហរណ៍៖ លទ្ធផលតេស្តជំហានដំបូងចំពោះថ្នាំមេតំហ្វេតាមីន (ប្រភេទសារធាតុធ្វើតេស្ត Marquis Test ដែលមានពណ៌

---

[51] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ១៦។

[52] ឧត្តមសេនីយឯក វេជ្ជ.មាស វីរិទ្ធ, *"ការយល់ដឹងពីលក្ខណៈបច្ចេកទេសទាក់ទងនឹងបទល្មើសគ្រឿងញៀន"*, ៩។

[53] ក្នុងចំណោមតេស្តខាងលើនេះ ភាគច្រើនគេឃើញមាន ម៉ាគ្វី តេស្ត (Marquis Test) និង ស៊ីម៉ុន តេស្ត (Simon Test) ដែលមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់ច្រើនជាងគេ

ឈាមជ្រូក លទ្ធផលវិជ្ជមាន គឺជាមេតំហ្វេតាមីន) ។[54] ហើយការដកសំណាកសម្រាប់ការធ្វើតេស្ត ជំហានដំបូងនេះ គេអាចធ្វើក្រោមរូបភាពដូចខាងក្រោម ៖

- សំណាកជាម្សៅ ៖ យកសំណាកយ៉ាងតិចបំផុតដាក់ក្នុងចានវិភាគ
- សំណាកជាគ្រាប់ ឬជាវត្ថុធាតុរឹង ឬជាដំរឹង ៖ ត្រូវកាត់វាជាដុំតូចៗ រួចកិនឲ្យម៉ត់ ហើយយកបរិមាណយ៉ាងតិចបំផុតដាក់ក្នុងចានវិភាគសម្រាប់ធ្វើតេស្តពណ៌ ។
- សំណាកជាថ្នាំគ្រាប់មានស្រោបពីក្រៅ ៖ ត្រូវដកសំបកគ្រាប់ថ្នាំថ្មមៗ រួចយកម្សៅនៅខាងក្នុងនោះយ៉ាងតិចបំផុតដាក់ក្នុងចានវិភាគសម្រាប់ធ្វើតេស្តពណ៌ ។
- សំណាកជារុក្ខជាតិ ៖ ត្រូវកាត់យកតែចំណែកតូច រួចកិន ឬបុកឲ្យម៉ត់ ហើយយកកំទេចរុក្ខជាតិនោះយ៉ាងតិចបំផុតដាក់ក្នុងចានវិភាគសម្រាប់ធ្វើតេស្តពណ៌ ។
- សំណាកជាបារី ៖ ត្រូវហែកក្រដាសស្រោបបារីនោះចេញ រួចយកស្លឹកថ្នាំនោះបន្តិចទៅកិន ឬបុកឲ្យម៉ត់ ហើយយកកំទេចនោះយ៉ាងតិចបំផុតដាក់ក្នុងចានវិភាគសម្រាប់ធ្វើតេស្តពណ៌ ។

### ១២. ការវេចខ្ចប់

វត្ថុតាងដែលចាប់បានមិនមែនអាចយកទៅទុកដាក់ ឬ ទុកចោលបាននោះទេ វាទាមទារឲ្យមានការរៀបចំទុកដាក់ឲ្យបានត្រឹមត្រូវដើម្បីរក្សាទុកនូវគុណភាព និងរក្សាការដកហូតវត្ថុតាងដែលជាសារធាតុញៀនទាំងនោះទុករហូតដល់ដំណាក់កាលចៅក្រមស៊ើបសួរបន្តទៀត ។ ជាការពិតណាស់ វត្ថុតាងដែលសង្ស័យថាជាគ្រឿងញៀន ត្រូវរក្សាទុកក្នុងកញ្ចប់ ប្រអប់ ឬហឹប និងបិទស្លាកបោះត្រា ។ កញ្ចប់ ប្រអប់ ឬហឹប ដែលមានបិទស្លាកបោះត្រា ត្រូវធ្វើយ៉ាងណាការពារឲ្យបានដើម្បីកុំឲ្យមានការលួចដកហូតយកវត្ថុតាងក្នុងនោះ ។ កញ្ចប់ ប្រអប់ ឬហឹប ដែលមានបិទស្លាកបោះត្រានីមួយៗត្រូវដាក់លេខរៀង និងមានសរសេរពីលើសំបកកញ្ចប់ ប្រអប់ ឬហឹប ឬសរសេរលើស្លាកបោះត្រារាយសេចក្តីអំពីប្រភេទ និងទម្ងន់នៃវត្ថុដែលសង្ស័យថាជាគ្រឿងញៀនព្រមទាំងចំនួនកញ្ចប់ដែលវេចខ្ចប់វត្ថុតាងនោះ ។ គ្រឿងញៀនដែលចាប់បាន ត្រូវបានវេចខ្ចប់ទៅតាមប្រភេទរបស់វា គឺមានន័យថា គ្រឿងញៀនប្រភេទគ្រាប់ និងម្សៅ ត្រូវធ្វើការវេចខ្ចប់ដាច់ដោយឡែកពីគ្នា ។ ការវេចខ្ចប់

[54] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ១៧។

គ្រឿងញៀនទាំងនេះ ត្រូវដាក់ក្នុងស្រោមសំបុត្រឲ្យបានត្រឹមត្រូវ និងមានចុះហត្ថលេខារបស់គណៈកម្មការដែលបានចូលរួម និងជៀសវាងការបើកផ្តេសផ្តាស ដែលនាំឲ្យប៉ះពាល់ដល់វត្ថុតាងសម្រាប់ដំណើរការស៊ើបអង្កេតបន្តទៅមុខទៀត ។ នៅពេលដែលធ្វើការវេចខ្ចប់រួចរាល់ហើយ មន្ត្រីនគរបាលត្រូវធ្វើកំណត់ហេតុស្តីពីការធ្វើតេស្ត និងវេចខ្ចប់ ដោយត្រូវបញ្ជាក់ពី ៖

– កាលបរិច្ឆេទនៃការដកហូត

– អត្តសញ្ញាណរបស់ជនល្មើស[55]

– ប្រភេទ ទម្ងន់នៃវត្ថុដែលសង្ស័យថាជាគ្រឿងញៀន

– វិធីថ្លឹងគ្រឿងញៀនដែលបានធ្វើ

– បញ្ជាក់ពីការធ្វើតេស្ត និងលទ្ធផលនៃការធ្វើតេស្ត

កំណត់ហេតុ និងកំណត់សរសេរនៅលើកញ្ចប់ ប្រអប់ ឬហឹបនីមួយៗ ត្រូវចុះអត្តសញ្ញាណ និងហត្ថលេខា របស់បុគ្គលដែលបានចូលរួមរៀបចំធ្វើកញ្ចប់ ប្រអប់ ឬហឹបទាំងអស់នោះ ។ ចំពោះការថែរក្សានូវកញ្ចប់[56] ប្រអប់ ឬហឹប នៅកន្លែងណាមួយ ការផ្លាស់ប្តូរទីកន្លែងនៃការរក្សាទុក[57] ឬការប្រែប្រួលសភាពដើមនៃកញ្ចប់ ប្រអប់ ឬហឹប ត្រូវធ្វើកំណត់ហេតុ ។[58]

**ច/. ការឃាត់ខ្លួន**[59]

---

[55] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ១៩។

[56] អង្គភាពដែលទទួលបន្ទុករក្សាវត្ថុរឹបអូស គឺ លេខាធិការដ្ឋាន ការិយាល័យក្រឡាបញ្ជីសាលាដំបូង (អំណោយស្ថានទូតបារាំង, *នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល* (២០០៩), ១៨៣។

[57] រដ្ឋបាលតុលាការ ជាអ្នកទទួលទុកគ្រឿងញៀន និងរក្សាទុកឲ្យបានត្រឹមត្រូវបន្ទាប់ពីបានធ្វើការដកយកទៅធ្វើតេស្តជាបឋមរួចហើយ។

[58] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៨១។

[59] ការឃាត់ខ្លួន គឺជាវិធានការដកហូតសេរីភាពមួយដែលសម្រេចដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើប្រតិបត្តិការក្នុងក្របខ័ណ្ឌបេសកកម្មនគរបាលយុត្តិធម៌ ។ វិធានការនេះ ត្រូវបានអនុវត្តក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរយុត្តាធិការ និងទៅតាមទម្រង់ការដ៏រឹងមួយដើម្បីគោរពសេរីភាពបុគ្គល។ (អំណោយស្ថានទូតបារាំង, *នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល* (២០០៩), ១១៨។

### ច១. លក្ខខណ្ឌនៃការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលមានការសង្ស័យថា ជាប់ពាក់ព័ន្ធនឹងបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀននេះបាន ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីអង្គហេតុនេះបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ ៖

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន
- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។

យើងត្រូវពិនិត្យមើលថា ការឃាត់ខ្លួនត្រូវគោរពលើលក្ខខណ្ឌ២ ចំពោះការឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស ពេលនោះការឃាត់ខ្លួនត្រូវបានការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ។ ប៉ុន្តែចំពោះបុគ្គលមួយចំនួនដែលមន្ត្រីនគរបាលចង់បានព័ត៌មានពីគាត់ ដែលជួនកាលគាត់មិនបានប្រព្រឹត្តបទល្មើសទេ តែគាត់អាចធ្វើសាក្សីដែលមន្ត្រីនគរបាលចង់បានក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រោះ *ទីមួយ* ៖ គាត់ប្រកែកមិនព្រមផ្តល់ព័ត៌មាន និង *ទីពីរ* ៖ មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា ។ ដូច្នេះ ទើបមន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលនោះបាន ។ នៅពេលដែលឃាត់ខ្លួនបុគ្គលនោះភ្លាមមន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាមដែរមានន័យថា មិនអាចឃាត់ខ្លួនគេដោយមិនរាយការណ៍ ឬជូនដំណឹងទៅព្រះរាជអាជ្ញានោះទេ ។[60] ប្រសិនបើបុគ្គលដែលត្រូវបានឃាត់ខ្លួនដែលទាក់ទងនឹងបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនជាអនីតិជន នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ ។[61]

### ច២. រយៈពេលនៃការឃាត់ខ្លួន

ទាក់ទងនឹងរយៈពេលនៃការឃាត់ខ្លួននេះ គឺមានថិរវេលាតែ ៤៨ (សែសិបប្រាំបី) ម៉ោងប៉ុណ្ណោះ ព្រោះនេះជាពេលវេលាដែលច្បាប់អនុញ្ញាត ។ ថិរវេលាត្រូវបានចាប់គិតពីម៉ោងដែលសាមី

[60] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៩៦ កថាខណ្ឌទី ១ និង ២។

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១០០។

ខ្លួនមកដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ។ ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឲ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលបានឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យាពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីឲ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ការពន្យាពេលនេះត្រូវសុំទៅព្រះរាជអាជ្ញា ដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព[62] មានន័យថា ព្រះរាជអាជ្ញាគាត់នឹងផ្ទៀងផ្ទាត់មើលថា តើការសុំពន្យាពេលរបស់មន្ត្រីនគរបាលយុត្តិធម៌មានមូលហេតុសមហេតុផលដែរ ឬទេ? មិនមែនចេះតែសុំពន្យាពេលចង់ទុកគេឲ្យនៅយូរនោះទេ សំខាន់ទាល់តែមន្ត្រីនគរបាលយុត្តិធម៌មានតម្រុយបញ្ជាក់ថា បុគ្គលនោះមានពិរុទ្ធភាពពាក់ព័ន្ធនឹងបទល្មើសផ្សេងៗបន្ថែមទៀតរបស់ខ្លួន ហើយការអនុញ្ញាតឲ្យពន្យាពេលឃាត់ខ្លួនត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រឹមត្រូវស្តីពីការសុំពន្យាពេលឃាត់ខ្លួននេះ ។ ការពន្យាពេលឃាត់ខ្លួននេះមិនអាចធ្វើឡើងលើសពី ២៤(ម្ភៃបួន)ម៉ោង បានទេ ។ លើសពីនេះទៅទៀត ការស្នើសុំពន្យាពេលឃាត់ខ្លួននេះ មិនអាចធ្វើបាននោះទេ ប្រសិនបើបុគ្គលដែលបានប្រព្រឹត្តបទល្មើសជាអនីតិជន ។[63]

## តារាងថិរវេលានៃការឃាត់ខ្លួនអនីតិជន

| **បទល្មើស** | **អាយុ** | **ថិរវេលាកំណត់** |
|---|---|---|
| **បទឧក្រិដ្ឋ** | ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ | ៣៦ (សាមសិបប្រាំមួយ) ម៉ោង |
| **បទមជ្ឈិម** | ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ | ២៤ (ម្ភៃបួន) ម៉ោង |
| **បទឧក្រិដ្ឋ** | ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ | ៤៨ (សែសិបប្រាំបី) ម៉ោង |
| **បទមជ្ឈិម** | ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ | ៣៦ (សាមសិបប្រាំមួយ) ម៉ោង |
| | ១៤ឆ្នាំ ចុះក្រោម | ពុំអាចត្រូវបានឃាត់ខ្លួនបានឡើយ |

[62] មូលកភាព ៖ ភាពត្រឹមត្រូវ ភាពប្រាកដប្រជា។

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៩៦ កថាខណ្ឌទី ៣ និង ៤។

**ច៣. ការធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួន**

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឲ្យបានដឹងអំពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួននេះ ។ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់ដល់សាមីខ្លួនឲ្យបានដឹងផងដែរអំពីសិទ្ធិដែលបានចែងនៅមាត្រា ៩៨ (ជំនួយមេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ ហើយធ្វើកំណត់ហេតុស្តីអំពីការឃាត់ខ្លួនជាបន្ទាន់ដោយមានចុះសេចក្តីដូចតទៅ ៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យឃាត់ខ្លួន
- អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន
- ការឲ្យដំណឹងអំពីសិទ្ធិដែលបានចែងក្នុងមាត្រា ៩៨ (ជំនួយរបស់មេធាវីក្នុងពេលឃាត់ខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ឈ្មោះអ្នកបកប្រែ។

កំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬ ផ្តិតស្រាមដៃដោយជនឃាត់ខ្លួនក្រោយពីបានអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអក្សរមន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឲ្យស្តាប់ ។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតស្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស ។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង ។[64]

**ឆ/. ការបញ្ជូនខ្លួន**

**ឆ១. ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន**

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៩៧។

ក្រោយពីធ្វើការស៊ើបអង្កេតចប់សព្វគ្រប់រួចរាល់ហើយ ឬនៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួនបុគ្គលដែលត្រូវឃាត់ខ្លួនហើយនោះ ត្រូវបញ្ជូនជនដែលត្រូវបានឃាត់ខ្លួនទៅព្រះរាជអាជ្ញា ហើយបើគាត់មើលឃើញថាវាមិនធ្ងន់ធ្ងរទេ ព្រះរាជអាជ្ញាអាចមិនបញ្ជូនខ្លួនបុគ្គលនោះទៅឲ្យចៅក្រមស៊ើបសួរទៀតទេ គាត់អាចបន្តនីតិវិធីរបស់គាត់ ដោយដោះលែងឲ្យបុគ្គលនោះត្រលប់មកផ្ទះដើម្បីមានសេរីភាពដូចដើមឡើងវិញ ។ សេចក្តីសម្រេចនេះ ធ្វើឡើងដោយព្រះរាជអាជ្ញាមានន័យថាអាចសម្រេចបញ្ជូនទៅចៅក្រមស៊ើបសួរ ឬដោះលែងឲ្យមានសេរីភាពវិញ ។[65] មួយវិញទៀតមន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញាផងដែរមានន័យថា កាលណាមានការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនទៅព្រះរាជអាជ្ញា នោះកំណត់ហេតុ និងវត្ថុតាងទាំងអស់ក៏ត្រូវបញ្ជូនទៅជាមួយនឹងការបញ្ជូនខ្លួនបុគ្គលនោះផងដែរ ។[66]

#### ឆ២. រយៈពេលនៃការបញ្ជូនខ្លួន

កាលណាបុគ្គលដែលត្រូវឃាត់ខ្លួនត្រូវបញ្ជូនខ្លួនទៅកាន់ព្រះរាជអាជ្ញា នោះបុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា ។ ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូនដូចជា ឡានបែកកង់ ឡានអស់សាំង ឬចម្ងាយផ្លូវនៃការដឹកជញ្ជូននោះរយៈពេលបន្ថែមអាចផ្តល់ឲ្យដោយព្រះរាជអាជ្ញាបាន។ នៅក្នុងគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះក្នុងកំណត់ហេតុនូវមូលហេតុនៃការយឺតយ៉ាវ ហើយត្រូវប្រគល់ជូនព្រះរាជអាជ្ញា ។[67]

### កថាខណ្ឌទី២ ការស៊ើបអង្កេតបឋម

ជាការពិតណាស់ បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មិនមែនសុទ្ធតែជាបទល្មើសជាក់ស្តែងទាំងអស់នោះទេ ព្រោះថាក្នុងករណីមួយចំនួនបទល្មើសនេះត្រូវបានចុះបង្ក្រាបដោយការរាយការណ៍ពីប្រជាពលរដ្ឋតាមមូលដ្ឋាន ដែលពួកគេប្រទះឃើញមានការដោះដូរលក់

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១០៣។

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១០៧។

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១០៥។

គ្រឿងញៀនជាដើម ។ ដូច្នេះ ក្នុងករណីនេះអាជ្ញាធរមានសមត្ថកិច្ច ត្រូវអនុវត្តការស៊ើបអង្កេតតាមរយៈនីតិវិធីស៊ើបអង្កេតបឋម ។ នៅក្នុងនីតិវិធីស៊ើបអង្កេតបឋម យើងសង្កេតឃើញថាមិនសូវជាខុសគ្នាប៉ុន្មាននោះទេទាក់ទងទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែង ព្រោះតាមរយៈមាត្រា ១១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជាក់យ៉ាងច្បាស់ថា បទបញ្ញត្តិនៃមាត្រាមួយចំនួនដែលមានចែងនៅក្នុងការស៊ើបអង្កេតជាក់ស្តែង ត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេតបឋមដែរ ។ ចំពោះមាត្រាទាំងនោះរួមមាន ៖

- មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)
- មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)
- មាត្រា ១០៥ (ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា ១០៨ ( និទ្ទេសដែលត្រូវចុះក្នុងកំណត់ហេតុ)

សូមបញ្ជាក់ថា ដោយសារតែវិធានទាំងនេះ យើងបានបកស្រាយយ៉ាងលំអិតរួចមកហើយនៅក្នុងការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែង ដូច្នេះដើម្បីមានភាពច្បាស់លាស់ សូមមេត្តាអាននូវចំណុចដែលពាក់ព័ន្ធនឹងមាត្រាទាំង៥នេះ ដូចមាននៅក្នុងការបកស្រាយខាងលើ ។

### ក/. ការឆែកឆេរ

ការឆែកឆេរនៅក្នុងការស៊ើបអង្កេតបឋម ថ្វីត្បិតតែមានចំនុចមួយចំនួនដូចគ្នាទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែង តែផ្ទុយទៅវិញ ក៏នូវមានចំនុចមួយចំនួនមិនដូចគ្នាដែរទាក់ទងនឹងបែបបទដែលត្រូវគោរព ។ ចំនុចដែលមន្ត្រីនគរបាលយុត្តិធម៌ ត្រូវគោរពគឺមានដូចតទៅ ៖

កាលណាការស៊ើបអង្កេតបឋមនោះទាក់ទងនឹងបទឧក្រិដ្ឋ ឬ បទបជ្ជិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង ។ មន្ត្រីនគរបាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង តែប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះត្រូវសរសេរឲ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរហើយយល់ព្រមឲ្យឆែកឆេរ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីការអនុញ្ញាតឲ្យ

ឆែកឆេរតាមការសុំរបស់ព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញា ត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនោះ ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី០២នាក់ ។ សាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា ហើយសាក្សីមិនអាចជានគរបាល ឬ ជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។ ការឆែកឆេរមិនអាចផ្តើមមុនម៉ោង៦(ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨(ដប់ប្រាំបី) ល្ងាចបានឡើយ ។[68]

## ខ/. ការបិទស្លាកលើវត្ថុតាង

ចំពោះការបិទស្លាកលើវត្ថុតាង ក្នុងការស៊ើបអង្កេតបឋម គឺមានលក្ខណៈដូចគ្នាទៅនឹងការបិទស្លាកលើវត្ថុតាង ដែលមានក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង ដូចដែលធ្វើការបកស្រាយខាងលើ ។

## គ/. ការបញ្ជាឲ្យចូលខ្លួន

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយរបស់បុគ្គលគ្រប់រូបដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬ ដែលអាចផ្តល់ពត៌មានស្តីពីរឿងហេតុ ។ បុគ្គលដែលកោះហៅ ត្រូវតែចូលមកបង្ហាញខ្លួន ។ ក្នុងករណីដែលរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឲ្យចូលខ្លួន ។ បញ្ជាឲ្យចូលខ្លួននេះត្រូវមានអត្តសញ្ញាណបុគ្គលពាក់ព័ន្ធ កាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។ បញ្ជាឲ្យចូលខ្លួននេះ អនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ ប្រើប្រាស់កងកម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួនបាន ។[69]

## ឃ/. ការឃាត់ខ្លួន និងបញ្ជូនខ្លួន

យោងតាមមាត្រា ១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ ឬ បទមជ្ឈិម នោះបទប្បញ្ញត្តិនៃជំពូកទី៣ ស្តីពីការឃាត់ខ្លួន និងជំពូកទី ៤ ស្តីពីការបញ្ជូនខ្លួននៃមាតិកាទី ២ ស្តីពីការស៊ើបអង្កេតករណីជាក់ស្តែងត្រូវយកមកអនុវត្តដូចគ្នា ។[70]

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១១៣។

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១១៤។

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១១៦។

# ជំពូកទី៣
# ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលអយ្យការ

## ផ្នែកទី១ ការចោទប្រកាន់របស់ព្រះរាជអាជ្ញា

ក្រោយពីធ្វើការស៊ើបអង្កេតចប់ ព្រះរាជអាជ្ញាមានតួនាទីចំបង ដែលត្រូវសម្រេចចិត្តដោយយោងទៅលើភាពជាក់ស្តែង និងស្ថានភាពភស្តុតាងដែលប្រមូលបាន ។ នៅក្នុងដំណាក់កាលនេះ ព្រះរាជអាជ្ញាអាចធ្វើចំណាត់ការសំណុំរឿងទៅតាមជម្រើសពីរយ៉ាងគឺ ៖

- **ជម្រើសនៃការចោទប្រកាន់**[71] ៖ យោងទៅតាមមាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ព្រះរាជអាជ្ញា អាចធ្វើការចោទប្រកាន់បាន ៣ វិធីគឺ៖ (១)ការបើកការស៊ើបសួរ, (២)ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និង (៣)ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។
- **ជម្រើសមិនធ្វើការចោទប្រកាន់**[72] ៖ សំដែងចេញតាមរយៈសេចក្តីសម្រេចតម្កល់រឿងឥតចាត់ការ ផ្អែកលើការវាយតម្លៃរបស់ព្រះរាជអាជ្ញា ។ មូលហេតុនៃការតម្កល់រឿងឥតចាត់ការ នេះមកពី (១)អង្គហេតុនៃបទល្មើសមិនបង្កើតជាបទល្មើសព្រហ្មទណ្ឌ[73], (២)បណ្តឹងអាជ្ញារលត់[74] និង (៣) គោលរណ៍កាលានុវត្តភាពនៃចោទប្រកាន់នៃបណ្តឹងអាជ្ញា[75] ។

នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ដំណាក់កាលចោទប្រកាន់គឺជាដំណាក់កាលមួយដែលអនុវត្តដោយព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញា គឺជាម្ចាស់បណ្តឹងអាជ្ញានៅក្នុងការធ្វើបណ្តឹង និងចោទប្រកាន់ជនល្មើស ។ បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាព នៃបទល្មើសបង្ហាញឲ្យឃើញពី

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៤០។

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៤០។

[73] នៅពេលដែលទទួលបណ្តឹង ឬព្រះរាជអាជ្ញាបញ្ជាឲ្យធ្វើការស៊ើបអង្កេតបឋម ហើយគាត់ពិនិត្យឃើញថា ពុំមានវត្តមានអត្តសញ្ញាណនៃចារី, អវត្តមាននៃបទល្មើស, ពុំមានបន្ទុកគ្រប់គ្រាន់ដើម្បីបង្ហាញពីពិរុទ្ធភាពរបស់ចារី ហើយការស្រាវជ្រាវបន្ថែមដែលអាចនឹងត្រូវធ្វើហាក់ដូចជា គ្មានប្រយោជន៍ និងគ្មានប្រសិទ្ធិភាព ឬក៏អំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ តែជាបទល្មើសផ្នែករដ្ឋប្បវេណី, ពាណិជ្ជកម្ម, ការងារជាអាទិ៍ ។

[74] មរណភាពនៃជនល្មើស, ការផុតអាជ្ញាយុកាល, ការលើកលែងទោសជាទូទៅ, និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ, អាជ្ញាអស់ជំនុំ។

[75] ដោយមានរឿងមួយចំនួនបង្កើតជាបទល្មើស តែព្រះរាជអាជ្ញាមិនចោទប្រកាន់ដោយយោងតាមស្ថានភាព និងកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ដែលកាលៈទេសៈនោះរួមមាន បទល្មើសនោះជាប្រភេទបទល្មើសតូចតាច, ជនល្មើសប្រព្រឹត្តលើកទីមួយ, ជនរងគ្រោះមិនធ្វើការទាមទារ និង ជនល្មើសធ្វើការជួសជុលព្យសនកម្មរួចរាល់ ។

ពិរុទ្ធភាពនៃបទល្មើស និងផ្តន្ទាទោសតាមច្បាប់កំណត់ដើម្បីជាប្រយោជន៍រួម ។ បណ្តឹងអាជ្ញាអាច អនុវត្តលើគ្រប់បុគ្គលទាំងអស់ ទាំងរូបវន្តបុគ្គល នីតិបុគ្គល ។[76]

### កថាខណ្ឌទី១ ការបើកការស៊ើបសួរ

ព្រះរាជអាជ្ញា ត្រូវធ្វើការបើកការស៊ើបសួរ កាលណាមានលក្ខខណ្ឌដូចខាងក្រោម ៖

- ជាបទឧក្រិដ្ឋ[77] ៖ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវជា (១) ទោសដាក់ពន្ធនាគារអស់មួយជីវិត, (២) ទោសដាក់ពន្ធនាគារមានរយៈពេល លើសពី ៥(ប្រាំ)ឆ្នាំ និងក្រោម ឬស្មើនឹង ៣០(សាមសិប)ឆ្នាំ ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។[78]
- បទមជ្ឈិម[79]៖ នៅក្នុងករណីអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះមាន រយៈពេលលើសពី ៦(ប្រាំមួយ)ថ្ងៃ និងក្រោម ឬស្មើនឹង ៥(ប្រាំ)ឆ្នាំ ។ ទោសដាក់ ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។[80]

### កថាខណ្ឌទី២ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ព្រះរាជអាជ្ញា អាចបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ កាលណាបទល្មើសនោះជាបទមជ្ឈិម[81] ដោយធ្វើដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឲ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅ មុខតុលាការជាន់ដំបូង ។[82]

### កថាខណ្ឌទី៣ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញា អាចបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣។

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៤៥។

[78] ក្រមព្រហ្មទណ្ឌ, មាត្រា ៤៦។

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៤៥។

[80] ក្រមព្រហ្មទណ្ឌ, មាត្រា ៤៧។

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៤៥។

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៤៦។

ដំបូងប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅ ៖[83]

- បទល្មើសជាបទល្មើសជាក់ស្តែង[84]
- បទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១(មួយ)ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ)ឆ្នាំ
- ជនជាប់ចោទជានីតិជន
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

## ផ្នែកទី២ ការបើកការស៊ើបសួរ

ជាការពិតណាស់ ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់បានតាមបីវិធីដែលបានរៀបរាប់មកខាងលើកាលបើលក្ខខណ្ឌត្រូវបានបំពេញ ។ ប៉ុន្តែ ចំពោះបទជួញដូរដោយខុសច្បាប់នូវសារធាតុនេះ ព្រះរាជអាជ្ញាមិនអាចចោទប្រកាន់តាមការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ឬ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមបានទេ ព្រោះថាលក្ខខណ្ឌនៃវិធីទាំងពីរនេះមិនត្រូវបានបំពេញ ។ ដូច្នេះ បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ត្រូវបានចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ ។

### កថាខណ្ឌទី១ លក្ខខណ្ឌនៃការបើកការស៊ើបសួរ

យោងទៅតាមមាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មានតែបទល្មើសដែលជាបទឧក្រិដ្ឋ និងមជ្ឈិម ទេដែលអាចបើកការស៊ើបសួរបាន ។ បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាបទល្មើសស្មុគស្មាញ និងជាបទឧក្រិទ្ធ/មជ្ឈិម ដែលតម្រូវអោយព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ ។ ការស៊ើបសួរត្រូវបានបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលប្តឹងទៅចៅក្រមស៊ើបសួរ ដើម្បីបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ។[85]

### កថាខណ្ឌទី២ នីតិវិធីនៃការបើកការស៊ើបសួរ

នៅក្នុងរឿងក្តីជួញដូរគ្រឿងញៀន ព្រះរាជអាជ្ញាទទួលសំណុំរឿងតាមរយៈការបញ្ជូនសំណុំ

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៤៧។

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៨៦ និងមាត្រា ៨៨។

[85] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៤៤ និងមាត្រា ៤៥។

រឿងពីមន្ត្រីនគរបាលយុត្តិធម៌ ។ ដូចនេះ មុននឹងសម្រេចបើកការស៊ើបសួរ ព្រះរាជអាជ្ញាធ្វើការវាយតម្លៃ និងវិនិច្ឆ័យលើសំណុំរឿងតាមប្រភពនៃការបញ្ជូននោះ ។

មន្ត្រីនគរបាលយុត្តិធម៌ បើកការស៊ើបអង្កេតបឋមចំពោះបណ្តឹងដែលខ្លួនបានទទួល ឬនៅពេលដឹងពីបទឧក្រិដ្ឋ មជ្ឈិម ណាមួយ រួចបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។ ចំពោះករណីបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់ខ្លួន និងឃាត់ខ្លួនជនសង្ស័យរួចបញ្ជូនខ្លួនជនសង្ស័យទៅចំពោះមុខព្រះរាជអាជ្ញា ។ ដូចនេះ នីតិវិធីក្នុងការធ្វើចំណាត់ការចំពោះសំណុំរឿងដែលបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើឡើងតាមករណីដូចខាងក្រោម ៖

- **ករណីសំណុំរឿងគ្មានខ្លួនជនសង្ស័យ (ក្រៅឃុំ)**

សំណុំរឿងគ្មានខ្លួនជនសង្ស័យ សំដៅដល់សំណុំរឿងដែលបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយជនសង្ស័យពុំត្រូវបានឃាត់ខ្លួន ហើយបញ្ជូនមកព្រះរាជអាជ្ញានោះទេ ។ នៅពេលដែលព្រះរាជអាជ្ញាទទួលបានសំណុំរឿង ព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងអង្គហេតុ ដោយពិនិត្យមើលភស្តុតាងដែលមានក្នុងសំណុំរឿង ដូចជា ទម្ងន់ ប្រភេទ នៃក្រាមសថ្លាដែលមានតម្រុយថាជាគ្រឿងញៀនខុសច្បាប់ជាដើម របាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ និងកោះហៅជនសង្ស័យ សាក្សី ដើម្បីសួរ និងស្តាប់ចម្លើយ ។ បន្ទាប់មក ប្រសិនជាពិនិត្យឃើញថា ជនល្មើសពិតជាបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន នោះព្រះរាជអាជ្ញានឹងត្រូវធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅចៅក្រមស៊ើបសួរ ដោយធ្វើការកំណត់ឈ្មោះជនត្រូវចោទម្នាក់ ឬច្រើននាក់ ឬអញ្ញាតជន ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ ។

- **ករណីសំណុំរឿងមានខ្លួនជនសង្ស័យ (ក្នុងឃុំ)**

សំណុំរឿងមានខ្លួន សំដៅដល់សំណុំរឿងដែលជនសង្ស័យត្រូវបានចាប់ និងឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ ហើយត្រូវបាននាំខ្លួនមកបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា បន្ទាប់មកព្រះរាជអាជ្ញា ធ្វើការសួរចម្លើយ និងពិនិត្យសំណុំរឿង ដោយពិនិត្យទៅលើអង្គហេតុ ឯកសារ និង ភស្តុតាងដែលមានក្នុងសំណុំរឿង របាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ ។ បន្ទាប់មក ប្រសិនជាពិនិត្យឃើញថា ជនល្មើសពិតជាបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន នោះព្រះរាជអាជ្ញានឹងត្រូវធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ ។

**កថាខណ្ឌទី៣ ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[86] ត្រូវធ្វើតាមទម្រង់ការដែលមានលក្ខណ:ដាច់ខាត ត្រូវតែគោរពដូចខាងក្រោមនេះ បើពុំដូច្នេះទេ ត្រូវចាត់ទុកជាមោឃ: ៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន
- ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខារបស់ព្រះរាជអាជ្ញា ។[87]

[86] ភាគច្រើនគេហៅថា RI។

[87] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៨៤។

# ជំពូកទី៤

# ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលចៅក្រមស៊ើបសួរ

## ផ្នែកទី១ ដំណើរការនៃការបើកការស៊ើបសួរ

ការស៊ើបសួរ ត្រូវធ្វើឡើងជាការសម្ងាត់ មានន័យថា បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេស ចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងមន្ត្រីផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈរបស់ខ្លួន ។[88] ការបំពានលើកការសម្ងាត់ខាងលើ គឺជាបទប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) ។[89]

### កថាខណ្ឌទី១ ការបើកការស៊ើបសួរ

ការស៊ើបសួរត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ មិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានឡើយ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ ។[90] ជាការពិតណាស់ នៅពេលដែលចៅក្រមស៊ើបសួរទទួលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញាហើយ ចៅក្រមស៊ើបសួរ ត្រូវស៊ើបសួរតែអំពីអង្គហេតុដែលមាននៅក្នុងដីកានោះតែប៉ុណ្ណោះ ក្នុងករណីដែលមានការលេចនូវអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌ នៅពេលស៊ើបសួរចៅក្រមស៊ើបសួរត្រូវជូនជាពត៌មានអំពីអង្គហេតុនេះទៅព្រះរាអាជ្ញា ។ ព្រះរាជអាជ្ញា អាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ ។ ប៉ុន្តែ ចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថាន

---

[88] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១២១។

[89] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣១៤។

[90] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១២៤។

ទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូង ។[91]

## កថាខណ្ឌទី២ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

### ក/. ការដាក់ឲ្យស្ថិតក្រោមការពិនិត្យ

នៅពេលដែលសំណុំរឿងត្រូវបានបញ្ជូនមកចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវតែដាក់ឲ្យស្ថិតក្រោមការពិនិត្យនូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ ។ ចៅក្រមស៊ើបសួរ មានអំណាចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើសទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ ។ ចៅក្រមស៊ើបសួរ អាចដាក់បុគ្គលនោះឲ្យស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈ ជាចារី ជាអ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត ។[92]

នៅពេលជនត្រូវចោទចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណជនត្រូវចោទ ដោយធ្វើការបញ្ជាក់នូវឈ្មោះ ភេទ អាយុ មុខរបរ ទីកន្លែងកំណើត ទីលំនៅបច្ចុប្បន្ន ឈ្មោះឪពុកម្តាយ ជាដើម ដើម្បីជៀសវាងការភាន់ច្រឡំណាមួយកើតឡើង ។ បន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់និងបញ្ជាក់អត្តសញ្ញាណជនត្រូវចោទត្រឹមត្រូវរួចរាល់ហើយ ចៅក្រមស៊ើបសួរត្រូវប្រាប់ឲ្យជនត្រូវចោទបានដឹងនូវរឿងរ៉ាវដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលបានចោទប្រកាន់មកលើខ្លួន ។ ចៅក្រមស៊ើបសួរ ត្រូវប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី ។ និទ្ទេសស្តីពីការប្រាប់នេះ ត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង ។ ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម ចៅក្រមស៊ើបសួរ ប្រាប់ជនត្រូវចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ ជនត្រូវចោទ ជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច ។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិកៈ ។[93] ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរត្រូវហៅ

---

[91] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១២៥។

[92] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១២៦។

[93] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៤៣។

រកអ្នកបកប្រែ ។ អ្នកបកប្រែត្រូវស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថា ខ្លួននឹងជួយដល់តុលាការ និងបកប្រែឲ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ ។ ក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ឬសាក្សីទេ ។[94] នៅក្នុងកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង ត្រូវតែចុះសេចក្តីដូចខាងក្រោម ៖

- ឈ្មោះរបស់ចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
- ប្រភេទនៃបទល្មើស ដែលចង្អុលប្រាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
- កាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ

ទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវតែចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី ។ កំណត់ហេតុមិនត្រូវឲ្យមានចន្លោះបន្ទាត់ទេ ។ ការឆូតលុប ឬ ការយោងត្រូវតែបញ្ជាក់ដោយហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី នៅរឹមទំព័រ ។[95] ទំព័រនីមួយៗ នៃកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនលើកដំបូង ត្រូវចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ក្រឡាបញ្ជី និងសាមីខ្លួននៅរឹមទំព័រ ។[96]

### ខ/. ការសួរចម្លើយជនត្រូវចោទ

#### ខ.១. ការពិភាក្សាដេញដោលចំពោះមុខ

ការពិភាក្សាដេញដោល ត្រូវបានយកមកអនុវត្តក្នុងករណីសួរចម្លើយតទល់នឹងជនត្រូវចោទ

[94] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៤៥។

[95] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៤០។

[96] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៤១។

ដោយការសួរតទល់នេះតម្រូវអោយមានកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ ដែលទំព័រនីមួយៗ នៃកំណត់ហេតុត្រូវចុះហត្ថលេខាដោយគ្រប់បុគ្គលទាំងអស់ដែលតទល់គ្នា និងជាយថាហេតុដោយអ្នកបកប្រែ ។ [97] ឧទាហរណ៍៖ ហត្ថលេខារបស់ចៅក្រមស៊ើបសួរ ក្រឡាបញ្ជីជនត្រូវចោទ អាណាព្យាបាលជនត្រូវចោទ ជាដើម ។ មុននឹងចុះហត្ថលេខា ជនត្រូវចោទត្រូវអានឡើងវិញនូវកំណត់ហេតុនេះ ប្រសិនបើជនត្រូវចោទមិនចេះអានទេ ក្រឡាបញ្ជីត្រូវអានកំណត់ហេតុនេះដោយសំឡេងខ្លាំងៗ ។ ក្នុងករណីជនត្រូវចោទជាជនបរទេស មិនចេះអានអក្សរខ្មែរ អ្នកបកប្រែត្រូវធ្វើការបកប្រែអន្ថន័យនៃកំណត់ហេតុនោះអោយជនត្រូវចោទស្តាប់ ។ លើសពីនេះទៅទៀត ប្រសិន បើជនត្រូវចោទមិនព្រមចុះហត្ថលេខាលើកំណត់ហេតុទេ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសនៅលើកំណត់ហេតុនោះ ។ [98]

### ខ.២ ការសួរចម្លើយជនត្រូវចោទ

ការសួរចម្លើយជនត្រូវចោទ ត្រូវតែមានកំណត់ហេតុស្តីពីការសួរចម្លើយ ដែលកំណត់ហេតុនេះត្រូវស្រង់យ៉ាងត្រឹមត្រូវនូវសំណួរ ចម្លើយ និងចម្លើយដែលឆ្លើយដោយឯកឯង ហើយទំព័រនីមួយៗនៃកំណត់ហេតុត្រូវចុះហត្ថលេខាដោយជនត្រូវចោទ និងជាយថាហេតុដោយអ្នកបកប្រែ ។ មុននឹងចុះហត្ថលេខា ជនត្រូវចោទត្រូវអានឡើងវិញនូវកំណត់ហេតុនេះ ប្រសិនបើជនត្រូវចោទមិនចេះអានទេ ក្រឡាបញ្ជីត្រូវអានកំណត់ហេតុនេះដោយសំឡេងខ្លាំងៗ ។ ក្នុងករណីជនត្រូវចោទជាជនបរទេស មិនចេះអានអក្សរខ្មែរ អ្នកបកប្រែត្រូវធ្វើការបកប្រែអន្ថន័យនៃកំណត់ហេតុនោះអោយជនត្រូវចោទស្តាប់ ។ លើសពីនេះទៅទៀត ប្រសិនបើជនត្រូវចោទមិនព្រមចុះហត្ថលេខាលើកំណត់ហេតុទេ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសនៅលើកំណត់ហេតុនោះ ។[99]

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥(ប្រាំ) ថ្ងៃ មុនការសួរចម្លើយ ។ ក្នុងចិរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី ។ ជនត្រូវចោទ អាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ

[97] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៩៧។

[98] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៤២។

[99] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៤២។

ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានរបស់មេធាវីបាន ។ និទ្ទេសស្តីអំពីអវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ ។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយមិនបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន ។ ការបោះបង់នេះត្រូវចុះនៅក្នុងកំណត់ហេតុមួយផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ ។[100]

### គ/. ការស្តាប់ចម្លើយសាក្សី

ចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនេះអាចមានប្រយោជន៍នៅក្នុងការសំដែងឲ្យឃើញការពិត ដោយការស្តាប់ចម្លើយសាក្សីត្រូវធ្វើឲ្យដាច់ពីគ្នាពីជនត្រូវចោទ ។ បុគ្គលគ្រប់រូប ដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែមកបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង ចៅក្រមស៊ើបសួរអាចសុំឲ្យកម្លាំងសាធារណៈបង្ខំសាក្សីនេះឲ្យចូលមកបង្ហាញខ្លួនបាន តាមរយៈការចេញបញ្ជាឲ្យចូលមកបង្ហាញខ្លួន ដោយបញ្ជានេះត្រូវមានអត្តសញ្ញាណរបស់សាក្សីនោះ ហើយត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និង មានបោះត្រាផង ។[101]

### ឃ/. ការឃុំខ្លួន

ការឃុំខ្លួនបណ្តោះអាសន្ន[102] អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ) ឆ្នាំតែប៉ុណ្ណោះ[103] ដូចនេះតាមរយៈបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន[104] ជនត្រូវចោទនឹងត្រូវធ្វើការឃុំខ្លួនជាបណ្តោះអាសន្នបន្ទាប់ពីការសួរចម្លើយ ព្រោះថាបទល្មើសនេះមានរយៈពេលផ្តន្ទាទោសលើសពី ១(មួយ) ឆ្នាំ

[100] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៥៥។

[101] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៥៣។

[102] យោងតាមមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាគោលការណ៍ជនត្រូវចោទ ត្រូវតែមានសេរីភាព លើកលែងតែមានករណីពិសេសតែប៉ុណ្ណោះ។

[103] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២០៥។

[104] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ២០៥។

ចៅក្រមស៊ើបសួរធ្វើការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ននេះគឺដោយសារតែមានករណីចាំបាច់ដូចខាងក្រោម៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី
- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស ។[105]

### ឃ១. ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន

ជាការពិតណាស់ កាលណាចៅក្រមស៊ើបសួរសម្រេចថានឹងត្រូវឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នហើយ[106] ចៅក្រមស៊ើបសួរ ត្រូវចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន និងត្រូវឲ្យដំណឹងជនត្រូវចោទ ឬមេធាវីការពារសិទ្ធិជនត្រូវចោទ និងព្រះរាជអាជ្ញា[107] ស្តីពីការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ននោះ ។ ដីកាសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ត្រូវតែមានសំអាងហេតុស្តីពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ។

[105] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២០៥។

[106] ការសម្រេចអំពីការឃុំខ្លួនជនត្រូវជាបណ្តោះអាសន្ន អាចជាការគំនិតផ្តើមរបស់ចៅក្រមស៊ើបសួរ ឬព្រះរាជអាជ្ញា តាមរយៈដីកាសន្និដ្ឋានស្នើសុំឲ្យឃុំខ្លួនបណ្តោះអាសន្ន ។

[107] ការជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ ត្រូវបានធ្វើឡើងតាមរយៈដីកាបញ្ជូន ដែលដីកានេះមានសរសេរបញ្ជាក់ថា ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នក្នុងរយៈណាមួយកំណត់។

### ឃ២. ដីកាបង្គាប់ឲ្យឃុំខ្លួន

បន្ទាប់ពី ចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នហើយ ចៅក្រមស៊ើបសួរត្រូវចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន[108] ដើម្បីឲ្យមន្ត្រីពន្ធនាគារទទួលឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន និងត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។[109] ដីកាបង្គាប់ឲ្យឃុំខ្លួន ត្រូវចុះនិទ្ទេសដូចតទៅ៖

- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា
- កាលបរិច្ឆេទ ហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងមានបោះត្រា ។[110]

នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យឃុំខ្លួនហើយ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានអត្តសញ្ញាណក្នុងដីកាបង្គាប់ឲ្យឃុំខ្លួនរហូតទាល់តែបានទទួលការឲ្យដំណឹងអំពីការដោះលែងឲ្យមានសេរីភាពវិញ ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវរក្សាទុកដើមដីកាបង្គាប់ឲ្យឃុំខ្លួន ឬចុងដីកានោះដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ។[111]

### ឃ៣. រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

#### ឃ.៣.១. រយៈពេលនៃការឃុំខ្លួននីតិជន

បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន អាចជាបទឧក្រិដ្ឋ ឬមជ្ឈិម គឺអាស្រ័យទៅលើ

[108] យោងទៅតាមមាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ "ដីកាបង្គាប់ឲ្យឃុំខ្លួន" គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឲ្យឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរ អាចនឹងចេញដីកាបង្គាប់ឲ្យឃុំខ្លួនបានលុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន។

[109] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២០៦។

[110] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២២១។

[111] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២២២។

ប្រភេទ និងទម្ងន់នៃសារធាតុញៀនដែលជនត្រូវចោទបានលក់ ដូរ ។[112]

- បទឧក្រិដ្ឋ ៖ ប្រសិនបើជាបទឧក្រិដ្ឋ នោះការឃុំខ្លួនមានរយៈពេលមិនលើសពី ៦ (ប្រាំមួយ) ខែប៉ុន្តែនៅពេលដែលផុតរយៈពេលនេះហើយចៅក្រមស៊ើបសួរនៅតែមិនអាចបញ្ចប់នីតិវិធីស៊ើបសួររបស់ខ្លួនដោយមូលហេតុថា បទល្មើសមានភាពស្មុគស្មាញពេក ចៅក្រមស៊ើបសួរអាចពន្យាពេលនៃការឃុំខ្លួននេះបាន ៦ (ប្រាំមួយ)ខែទៀត តាមរយៈដីកាពន្យាពេលឃុំខ្លួនដោយដីកានេះត្រូវមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) និងត្រូវជូនដំណឹងទៅជនត្រូវចោទជាបន្ទាន់ ។[113] នៅក្នុងបទឧក្រិដ្ឋនេះ ចៅក្រមស៊ើបសួរ អាចពន្យាការឃុំខ្លួនបណ្តោះអាសន្នបានតែ ២(ពីរ) ដងគត់ ។[114]

- បទមជ្ឈិម ៖ ប្រសិនបើជាបទមជ្ឈិម នោះការឃុំខ្លួនមានរយៈពេលមិនលើសពី ៤ (បួន) ខែ ប៉ុន្តែនៅពេលដែលផុតរយៈពេលនេះហើយចៅក្រមស៊ើបសួរ អាចពន្យាពេលនៃការឃុំខ្លួននេះបានតែម្តងគត់ គឺមានរយៈពេល ២ (ពីរ)ខែ តាមរយៈដីកាពន្យាពេលឃុំខ្លួនដោយដីកានេះត្រូវមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) និងត្រូវជូនដំណឹងទៅជនត្រូវចោទជាបន្ទាន់ ។[115] ថរិវេលានេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ ។[116]

### ឃ.៣.២. រយៈពេលនៃការឃុំអនីតិជនមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ

អនីតិជនអាយុតិចជាង ១៤(ដប់បួន)ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះឲ្យឪពុកម្តាយ អ្នកអាណាព្យបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាលត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្នរង់ចាំសេចក្តីសម្រេចរបស់តុលាការ ។[117]

[112] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៤០។

[113] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២១១។

[114] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២០៨។

[115] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២១១។

[116] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២០៩។

[117] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២១២។

### ឃ.៣.៣. រយៈពេលនៃការឃុំខ្លួនអនីតិជន

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ និងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ មានដូចខាងក្រោម ៖

- បទឧក្រិដ្ឋ ៖ ការឃុំខ្លួនមិនអាចលើសពី ៤(បួន)ខែ កាលណាអនីតិជនមានអាយុតិចជាង ១៦(ដប់ប្រាំមួយ)ឆ្នាំ ការឃុំខ្លួនមិនអាចលើសពី ៦(ប្រាំមួយ)ខែ កាលណាអនីតិជនមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ។[118]

- បទមជ្ឈិម ៖ ការឃុំខ្លួនមិនអាចលើសពី ២(ពីរ)ខែ កាលណាអនីតិជនមានអាយុតិចជាង ១៦(ដប់ប្រាំមួយ)ឆ្នាំ និង ការឃុំខ្លួនមិនអាចលើសពី ៤(បួន)ខែ កាលណាអនីតិជនមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ។ ថិរវេលានៃការឃុំខ្លួនខាងលើនេះមិនត្រូវលើសពីពាក់កណ្ដាល នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ។[119]

### ខ/. ការស៊ើបសួរចំពោះបក្ខពួក

#### ខ១. ការចាត់ឲ្យស៊ើបសួរជំនួស

នៅក្នុងករណីដែលដំណើរការនៃការស៊ើបសួរ រកឃើញថាមានបក្ខពួកចូលរួមផ្សេងទៀត ចៅក្រមស៊ើបសួរ អាចប្រគល់សិទ្ធិឲ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬ ដល់អង្គការនគរបាលយុត្តិធម៌ តាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស[120] ដើម្បី

[118] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២១៣។

[119] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២១៤។

[120] យោងទៅតាមមាត្រា ១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ "ដីកាចាត់ឲ្យស៊ើបសួរជំនួស" គឺជាដីកាដែលបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ ដែលកិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងបទល្មើសដែលចោទប្រកាន់ ហើយដីកាចាត់ឲ្យស៊ើបសួរជំនួសនេះ មិនអាចមានលក្ខណៈទូទៅទេ គឺត្រូវណែនាំឲ្យបានច្បាស់។ ចៅក្រមស៊ើបសួរ កំណត់ថិរវេលាដែលត្រូវ អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស។ ដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខា ដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ ។

បំពេញកិច្ចស៊ើបរកបក្ខពួកទាំងនោះបាន ។[121] ដីកាចាត់ឲ្យស៊ើបសួរជំនួស ត្រូវមានទម្រង់ដូចខាងក្រោម៖

- ត្រូវមានចុះកាលបរិច្ឆេទ ហត្ថលេខា និងប្រថាប់ត្រារបស់ចៅក្រមដែលចេញដីកានោះ
- ដីកាត្រូវបញ្ជាក់នូវប្រភេទបទល្មើស និងកម្មវត្ថុនៃការចោទប្រកាន់
- បញ្ជាក់អំពីអត្តសញ្ញាណរបស់ជនត្រូវចោទ និងបក្ខពួក
- ដីកានេះបញ្ញត្តិត្រឹមតែកិច្ចនានាដែលបានជាប់ពាក់ព័ន្ធផ្ទាល់នឹងបទល្មើសដែលចុះក្នុងដីកាសន្និដ្ឋាន[122]តែប៉ុណ្ណោះ
- ដីកានេះត្រូវកំណត់ពីរយៈពេលនៃការអនុវត្ត

ព័ត៌មានទាំងអស់ខាងលើនេះ មានសារៈសំខាន់ណាស់ចំពោះដីកាចាត់ឲ្យស៊ើបសួរជំនួស ព្រោះប្រសិនបើភ្លេចនៅចំណុចណាមួយនោះ វានិងអាចធ្វើអោយដីកាមោឃៈភាពបានគ្រប់ពេលវេលា ។[123]

## ១២. ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស

កាលណាដីកាចាត់ឲ្យស៊ើបសួរជំនួស ត្រូវបានប្រគល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌នោះ មន្ត្រីនគរបាលយុត្តិធម៌អាចប្រើប្រាស់អំណាច ដូចដែលមានចែងក្នុងមាត្រា ១៧៨ (ស្តីពីការស្រាវជ្រាវនិងការពិនិត្យកំណត់ហេតុ) ដល់មាត្រា ១៨៥ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនីតិវិធីព្រហ្មទណ្ឌបាន ។ ចំពោះការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ គឺនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវធ្វើការរាយការណ៍ជូនចៅក្រមនោះតែប៉ុណ្ណោះ៖[124] មន្ត្រីនគរបាលយុត្តិធម៌ត្រូវបំពេញកិច្ចដែលមានចែងនៅក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស

---

[121] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៧៣។

[122] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបំពេញបន្ថែម។

[123] អំណោយស្ថានទូតបារាំង, *នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល* (២០០៩), ៣៥។

[124] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៧៦។

នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែបទប្បញ្ញត្តិនៃកថាខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[125]

- **កំណត់ហេតុស្តីពីការស្រាវជ្រាវ ពិនិត្យ និងការស្តាប់ចម្លើយ**

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។[126] មន្ត្រីនគរបាលយុត្តិធម៌ អាចកោះហៅ និងស្តាប់ចម្លើយសាក្សី ។ មុននឹងឆ្លើយចំពោះសំនួរ សាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួនថា និយាយតែការពិត ប៉ុន្តែចំពោះសាក្សីដែលជាឪពុក ម្តាយ បុព្វជនគ្រប់រូប និងញាតិរបស់ជនត្រូវចោទមិនត្រូវបានស្បថទេ ។[127] ដើម្បីគោរពនៅសិទ្ធិការពារខ្លួន មន្ត្រីនគរបាលយុត្តិធម៌ មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាម្នាក់ដែលមានតម្រុយនៃពិរុទ្ធភាពលើបុគ្គលនោះទេ ។ កាលណាការស្តាប់ចម្លើយសាក្សីណាម្នាក់បានធ្វើឲ្យលេចតម្រុយនៃពិរុទ្ធភាពលើសាក្សីនោះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ឈប់ការស្តាប់ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែ ដែលបានស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថា ខ្លួននឹងបកប្រែជូនតុលាការឲ្យបានត្រឹមត្រូវ ។ បុគ្គលដែលបានកោះហៅក្នុងឋានៈជាសាក្សីត្រូវបានចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ ដែលអាចបញ្ជាឲ្យចូលខ្លួន ដែលមានចុះអត្តសញ្ញាណនៃសាក្សី ។ បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រា ។ បញ្ជាឲ្យចូលបង្ហាញខ្លួន អនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំឲ្យសាក្សីចូលបង្ហាញខ្លួនចំពោះមុខខ្លួនបាន ។[128] មួយវិញទៀត មន្ត្រីនគរបាលយុត្តិធម៌មិនអាចសួរចម្លើយជនត្រូវចោទបានទេ។[129]

- **ការឆែកឆេរ និងការចាប់យកវត្ថុតាង**

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងនៅក្នុងលក្ខខណ្ឌដែលចែង

---

[125] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៧៧។

[126] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៧៨។

[127] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៥៦។

[128] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៧៩។

[129] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៨០។

នៅក្នុងមាត្រា ៩១(ការឆែកឆេរ) និងមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប៉ុន្តែការអនុញ្ញាតដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី២ កថាខ័ណ្ឌទី១ មាត្រា៩១ (ការឆែកឆេរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវតែផ្តល់ឲ្យដោយចៅក្រមស៊ើបសួរ ។[130]

➢ **ការឃាត់ខ្លួន**

បទប្បញ្ញត្តិនៃមាត្រា ៩៦ (ការឃាត់ខ្លួន) ដល់មាត្រា១០២ (កំណត់ហេតុសរុបនៃការឃាត់ខ្លួន) ស្តីពីការឃាត់ខ្លួនត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ប៉ុន្តែអំណាចដែលប្រគល់ឲ្យដោយព្រះរាជអាជ្ញា ត្រូវប្រើប្រាស់ដោយចៅក្រមស៊ើបសួរហើយសម្រាប់ការអនុវត្តមាត្រា ១០៣ (ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន) និងមាត្រា១០៤ (រយៈពេលនៃការបញ្ជូនខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅពេលផុតកំណត់នៃការឃាត់ខ្លួនជនដែលត្រូវបានឃាត់ខ្លួនត្រូវតែនាំទៅបង្ហាញនៅចំពោះមុខចៅក្រមស៊ើបសួរ ។[131]

➢ **ការស្តាប់ទូរស័ព្ទ**

កាលណាដីកាចាត់ឲ្យស៊ើបសួរជំនួស បានចែងអំពីការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទ ឬការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ដូចជា សារតាមទូរសារ ឬ សារតាមអ៊ីនធើណែត មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលប្រគល់ឲ្យចៅក្រមស៊ើបសួរដោយវាក្យខណ្ឌទី២ កថាខ័ណ្ឌទី១ និងកថាខ័ណ្ឌទី២ នៃ មាត្រា១៧២ (ការស្តាប់ទូរស័ព្ទជាអាទិ៍ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។[132]

➢ **កំណត់ហេតុស្តីពីការកសាងដោយមន្ត្រីនគរបាលយុត្តិធម៌**

កំណត់ហេតុដែលធ្វើឡើង ដោយមន្ត្រីនគរបាលយុត្តិធម៌នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវចុះ ៖[133]

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌
- អង្គភាពរបស់មន្ត្រីនោះ

---

130 ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៨១។

131 ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៨២។

132 ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៨៣។

133 ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៨៤។

- កាលបរិច្ឆេទ

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ ។ ពាក្យឆូតលុប និងការយោង ត្រូវមានបញ្ជាក់យល់ព្រម ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រ ។[134]

**ច/. ការដកយកសំណាក**

ដើម្បីស្វែងរកការពិត ថាតើវត្ថុតាងដែលចាប់បាននោះជាគ្រឿងញៀនពិតប្រាកដឬទេនោះ គឺវាទាមទារឲ្យធ្វើការដកសំណាកមកធ្វើកោសលវិច័យ ពីព្រោះថាការធ្វើតេស្តនៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌គ្រាន់តែជាការធ្វើតេស្តបឋមតែប៉ុណ្ណោះ ដែលមិនអាចមានភាពជឿជាក់បាន ១០០% នោះទេ ។ ដូច្នេះចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ច ត្រូវតែធ្វើការដកយកសំណាកមកធ្វើកោសលវិច័យជាបន្ទាន់ ដោយត្រូវធ្វើការដកយកសំណាកយ៉ាងតិច ៣(បី)កញ្ចប់ ឬតាមចំនួនដែលត្រូវការជាចាំបាច់ ។ សំណាកនីមួយៗ ត្រូវដាក់ក្នុងកញ្ចប់បិទស្លាកបោះត្រាជាសម្គាល់ នៅលើកញ្ចប់ និងស្លាកត្រូវកត់ចំណាំប្រភេទ ទម្ងន់នៃវត្ថុដែលនៅខាងក្នុង ។ បន្ទាប់ពីការដកសំណាកហើយ ត្រូវបិទស្លាកបោះត្រាឡើងវិញលើកញ្ចប់ដើម និងត្រូវធ្វើកំណត់ហេតុមួយបញ្ជាក់អំពីចំនួនសំណាកដែលបានដកយក ប្រភេទ និងទម្ងន់នៃវត្ថុដែលសង្ស័យថាជាគ្រឿងញៀនដែលមាននៅក្នុងកញ្ចប់នីមួយៗ ព្រមទាំងការផ្លាស់ប្តូរទៅលើស្លាក និងត្រាដើម ។ កំណត់ហេតុ និងការសរសេរបញ្ជាក់ទាំងអស់លើសំណាកនីមួយៗ និងការបិទស្លាកបោះត្រាដែលបានធ្វើឡើងវិញ ត្រូវចុះអត្តសញ្ញាណ និងហត្ថលេខារបស់បុគ្គលដែលបានចូលរួមក្នុងកិច្ចប្រតិបត្តិការដកសំណាកនោះ ។[135]

**ច១. ការចូលរួមដកសំណាក**

ការដកសំណាកគ្រឿងញៀនដែលបានចាប់យក និងសង្ស័យថាជាគ្រឿងញៀនខុសច្បាប់ អាចធ្វើទៅបាន លុះត្រាតែមានការចូលរួមពីស្ថាប័នសំខាន់ៗដែលពាក់ព័ន្ធដូចខាងក្រោម ៖

- ចៅក្រមស៊ើបសួរ
- ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង

[134] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១០៨។

[135] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៨២។

- ក្រឡាបញ្ជី
- មន្ត្រីនគរបាលយុត្តិធម៌ ស្នងការដ្ឋាននគរបាល ឬមន្ត្រីផ្នែកការិយាល័យស្រាវជ្រាវ និងប្រឆាំគ្រឿងញៀន
- ជនត្រូវចោទ[136]

## ច២. នីតិវិធីនៃការដកយកសំណាកសម្រាប់ធ្វើកោសលវិច័យ

ការដកសំណាកមិនមែនចេះតែដកនោះទេ តែវាចាំបាច់ត្រូវតែកំណត់ពីបរិមាណ និងចំនួនត្រឹមត្រូវសម្រាប់ដកយកទៅធ្វើកោសលវិច័យ និងលក្ខណៈបច្ចេកទេស ដើម្បីឈានទៅរកការធ្វើកោសលវិច័យ ។ សំណាកត្រូវដកចេញពីកញ្ចប់វេចខ្ចប់ដែលមន្ត្រីនគរបាលប្រគល់ឲ្យ បន្ទាប់មកចៅក្រមស៊ើបសួរនឹងអនុញ្ញាតឲ្យធ្វើការថ្លឹងសារធាតុញៀនទាំងនោះ និងឲ្យក្រឡាបញ្ជីធ្វើកំណត់ត្រាពីការដកហូតនោះ ។[137]

## ច៣. ការបញ្ចប់នីតិវិធីនៃការដកយកសំណាកសម្រាប់ធ្វើកោសលវិច័យ

មុនបញ្ចប់កិច្ចនីតិវិធីនៃការដកហូតសំណាក ក្រឡាបញ្ជីត្រូវតែធ្វើកំណត់ហេតុស្តីពីការដកហូតសំណាកវត្ថុចាប់យកដែលសង្ស័យថាជាថ្នាំញៀន ។ កំណត់ហេតុនេះ នឹងបញ្ជាក់ពីនីតិវិធីនៃការដកហូត ចំនួនដែលត្រូវដកយកពីបរិមាណសរុប និងការធ្វើការបិទវេចខ្ចប់ ។ បន្ទាប់ពីបានធ្វើរួចរាល់ត្រូវមានការចុះហត្ថលេខារបស់ជនទាំងនោះដែលបានចូលរួម ។

ជារួមទៅ បន្ទាប់ពីបានបញ្ជាក់នីតិវិធីនៃការដកសំណាក ត្រូវតែវេចខ្ចប់សំណាកនោះបញ្ជូនមកធ្វើកោសលវិច័យដូចខាងក្រោម៖

- ត្រូវដាក់សំណាកទៅក្នុងថង់ផ្លាស្ទិចតូច រួចខ្ចប់ក្នុងស្រោមសំបុត្រតូចហើយបិទជិតដោយមានហត្ថលេខាអ្នកចូលរួម និងស្នាមមេដៃរបស់ជនល្មើស ដោយធ្វើបែបនេះឲ្យបាន ៣(បី)កញ្ចប់ ដែលកញ្ចប់នីមួយៗត្រូវតែមានតម្លៃស្មើៗគ្នា ទាំងបរិមាណ និងទាំងលក្ខណៈរូប ។

---

[136] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ២០។

[137] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ២១។

– បន្ទាប់មកច្រកកញ្ចប់ទាំង ៣ (បី) កញ្ចប់ ទៅក្នុងស្រោមសំបុត្ររក្សាវត្ថុតាងរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានផ្តល់ជូនដោយបំពេញពិតមាននៅលើស្រោមសំបុត្រនោះឲ្យបានគ្រប់ និងមានហត្ថលេខាអ្នកចូលរួម និងស្នាមមេដៃរបស់ជនត្រូវចោទ ។ បន្ទាប់មក វត្ថុតាងដែលបានវេចខ្ចប់ និងបិទជិត ត្រូវបានបញ្ជូនទៅធ្វើកោសលវិច័យនៅអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅរាជធានីភ្នំពេញ[138]។[139]

### ឆ/. ការធ្វើកោសលវិច័យ

#### ឆ១. ការចាត់តាំងអ្នកជំនាញ

ការធ្វើកោសលវិច័យ ជាសមត្ថកិច្ចរបស់អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន ដូច្នេះចៅក្រមស៊ើបសួរ ត្រូវធ្វើដីកាចាត់តាំងអ្នកជំនាញ[140] ដើម្បីប្រគល់ភារកិច្ចអោយអ្នកជំនាញនោះធ្វើកោសលវិច័យតាមបច្ចេកទេសវិទ្យាសាស្ត្រ ដោយអ្នកជំនាញនេះត្រូវបានទទួលស្គាល់ដោយក្រសួងយុត្តិធម៌ មានន័យថាអ្នកជំនាញនោះមានឈ្មោះក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ ដែលត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។[141] ឧទាហរណ៍៖ សេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀនរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលចូលជាធរមានថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១២ និងសេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀនលេខ ៣៤ កយ.សសរ/១៧ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៧ របស់ទីស្តីការក្រសួងយុត្តិធម៌ ។[142]

---

[138] នាពេលបច្ចុប្បន្ននេះ មានតែអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅរាជធានីភ្នំពេញទេ ដែលអាចធ្វើកោសលវិច័យពីសារធាតុញៀននេះបាន ព្រោះថាយើងមានម៉ាស៊ីនពិសោធន៍តែមួយ ដូច្នេះគ្រប់បណ្តាខេត្ត-ក្រុង ទាំងអស់ត្រូវបញ្ជូនវត្ថុតាងដែលសង្ស័យថាជាគ្រឿងញៀនទាំងនោះ មកធ្វើកោសលវិច័យនៅអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅរាជធានីភ្នំពេញ ។

[139] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ២១។

[140] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៦២ កថាខណ្ឌ ១។

[141] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៦៣។

[142] អាចរកមើលបាននៅឧបសម្ព័ន្ធនៃសារណានេះ ។

ការធ្វើកោសលវិច័យនេះ គឺដើម្បីឲ្យបានដឹងអំពីប្រភេទធាតុផ្សំ និងកម្រិតធាតុសកម្ម ឬកម្រិតភាពសុទ្ធរបស់គ្រឿងញៀនដែលបានដកយក ហើយការធ្វើកោសលវិច័យនេះត្រូវធ្វើដោយឆាប់បំផុតបន្ទាប់ពីការដកយក ដើម្បីចៀសវាងការខូចខាតថយចុះនូវសារធាតុ រូបវត្ថុ និងជាតិគីមីនៃវត្ថុនោះ ។ អ្នកជំនាញ ត្រូវបញ្ជាក់ក្នុងរបាយការណ៍របស់ខ្លួននូវចំនួនសំណាកដែលគេបានប្រគល់ឲ្យអំពីប្រភេទ និងទម្ងន់នៃគ្រឿងញៀនដែលមាននៅក្នុងសំណាកនីមួយៗ ចំនួនសំណាកដែលបានប្រើប្រាស់ធ្វើកោសលវិច័យ ហើយប្រសិនបើមានត្រូវបញ្ជាក់ចំនួនសំណាកដែលបានប្រមូលមកវិញសល់ពីការធ្វើកោសលវិច័យ និងការប្រែប្រួលទៅលើសំណាកទាំងនោះ ។[143]ដីកាចាត់តាំងអ្នកជំនាញនេះ ត្រូវបញ្ជាក់អំពីបេសកកម្ម[144]របស់អ្នកជំនាញនោះ ព្រមទាំងរយៈពេលដែលត្រូវបំពេញបេសកកម្ម ។

### ឆ២. លទ្ធផលនៃកោសលវិច័យ

អ្នកជំនាញបំពេញបេសកម្មរបស់ខ្លួន ក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ ហើយអ្នកជំនាញត្រូវជូនពត៌មានដល់ចៅក្រមស៊ើបសួរ អំពីការប្រព្រឹត្តទៅនៃបេសកម្មរបស់ខ្លួនដូចជាករណីការលំបាកដែលបានជួបប្រទះជាដើម ។ ប្រសិនជាអ្នកជំនាញមិនគោរពរយៈពេលដែលបានកំណត់របស់ចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរចាត់អ្នកជំនាញផ្សេងទៀតជំនួសអ្នកជំនាញនោះ ប៉ុន្តែប្រសិនជាកាលៈទេសៈតម្រូវនោះ ចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមដីកាសម្រេចឲ្យធ្វើការពន្យាពេលបាន ។[145]

នៅពេលដែលការធ្វើកោសល្យវិច័យបានបញ្ចប់ អ្នកជំនាញធ្វើរបាយការណ៍ដែលក្នុងនោះត្រូវរៀបរាប់យ៉ាងច្បាស់លាស់អំពីប្រតិបត្តិការ និងការធ្វើសេចក្តីសន្និដ្ឋាន ។ កាលណាអ្នកជំនាញបានបំបែកស្លាកដើម្បីពិនិត្យវត្ថុដែលចាប់យក អ្នកជំនាញត្រូវចុះនិទ្ទេសអំពីបញ្ហានេះនៅក្នុងរបាយការណ៍របស់ខ្លួន ។ អ្នកជំនាញត្រូវប្រគល់របាយការណ៍ និងវត្ថុដែលចាប់យកដល់ចៅក្រមស៊ើបសួរកំណត់ហេតុស្តីពីការប្រគល់សងនូវវត្ថុ និងជាយថាហេតុការបិទស្លាកជាថ្មីត្រូវតែធ្វើឡើងវិញ ។[146]

---

143 ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៨៣។

144 បេសកកម្មអាចទាក់ទងទៅនឹងបញ្ហាដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ។

145 ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៦៦។

146 ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៦៨។

**ឆ៣. ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ**

កាលណារបាយការណ៍កោសលវិច័យត្រូវបានធ្វើរួចហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ហើយរបាយការណ៍នេះត្រូវដាក់ក្នុងសំណុំរឿង ។ ចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ និងមេធាវី ដើម្បីប្រាប់ឲ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ ។ ក្រៅពីនេះ ចៅក្រមស៊ើបសួរអាចកំណត់រយៈពេលមិនតិចជាង១០ថ្ងៃ ដើម្បីទទួលការដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យពីសំណាក់ព្រះរាជអាជ្ញា ជនត្រូវចោទ មេធាវី ប៉ុន្តែចៅក្រមស៊ើបសួរក៏មានសិទ្ធិក្នុងការបដិសេធតាមពាក្យសុំខាងលើនេះបានដែរ ដោយត្រូវធ្វើការសម្រេចតាមដីកាដោយមានសំអាងហេតុ ដែលត្រូវសម្រេចក្នុងរយៈពេល ០៥ថ្ងៃ សម្រាប់ព្រះរាជអាជ្ញា និង១ខែ សម្រាប់ជនត្រូវចោទ ។[147]

## ផ្នែកទី២ ដំណើរការនៃការបិទការស៊ើបសួរ

### កថាខណ្ឌទី១ ការជូនដំណឹងអំពីការបិទស៊ើប

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរ ត្រូវជូនព័ត៌មាននៃការបិទការស៊ើបសួរនេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវី ។[148]

### កថាខណ្ឌទី២ ការបញ្ជូនសំណុំរឿងទៅអយ្យការពិនិត្យ

នៅពេលដែលចៅក្រមស៊ើបសួរបានជូនដំណឹងទៅព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីរួចរាល់ហើយ ២(ពីរ) ថ្ងៃក្រោយមក ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញា ត្រូវធ្វើការស្នើសុំឲ្យបំពេញកិច្ច ដូចដែលមានក្នុងមាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ មួយវិញទៀតក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួន និង១(មួយ)ខែ[149] ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយមានភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានស្ថាពរ ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរ

[147] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៧០។

[148] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៤៦ កថាខណ្ឌ ១។

[149] ថិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាទទួលសំណុំរឿង។

ថា ការស៊ើបសួរត្រូវបានបញ្ចប់ នោះព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ។ នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ ព្រះរាជអាជ្ញា អាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងចោទប្រកាន់ ។[150]

### កថាខណ្ឌទី៣ ការចេញដីកាដំណោះស្រាយ

ចៅក្រមស៊ើបសួរ បិទការស៊ើបសួរតាមដីកាដំណោះស្រាយ ។ ដីកានេះអាចជាដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់ ។

- ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ៖ កាលណាជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ។ ដីកាត្រូវតែរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ។
- ដីកាលើកលែងចោទប្រកាន់ ៖ កាលណាអំពើនោះ (១) មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ, (២) ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់[151], (៣) គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។

ដីកាដំណោះស្រាយ ជានិច្ចកាលត្រូវតែមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរ មិនអាចជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកានេះ ត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ជាដើម ។[152]

### កថាខណ្ឌទី៤ ការរក្សាជនជាប់ចោទឲ្យនៅក្នុងឃុំបណ្ដោះអាសន្ន

កាលណាចៅក្រមស៊ើបសួរ សម្រេចថាបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ នោះចៅក្រមស៊ើបសួរត្រូវរក្សាជនត្រូវចោទឲ្យនៅជាប់ឃុំបណ្ដោះអាសន្ន តាមរយៈដីការក្សាជនត្រូវចោទជាបណ្ដោះអាសន្ន ដែលជនត្រូវចោទត្រូវរក្សាទុកឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ ។ សេចក្ដីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំ លែងមានអនុភាពក្នុង

[150] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៤៦។

[151] ក្នុងករណីដែលការចាត់ឲ្យស៊ើបសួរជំនួស មិនអាចស្វែងរកសវតាជាតិនូវជនដែលមានក្នុងដីកានោះ។ ឧទាហរណ៍៖ ជាជនមិនស្គាល់មុខ ឬបក្ខពួកដែលរត់គេចខ្លួន ។

[152] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៤៧។

រយៈពេល៤(បួន)ខែ ។ ប្រសិនបើជនត្រូវចោទមិនបានចូលបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤(បួន)ខែទេ ជនត្រូវចោទនេះត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយឯកឯង ។[153]

### កថាខណ្ឌទី៥ ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

ប្រសិនបើចៅក្រមស៊ើបសួរ សម្រេចចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរ ត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ ។[154]

[153] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៤៩។

[154] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៥០។

# ជំពូកទី៥

# ចំណាត់ការសំណុំរឿងក្នុងដំណាក់កាលជំនុំជម្រះ

រវាងមុខងារជាចៅក្រម និងមុខងារជាព្រះរាជអាជ្ញា ឬជាព្រះរាជអាជ្ញារង គឺមានវិសមិតភាពនឹងគ្នាយ៉ាងដាច់ខាត មានន័យថា ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬជាចៅក្រមស៊ើបសួរលើរឿងក្ដីណាមួយ មិនអាចចូលរួមជាចៅក្រមជំនុំជម្រះលើរឿងក្ដីនោះបានទេ បើពុំដូច្នេះទេសាលក្រមនឹងត្រូវទុកជាមោឃៈ ។[155]

## ផ្នែកទី១ ដំណើរការនៃការជំនុំជម្រះ

### កថាខណ្ឌទី១ ការចាត់តាំងចៅក្រមជំនុំជម្រះ

បន្ទាប់ពីចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនជាប់ចោទទៅតុលាការជំនុំជម្រះហើយ ប្រធានតុលាការត្រូវចាត់តាំងចៅក្រមជំនុំជម្រះ ដោយគិតពីវិសមិតភាពនៃចៅក្រម ។ ចៅក្រមជំនុំជម្រះអាចជាចៅក្រមណាក៏បានក្រៅពីចៅក្រមដែលពាក់ព័ន្ធក្នុងការស៊ើបសួរ ឬ អាចជាប្រធានតុលាការតែម្ដងក៏បានដែរ ។[156]ជាទូទៅ ប្រធានតុលាការត្រូវតែគិតគូរកាលបរិច្ឆេទនៃសវនាការតាមរយៈពេលដែលត្រូវគោរពការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឲ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួននៅមុខតុលាការ[157] និងរយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅ និងការបង្គាប់ឲ្យចូលខ្លួន[158]ដើម្បីកំណត់កាលបរិច្ឆេទបើកសវនាការ[159] ប៉ុន្តែក្នុងករណីដែលជនជាប់

[155] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៨៨។

[156] កុយ នាម, *ដំណើរការក្ដីនៅក្នុងតុលាការ* (ភ្នំពេញ, ១៩៩៨), ១៧១។

[157] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៤៥៧។

[158] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៤៦៦។

[159] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៩២។

ចោទត្រូវបានឃុំខ្លួន រយៈពេលខាងលើនេះមិនចាំបាច់គោរពទេ[160] កាលបរិច្ឆេទសវនាការ ត្រូវជូនដំណឹងដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញា ។

ជាការពិតណាស់ ប្រធានតុលាការជាអ្នកចាត់តាំងចៅក្រមជំនុំជម្រះ ប៉ុន្តែក្នុងករណីមួយចំនួនចៅក្រមជំនុំជម្រះនេះ អាចត្រូវបានជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទ ប្ដឹងជិតចិត្ត[161] បានផងដែរ ដូចដែលមានចែងក្នុងមាត្រា **៥៥៦** ដល់ មាត្រា **៥៦៥** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## កថាខណ្ឌទី២ ការចូលរួមសវនាការ

បន្ទាប់ពីកំណត់កាលបរិច្ឆេទសវនាការរួចរាល់អស់ហើយ ព្រះរាជអាជ្ញាត្រូវកោះហៅឲ្យចូលរួមសវនាការនូវ ជនជាប់ចោទ សាក្សី អ្នកជំនាញ អ្នកបកប្រែ មេធាវី ឬជនដែលពាក់ព័ន្ធដទៃទៀតជាដើម ។[162] ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការផ្ទាល់[163] ហើយជនជាប់ចោទដែលចូលបង្ហាញខ្លួននៅពេលសវនាការក្នុងឋានៈជាជនជាប់ឃុំនោះ[164] នៅតែជាប់ឃុំដដែលរហូតដល់មានសាលក្រមលើអង្គសេចក្ដី លើកលែងតែតុលាការបង្គាប់ឲ្យដោះលែងឲ្យមានសេរីភាពវិញ ។[165]

## កថាខណ្ឌទី៣ ការបើកសវនាការ

សវនាការត្រូវធ្វើជាសាធារណៈ លើកលែងតែតុលាការយល់ឃើញថាសាធារណៈភាពបង្កឲ្យ

[160] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៥៨៦ កថាខណ្ឌ ២។

[161] យោងទៅតាមមាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ "បណ្ដឹងជិតចិត្ត" គឺជាបណ្ដឹងដែលបើកឲ្យភាគីណាមួយធ្វើការប្ដឹងតែចៅក្រមអាសនៈណាដែលខកខានដោយចេតនាមិនបំពេញករណីកិច្ចចំពោះវិជ្ជាជីវៈរបស់ខ្លួនឲ្យបានត្រឹមត្រូវ ឬ បំពានដោយរំលោភលើក្រមសីលធម៌របស់តុលាការ។

[162] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៨៥។

[163] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣០០។

[164] ចំពោះសេចក្ដីសម្រេចរក្សាទុកខ្លួនជនជាប់ចោទនៅក្នុងឃុំ បណ្ដោះអាសន្ន ត្រូវអស់អនុភាពក្នុងរយៈពេល ៤(បួន)ខែ ដូច្នេះ ក្នុងករណីដែលជនជាប់ចោទមិនបានបង្ហាញខ្លួនចំពោះមុខតុលាការក្នុងរយៈ ៤(បួន)ខែ នេះទេ ជនជាប់ចោទត្រូវបានដោះលែងអោយមានសេរីភាពដោយឯកឯង។

[165] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣០៥។

មានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ ដល់ទំនៀមទម្លាប់ ។[166] ដំណើរការនៅពេលសវនាការ មានការប្រព្រឹត្តទៅជាបន្តបន្ទាប់ដូចជា ការពិភាក្សាដេញដោល និងការកំណត់អំពីការប្រកាស សាលក្រម ។

➢ **ការពិភាក្សាដេញដោល**

ប្រធានសវនាការធានាឲ្យមានសណ្តាប់ធ្នាប់ល្អនៅក្នុងពេលសវនាការ និងអាចធ្វើការហាម ឃាត់អនីតិជនខ្លះ ឬទាំងអស់មិនឲ្យចូលក្នុងបន្ទប់សវនាការ ហើយក៏អាចបង្គាប់ឲ្យបណ្តេញបុគ្គល គ្រប់រូបដែលបង្កឲ្យមានការច្របូកច្របល់ដល់របៀបរៀបរយនៃការពិភាក្សាដេញដោល ។[167]

ជាការចាប់ផ្តើមការពិភាក្សាដេញដោល ក្រឡាបញ្ជីនឹងធ្វើការហៅឈ្មោះជនជាប់ចោទ មេធាវី អ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់អត្តសញ្ញាណ ។[168] ក្រឡាបញ្ជីសរសេរកំណត់ហេតុសវនាការដោយ រៀបរាប់ពីដំណើរការប្រព្រឹត្តទៅនៃសវនាការ និងសំណួរចម្លើយជនពាក់ព័ន្ធនៅក្នុងសវនាការ ។ កំណត់ហេតុនេះ ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋាការផ្ទៀងផ្ទាត់ដោយប្រធានសវនាការ ក្នុងរយៈ ១០ ថ្ងៃក្រោយពីថ្ងៃប្រកាសសាលក្រម ។[169]

➢ **ការប្រកាសសាលក្រម**

សាលក្រមត្រូវសម្រេចចេញនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬនៅពេល សវនាការលើកក្រោយ ។ នៅក្នុងករណីនេះ ប្រធានសវនាការធ្វើការជូនដំណឹងដល់ភាគីទាំងឡាយ ដែលមានវត្តមានអំពីថ្ងៃដែលត្រូវប្រកាសសាលក្រម ។[170]

---

166 ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣១៦។

167 ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣១៨។

168 ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣២២។

169 ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣៤១។

170 ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣៤៧។

### កថាខណ្ឌទី៤ ការចេញសាលក្រមសម្រេច[171]

សាលក្រម ត្រូវបានចេញចំពោះមុខជនជាប់ចោទ ហើយអាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល ០១(មួយ)ខែ ដោយគិតពីពេលដែលប្រកាសសាលក្រម ។[172]

## ផ្នែកទី២ ការអនុវត្តទោស

### កថាខណ្ឌទី១ ពន្ធនាគារ និង ពិន័យ

#### ក/. ការកម្រិតទោស

ចៅក្រមជំនុំជម្រះ ធ្វើការសម្រេចអំពីទោសដែលត្រូវអនុវត្តចំពោះពិរុទ្ធជន ថាតើប្រភេទទោសណាមួយដែលត្រូវយកមកដាក់ឲ្យសមតាមកម្រិត នៃសារធាតុដែលបានជួញដូរដោយខុសច្បាប់។ តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស, ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ, ទៅលើសភាពផ្លូវចិត្ត, ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុ និង ព្រមទាំងទៅលើកិរិយាមាយាទរបស់ជនជាប់ល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ។ ចៅក្រមជំនុំជម្រះ អាចដាក់ទោសទាំងទោសពន្ធនាគារផង ទោសពិន័យជាប្រាក់ផង ហើយករណីខ្លះចៅក្រមក៏ធ្វើការព្យួរទោសផងដែរ ដែលការសម្រេចទាំងនេះអាស្រ័យទៅលើព្យសនកម្មនៃបទល្មើស និងកម្រិតនៃការប្រព្រឹត្តបទល្មើស ។[173] បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀនត្រូវបានផ្តន្ទាទោស និងពិន័យជាប្រាក់ដូចខាងក្រោម ៖[174]

---

171 លោកអ្នកអាចរកមើលសេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញបាននៅក្នុងឧបសម្ព័ន្ធខាងក្រោយ ។

172 ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៦ មិថុនា ២០១៣, មាត្រា ៣៨២ថ្មី។

173 ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ២៦។

174 ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៤០។

| ទោសពន្ធនាគារ | ទោសពិន័យជាប្រាក់ |
|---|---|
| ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ[175] | ៤.០០០.០០០(បួនលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន) រៀល |
| ៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ[176] | ១០.០០០.០០០(ដប់លាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល |
| ១០(ដប់)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ[177] | ២០.០០០.០០០(ម្ភៃលាន) ទៅ ៤០.០០០.០០០(សែសិបលាន)រៀល |

[175] បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាការផ្ដល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

[176] កាលបើ (១) បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង, (២) បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ, (៣) ជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធចាប់ពី ៤០០(បួនរយ)ក្រាម រហូតដល់ក្រោម ៨០០(ប្រាំបីរយ)ក្រាម, (៤) ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ២០០(ពីររយ)ក្រាម រហូតដល់ក្រោម ៤០០(បួនរយ)ក្រាម, (៥) ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធចាប់ពី ៤(បួន) ក្រាម រហូតដល់ក្រោម ២៥(ម្ភៃប្រាំ)ក្រាម, (៦) អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ១៥(ដប់ប្រាំ)ក្រាម រហូតដល់ក្រោម ៨០(ប៉ែតសិប)ក្រាម, (៧) កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ៨(ប្រាំបី)គីឡូក្រាម រហូតដល់ក្រោម ២០(ម្ភៃ)គីឡូក្រាម, (៨) ផ្លែអាភៀនស្រស់ មានបរិមាណចាប់ពី ៨(ប្រាំបី)គីឡូក្រាម រហូតដល់ក្រោម ៤០(សែសិប)គីឡូក្រាម, (៩) ផ្លែអាភៀនស្ងួត មានបរិមាណចាប់ពី ៤០ (សែសិប)គីឡូក្រាម រហូតដល់ក្រោម ១៦០(មួយរយហុកសិប)គីឡូក្រាម, (១០) បណ្ដាសារធាតុញៀន ដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ១៥(ដប់ប្រាំ)ក្រាម រហូតដល់ក្រោម ៨០(ប៉ែតសិប)ក្រាម, (១១) សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុស្មើនឹងបរិមាណសុទ្ធសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយចាប់ពីចំណុចទី៣ ដល់ចំណុចទី១០ នៃកថាខណ្ឌនេះ។

[177] កាលបើ (១) ជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធចាប់ពី ៨០០(ប្រាំបីរយ)ក្រាម រហូតដល់ក្រោម ១.៦០០ (មួយពាន់ប្រាំមួយរយ) ក្រាម, (២) ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៤០០(បួនរយ)ក្រាម រហូតដល់ក្រោម ៨០០(ប្រាំបីរយ)ក្រាម, (៣) ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធចាប់ពី ២៥(ម្ភៃប្រាំ)ក្រាម រហូតដល់ក្រោម ៨០(ប៉ែតសិប)ក្រាម, (៤) អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប)ក្រាម រហូតដល់ក្រោម ២៤០(ពីររយសែសិប)ក្រាម, (៥) កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ២០(ម្ភៃ)គីឡូក្រាម រហូតដល់ក្រោម ៦០(ហុកសិប)គីឡូក្រាម, ៦-ផ្លែអាភៀនស្រស់ មានបរិមាណចាប់ពី ៤០ (សែសិប)គីឡូក្រាម រហូតដល់ក្រោម ១២០(មួយរយម្ភៃ) គីឡូក្រាម, (៧) ផ្លែអាភៀនស្ងួត មានបរិមាណចាប់ពី ១៦០(មួយរយហុកសិប)គីឡូក្រាម រហូតដល់ក្រោម ៤៨០(បួនរយប៉ែតសិប)គីឡូក្រាម, (៨) បណ្ដាសារធាតុញៀន ដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ៨០(ប៉ែតសិប)ក្រាម រហូតដល់ក្រោម ២៤០ (ពីររយសែសិប)ក្រាម, (៩) សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុស្មើនឹងបរិមាណសុទ្ធសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុចទី១ ដល់ចំណុចទី៨ នៃកថាខណ្ឌនេះ។

| | |
|---|---|
| ២០(ម្ភៃ)ឆ្នាំ ទៅ ៣០(សាមសិប)ឆ្នាំ ឬ អស់មួយជីវិត[178] | ៤០.០០០.០០០(សែសិបលាន)រៀល ទៅ ១០០.០០០.០០០(មួយរយលាន)រៀល |

**ខ/. ការប្រកាសមូលទោស**

ក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង តុលាការអាចប្រកាសមូលទោសដូចខាងក្រោម ៖[179]

- ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ
- ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ
- ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

[178] កាលបើ (១) ជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធចាប់ពី ១.៦០០(មួយពាន់ប្រាំមួយរយ)ក្រាមឡើងទៅ, (២) ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៨០០(ប្រាំបីរយ)ក្រាមឡើងទៅ, (៣) ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធចាប់ពី ៨០(ប៉ែតសិប)ក្រាមឡើងទៅ, (៤) អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ២៤០(ពីររយសែសិប)ក្រាមឡើងទៅ, (៥) កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ៦០(ហុកសិប)គីឡូក្រាមឡើងទៅ, (៦) ផ្លែអាភៀនស្រស់ មានបរិមាណចាប់ពី ១២០(មួយរយម្ភៃ)គីឡូក្រាមឡើងទៅ, (៧) ផ្លែអាភៀនស្ងួត មានបរិមាណចាប់ពី ៤៨០(បួនរយប៉ែតសិប)ឡើងទៅ, (៨) បណ្តាសារធាតុញៀន ដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ផ្សេងទៀតមានបរិមាណសុទ្ធចាប់ពី ២៤០(ពីររយសែសិប)ក្រាមឡើងទៅ។

៩-សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុស្មើនឹងបរិមាណសុទ្ធសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុចទី១ ដល់ចំណុចទី៨ នៃកថាខណ្ឌនេះ។

[179] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៧ (ពីពេលនេះតទៅហៅថាក្រមព្រហ្មទណ្ឌ)។

### គ/. ការហាមឃាត់មិនឲ្យប្រើទោសជំនួស និងទោសបន្ថែមជំនួសឲ្យមូលទោស

មូលទោសចំពោះបទល្មើលជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មិនអាចត្រូវបានជំនួសដោយទោសជំនួស[180] ឬទោសបន្ថែម[181] ដូចមានចែងក្នុងក្រមព្រហ្មដែលអាចអនុវត្តបានដូចបទល្មើសធម្មតានោះទេ[182] ពីព្រោះថា បទល្មើសនេះបង្កឲ្យមានព្យសនកម្មដ៏ធំធេង ទាំងរូបវន្តបុគ្គល និងសង្គមជាតិទាំងមូល ។

ប៉ុន្តែ ទោះបីជាមានការចែងច្បាស់លាស់ការមិនអាចជំនួយទោសបន្ថែមទៅលើមូលទោសបានក្តី យើងឃើញថា ក៏មានបដិបញ្ញាត្តិទៅនឹងលក្ខខណ្ឌនៃការប្រកាសទោសបន្ថែម នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសនេះផងដែរ ដែលតុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន[183] ប្រសិនបើទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន ។ ទោសបន្ថែម ត្រូវប្រកាសជាកាតព្វកិច្ចប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ ។[184]

## ផ្នែកទី៣ ការចាត់ចែងចំពោះវត្ថុរឹបអូសដែលពាក់ព័ន្ធនឹងបទល្មើស

វត្ថុតាងដែលជាគ្រឿងញៀន ឬវត្ថុតាងដែលមិនមានការពាក់ព័ន្ធនឹងត្រូវបានយកទៅចាត់ចែងតាមច្បាប់បន្ទាប់ពីដំណើរការជំនុំជម្រះក្តីត្រូវបានបញ្ចប់ និងចូលជាស្ថាពរនូវសាលក្រម ។[185]

[180] យោងតាមមាត្រា ៩៨ នៃក្រមព្រហ្មទណ្ឌ, ការប្រកាសទោសជំនួស គឺជាការប្រកាសទោសការងារសហគមន៍ជំនួសឲ្យមូល ទោស។ តុលាការដែលប្រកាសទោស ការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬ ពិន័យជាប្រាក់បានទេ។ រីឯការស្តីពីបន្ទោសដែលតុលាការបានជំនួសឲ្យមូលទោស ក៏មិនអាចប្រកាសទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់បានទេ ។

[181] យោងទៅតាមមាត្រា ៩៩ នៃក្រមព្រហ្មទណ្ឌ, ការប្រកាសទោសបន្ថែមលើមូលទោស កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស។

[182] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ២៨។

[183] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៣៥។

[184] ក្រមព្រហ្មទណ្ឌ, មាត្រា ៥៥ ។

[185] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ២៨។

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុ នៃការរឹបអូសវត្ថុតាងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន តទៅហៅថា "ទ្រព្យសម្បត្តិរឹបអូស" រួមមាន ៖[186]

- ចលនទ្រព្យ ៖ បរិក្ខារផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យបច្ចេកទេសផ្សេងៗ, យានយន្ត មធ្យោបាយធ្វើដំណើរ និងគ្រឿងចក្រ និងសង្ហារឹម សម្ភារៈ
- អចលនទ្រព្យ ៖ ដី អាគារ ទ្រព្យសម្បត្តិដែលភ្ជាប់នឹងអាគារ
- ទ្រព្យជារតនវត្ថុ និងទ្រព្យដទៃទៀត ៖ ក្រោយពីមានសាលក្រមស្ថាពររបស់តុលាការបាន បង្គាប់ជាទ្រព្យសម្បត្តិរដ្ឋ ។

**កថាខណ្ឌទី១ ការរឹបអូសបំផ្លាញចោល**

ក្រោយពីបានចាប់យក និងក្រោយពីបានដកយកសំណាកក្នុងបរិមាណគ្រប់គ្រាន់ដើម្បីរក្សាទុកសម្រាប់ដំណើរការនីតិវិធី គ្រឿងញៀនទាំងនោះត្រូវរឹបអូសជាបន្ទាន់ និងត្រូវបានចាត់ចែងដូចខាងក្រោម ៖

- ប្រគល់ឪសថដែលមានសារធាតុញៀន ដែលអាចប្រើប្រាស់បានឲ្យទៅក្រសួងសុខាភិបាល
- ប្រគល់គ្រឿងញៀនដែលអាចប្រើប្រាស់ក្នុងឧស្សាហកម្មឪសថ ឬប្រើប្រាស់ក្នុងវិស័យផ្សេងទៀតឲ្យទៅក្រសួងសុខាភិបាល ឬក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមមុខងារប្រើប្រាស់នៃគ្រឿងញៀននោះ
- បំផ្លាញចោលនូវគ្រឿងញៀនដែលគ្មានប្រយោជន៍ក្នុងការប្រើប្រាស់ ។ ការបំផ្លាញចោលទាំងស្រុងនូវគ្រឿងញៀន ត្រូវធ្វើឲ្យបានឆាប់រហ័ស និងតាមមធ្យោបាយសមស្របបំផុតនៅចំពោះមុខគណៈកម្មការដែលត្រូវបង្កើតឡើងដោយប្រកាសរបស់មន្ត្រីក្រសួងយុត្តិធម៌ ។

ការរឹបអូសដើម្បីប្រគល់ ឬបំផ្លាញចោល ជាសមត្ថកិច្ចរបស់ ៖

- ព្រះរាជអាជ្ញា នៅក្នុងដំណាក់កាលស៊ើបអង្កេត

[186] ប្រកាសរួមស្តីពីការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន, លេខ ៥៧៦ សហវ.ប្រក, ១៦ ឧសភា ២០១៦, ប្រការ២។ ក្រមព្រហ្មទណ្ឌ, មាត្រា ៦២ និងមាត្រា ៦៣។

- យុត្តាធិការស៊ើបសួរ នៅក្នុងដំណាក់កាលស៊ើបសួរ
- យុត្តាធិការជំនុំជម្រះ នៅក្នុងដំណាក់កាលជំនុំជម្រះ ។[187]

**កថាខណ្ឌទី២ ការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ**

ចៅក្រមនឹងចេញសេចក្តីសម្រេចមួយ ដើម្បីបញ្ជាក់ពីប្រភេទវត្ថុតាងដែលអាចរឹបអូសចូលជាសម្បត្តិរបស់រដ្ឋបាន កាលបើការរឹបអូសក្លាយជាស្ថាពរ វត្ថុដែលរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋ ។[188]

- ផលនៃគ្រឿងញៀន ៖ ផលនៃគ្រឿងញៀនដែលបំប្លែងជា រថយន្ត ម៉ូតូ គ្រឿងសង្ហារិម និងសម្ភារៈដទៃទៀតជាច្រើន ។
- ការបញ្ចូលនៅក្នុងបេឡាមូលនិធិ ៖ ទ្រព្យ និងវត្ថុដទៃទៀត ដែលបានមកដោយការអនុវត្តសេចក្តីសម្រេចរឹបអូសរបស់តុលាការពីជំនួញគ្រឿងញៀនខុសច្បាប់អាចត្រូវបានបញ្ចូលទៅក្នុងបេឡាមូលនិធិ នៃ អ.ជ.ប.គ.ញ ។[189]

ចំណូលដែលប្រមូលបានជាសាច់ប្រាក់ បានមកពីការចាត់ចែងទ្រព្យសម្បត្តិ ក្រោយពីមានសេចក្តីសម្រេចស្ថាពររបស់សាលាជម្រះក្តី ដែលទ្រព្យសម្បត្តិទាំងនោះត្រូវបានរឹបអូសពីបទល្មើសគ្រឿងញៀន រួមទាំងផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសគ្រឿងញៀន និងប្រាក់ដែលបានមកពីការលក់វត្ថុ ការចាត់ចែង ឬទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ត្រូវបានកត់ត្រាទាំងស្រុងជាចំណូលថវិការដ្ឋ ។[190]

**កថាខណ្ឌទី៣ ការប្រគល់វត្ថុចាប់យកទៅម្ចាស់ដើមវិញ**

វត្ថុតាងដែលចាប់បាន និងមិនមានការពាក់ព័ន្ធត្រូវតែធ្វើការប្រគល់ឲ្យទៅម្ចាស់ដើមវិញ ដើម្បីអាចយកទៅប្រើប្រាស់ និងចាត់ចែងចំពោះសិទ្ធិលើវត្ថុដែលមាន ។ វត្ថុដែលរឹបអូសត្រូវប្រគល់

---

[187] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៨៥។

[188] ក្រមព្រហ្មទណ្ឌ, មាត្រា ១៧៨។

[189] ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា ១០។

[190] ប្រកាសរួមស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីការបង្ក្រាបបទល្មើសគ្រឿងញៀន, លេខ ៥៧៧ សហវ.ប្រក, ១៦ ឧសភា ២០១៦, ប្រការ ១។

អោយម្ចាស់ដើមវិញ គឺជាវត្ថុដែលពុំមានការពាក់ព័ន្ធក្នុងបទល្មើស ហើយតុលាការចេញសេចក្តីសម្រេចប្រគល់ឲ្យម្ចាស់កម្មសិទ្ធិយកទៅប្រើប្រាស់វិញ ។[191] ជាទូទៅ វត្ថុដែលត្រូវបានប្រគល់ត្រឡប់មកវិញ លុះត្រាតែមានការស្នើសុំពីម្ចាស់ដើម ឬករណីដែលមានការស្នើសុំពីតតិយជនដែលមានការពាក់ព័ន្ធទើបតុលាការធ្វើសេចក្តីសម្រេចក្នុងការប្រគល់ឲ្យត្រឡប់ទៅវិញ ។[192]

ជាការពិតណាស់ ចំពោះវត្ថុដែលមិនជាប់ពាក់ព័ន្ធនឹងបទល្មើស ម្ចាស់ដើមអាចធ្វើការទាមទារវត្ថុនោះបាននៅគ្រប់ពេល នៃដំណាក់កាលនីតិវិធីនីមួយៗ ។ នៅក្នុងដំណាក់ព្រះរាជអាជ្ញា ម្ចាស់ដើមដែលមានបំណងធ្វើការទាមទារវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន អាចធ្វើការស្នើសុំទៅព្រះរាជអាជ្ញាតាមរយៈពាក្យស្នើសុំបាន ព្រោះថាព្រះរាជអាជ្ញាជាអ្នកមានសមត្ថកិច្ចបង្គាប់ឲ្យប្រគល់វត្ថុដែលចាប់បាននៅក្នុងពេលស៊ើបអង្កេតទៅម្ចាស់ដើមវិញ ប្រសិនបើវត្ថុទាំងនោះពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតទេនោះ ហើយប្រសិនបើកម្មសិទ្ធិលើវត្ថុនោះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ ។ ក្នុងករណីមិនព្រមប្រគល់ឲ្យវិញទេ អ្នកប្តឹងសុំអាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន ។ ប៉ុន្តែ វត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬចំពោះទ្រព្យសម្បត្តិ ដូចជាអាវុធ ឬជាតិផ្ទុះព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ មិនអាចប្រគល់ឲ្យវិញបានទេ ។ វត្ថុទាំងនោះ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ឬត្រូវបំផ្លាញចោល ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា គ្មានសមត្ថកិច្ចក្នុងការប្រគល់ទេ កាលណាមានការចោទប្រកាន់ធ្វើឡើង នៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា នៅតែមានសមត្ថកិច្ច កាលណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចលើកលែងចោទប្រកាន់ជាស្ថាពរ ។[193] មួយវិញទៀត កាលបើតុលាការដែលទទួលពាក្យប្តឹងបានចេញសេចក្តីសម្រេចមួយជាស្ថាពរ ហើយពុំបានសម្រេចសេចក្តីលើការប្រគល់វត្ថុដល់ម្ចាស់ដើមវិញទេនោះព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា ក៏មានសមត្ថកិច្ចទៅតាមករណីនីមួយៗ ដើម្បីសម្រេចដោយឯកឯងលើពាក្យសុំឲ្យមានការប្រគល់វត្ថុដល់ម្ចាស់ដើមវិញនេះ នៅពេលដែលកម្មសិទ្ធិនៃវត្ថុនោះពុំមានការជំទាស់អ្វីជាប្រាកដប្រជាទេ ។[194]

[191] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣៥៤។

[192] ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, ៣១។

[193] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១១៩។

[194] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១២០។

មួយវិញទៀត ប្រសិនបើសំណុំរឿងត្រូវបានបញ្ជូនទៅចៅក្រមស៊ើបសួរ នោះម្ចាស់ដើមអាចធ្វើការដាក់ពាក្យសុំទៅចៅក្រមស៊ើបសួរដើម្បីស្នើសុំវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនបាន ព្រោះថា នៅពេលដែលចៅក្រមស៊ើបសួរមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ ។ ចៅក្រមស៊ើបសួរ សម្រេចតាមដីកាដែលមានសំអាងហេតុក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា ។ ដីកាសម្រេច ត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនបើមាន ។ មិនគួរប្រគល់សងទៅឲ្យអ្នកប្តឹងសុំទេ កាលណាវិធានការនេះ អាចបង្កជាឧបសគ្គដល់ការសំដែងឲ្យឃើញការពិត ។ វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់មិនស្របច្បាប់ មិនអាចប្រគល់សងទៅឲ្យសាមីខ្លួនបានទេ ។ វត្ថុទាំងនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ ។[195]

[195] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៦១ និងមាត្រា ២៨៨។

# សេចក្តីសន្និដ្ឋាន

ដូចដែលបានរៀបរាប់មកខាងលើ យើងឃើញថា បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាបទល្មើសដែលពិបាកនឹងធ្វើការបង្ក្រាបដើម្បីឈានទៅរកការចាប់បានទាំងជនល្មើស និងគ្រឿងញៀន ហើយបទល្មើសនេះ មិនត្រឹមតែធ្វើឲ្យប៉ះពាល់ដល់សុខភាពបុគ្គលប៉ុណ្ណោះទេប៉ុន្តែថែមទាំងជះឥទ្ធិពលយ៉ាងខ្លាំងដល់សង្គមជាតិទាំងមូលផងដែរ ។ ដោយពិនិត្យឃើញការប៉ះពាល់យ៉ាងខ្លាំងបែបនេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតស្ថាប័នប្រយុទ្ធប្រឆាំងគ្រឿងញៀនគ្រប់លំដាប់ថ្នាក់ ដើម្បីធ្វើការងារប្រយុទ្ធប្រឆាំងនឹងបទល្មើសគ្រឿងញៀននៅកម្ពុជា ស្ថាប័នទាំងនោះរួមមាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានអគ្គលេខាធិការដ្ឋានជាសេនាធិការ និងមានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ជាខ្សែបណ្តោយ ដែលមានតួនាទីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿង, ការិយាល័យប្រឆាំងបទល្មើសគ្រឿងញៀន នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលមានសមត្ថកិច្ចបង្ក្រាបបទល្មើសគ្រឿងញៀនទូទៅប្រទេសកម្ពុជា, មន្ទីរប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិដែលជាស្ថាប័នថ្នាក់ជាតិក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន និង សម្របសម្រួលជាមួយព្រះរាជអាជ្ញាតុលាការ សំដៅធានាការអនុវត្តនីតិវិធីកិច្ចប្រតិបត្តិការ និងការអនុវត្តសាលក្រម សាលដីកា, និងការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្តដែលជាស្ថាប័នថ្នាក់ក្រោមជាតិក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ។

ជាការពិតណាស់ ទោះបីជាមានស្ថាប័នជាច្រើនក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀនក៏ដោយក៏ការចុះបង្ក្រាប និងការកសាងសំណុំរឿងទៅតុលាការ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ដូចគ្នាផងដែរ ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានធ្វើការបែងចែកចំណាត់ការសំណុំរឿងជា ៤ ដំណាក់កាលគឺ ដំណាក់ទី១ ជាដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលក្នុងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀនមន្ត្រីនគរបាលយុត្តិធម៌អាចចាប់បានជា បទល្មើសជាក់ស្តែង ឬមិនជាក់ស្តែង ឬដោយការប្រើប្រាស់វិធីសាស្ត្រ តាមរយៈការប្រគល់ដោយមានការឃ្លាំមើល និង ការញុះញង់ឲ្យលក់គ្រឿងញៀន ។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការចាប់បានជាបទល្មើសជាក់ស្តែង ឬដោយការប្រើប្រាស់វិធីសាស្ត្រតាមរយៈការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់គ្រឿងញៀនជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តនីតិវិធីតាមរយៈការស៊ើបអង្កេតបទ

ល្មើសជាក់ស្តែង ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។ មួយវិញទៀតប្រសិនបើបទល្មើសគ្រឿងញៀននោះមិនជាក់ស្តែងទេនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តនីតិវិធីតាមរយៈការស៊ើបអង្កេតបឋមដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

ដំណាក់កាលទី២ គឺជាដំណាក់កាលចោទប្រកាន់របស់ព្រះរាជអាជ្ញា ។ បន្ទាប់ពីការស៊ើបអង្កេតត្រូវបានបញ្ចប់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿង និងជនសង្ស័យទៅព្រះរាជអាជ្ញាដើម្បីឲ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ។ ជាទូទៅព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់បានតាមបីវិធី ដូចជា (១)ការប្តឹងទៅចៅក្រមស៊ើបសួរ, (២)ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និង(៣)ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។ ប៉ុន្តែ ចំពោះបទជួញដូរដោយខុសច្បាប់នូវសារធាតុនេះ ព្រះរាជអាជ្ញាមិនអាចចោទប្រកាន់តាមការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ឬ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមបានទេ ព្រោះថាលក្ខខណ្ឌនៃវិធីទាំងពីរនេះមិនត្រូវបានបំពេញ ។ ដូច្នេះ បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ត្រូវបានចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ ពីព្រោះបទល្មើសនេះមានភាពស្មុគស្មាញ និងតម្រូវឲ្យធ្វើកោសលវិច័យចំពោះសារធាតុដែលមានតម្រុយថាជាគ្រឿងញៀនខុសច្បាប់ ។

ដំណាក់កាលទី៣ គឺជាដំណាក់កាលចៅក្រមស៊ើបសួរ ដែលការស៊ើបសួរត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ មិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានឡើយ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ ។ នៅពេលដែលជនត្រូវចោទ ត្រូវបានព្រះរាជអាជ្ញាប្តឹងតាម រយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវធ្វើការស្រាវជ្រាវដូចតទៅ ដាក់បុគ្គលនោះឲ្យស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈ ជាចារី ជាអ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត, ធ្វើការសួរចម្លើយជនត្រូវចោទ, ធ្វើការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន, ធ្វើការស៊ើបសួររកបក្ខពួក និងធ្វើកោសលវិច័យនូវសារធាតុដែលមានតម្រុយថាជាគ្រឿងញៀនខុសច្បាប់ ។ បន្ទប់ពីចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរត្រូវបិទការស៊ើបសួរ ដោយធ្វើការជូនដំណឹងទៅព្រះរាជអាជ្ញា , មេធាវី និងជនត្រូវចោទ អំពីការបិទការស៊ើបសួរ ។ បន្ទាប់ពីពីរថ្ងៃនៃការជូនដំណឹងបិទស៊ើបទៅព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាពិនិត្យដើម្បីអោយព្រះរាជអាជ្ញា សម្រេចអោយស៊ើបសួរបន្ថែមទៀត ឬធ្វើការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងចោទប្រកាន់ តាមរ

យៈដីកាសន្និដ្ឋានស្ថាពរ ។ តាមរយៈដីកាសន្និដ្ឋានស្ថាពរ ចៅក្រមស៊ើបសួរ នឹងត្រូវបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់ ។

និងដំណាក់ទី៤ គឺជាដំណាក់កាលជំនុំជម្រះ ដែលជាដំណាក់កាលចុងក្រោយដែលជនជាប់ចោទនឹងត្រូវបានជំនុំជម្រះនៅចំពោះមុខចៅក្រមជំនុំជម្រះ ដែលចាត់តាំងដោយប្រធានតុលាការ ។ ជនជាប់ចោទ នឹងត្រូវបានកោះហៅអោយចូលមកសវនាការនៅកាលបរិច្ឆេទកំណត់ ។ នៅពេលសវនាការមានការប្រព្រឹត្តទៅជាបន្តបន្ទាប់ដូចជា ការពិភាក្សាដេញដោល និងការកំណត់អំពីការប្រកាសសាលក្រម ។

សរុបសេចក្តីមក ដោយគោរពនូវ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ និងកតិកាសញ្ញា និង អនុសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស ការកំណត់អំពីដំណាក់កាលទាំងបួនខាងលើនេះពិតជាមានសារៈសំខាន់ ព្រោះថាគ្មានជនណាម្នាក់ត្រូវការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយគ្មានការអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ទេ ។ ជនគ្រប់រូបត្រូវបានធានាអោយមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ និងទទួលបានការជំនុំជម្រះដោយយុត្តិធម៌ពីស្ថាប័នតុលាការ ។ ដូច្នេះ មន្ត្រីអនុវត្តច្បាប់ទាំងអស់ត្រូវអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនអោយបានត្រឹមត្រូវតាមច្បាប់ បើមិនដូច្នេះទេ ការងាររបស់ខ្លួននឹងក្លាយជាមោឃៈ ហើយពេលខ្លះនិងអាចត្រូវបានពិន័យ និងផ្តន្ទាទោសថែមទៀតផង ។

# អនុសាសន៍

ជាចុងក្រោយ ដើម្បីចូលរួមក្នុងការកាត់បន្ថយ បង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនគ្រប់ប្រភេទនៅកម្ពុជា ក៏ដូចជាធ្វើយ៉ាងណាអោយកម្ពុជាជាប្រទេសគ្មានគ្រឿងញៀន និងរក្សាគ្រួសារនីមួយៗជា គ្រួសារស្អាតស្អំគ្មានគ្រឿងញៀន តាមទស្សនវិស័យ *"ចូលរួមទាំងអស់គ្នាដើម្បីជីវិត និងសហគមន៍គ្មានគ្រឿងញៀន"* នាងខ្ញុំស្នើនូវអនុសាសន៍ចំនួនបីចំណុច ដូចខាងក្រោម៖

— **ពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** ៖ ការពិតណាស់តាមរយៈរបាយការណ៍ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជាឆ្នាំ២០១៦ ឃើញថាបទល្មើសគ្រឿងញៀនមានការកើនឡើង ៣៨,៧១% បើធៀបនឹងឆ្នាំ២០១៥គន្លងទៅ ដូច្នេះ យើងអាចសន្និដ្ឋានបានថា បទល្មើសគ្រឿងញៀននៅកម្ពុជាបច្ចុប្បន្ន នៅតែបន្តមានការកើតឡើងជាលំដាប់ ដូច្នេះ រាជរដ្ឋាភិបាលគួរតែពង្រឹងការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបន្តការចេញបទបញ្ជាសម្រាប់ឆ្នាំ២០១៨ និងឆ្នាំបន្តបន្ទាប់ទៀត ស្ដីពីវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅតាមរាជធានី-ខេត្ត និងបន្តអនុវត្តបទបញ្ជានេះអោយមានប្រសិទ្ធភាព ។

— **ជំរុញអោយមានការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ សង្កាត់ ឃុំ** ៖ បទល្មើសគ្រឿងញៀន អាចកើតឡើងគ្រប់ទីកន្លែង ជាពិសេសតំបន់ដែលងាយរងគ្រោះបំផុតគឺនៅតាមភូមិ ស្រុក ឃុំ សង្កាត់ នានា ដែលជនល្មើសប្រើប្រាស់តំបន់នោះជាកន្លែងដោះដូរគ្រឿងញៀន និងផលិតគ្រឿងញៀន ព្រោះថាតំបន់នោះមិនសូវមានការចាប់អារម្មណ៍ ពីប្រជាពលរដ្ឋ និងសមត្ថកិច្ច ។ តាមរយៈច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនមានតែនៅថ្នាក់រាជធានី-ខេត្ត តែប៉ុណ្ណោះ ដូច្នេះដើម្បី កាត់បន្ថយ បង្ការ និង បង្ក្រាបបទល្មើសគ្រឿងញៀនអោយមានប្រសិទ្ធភាពគ្រប់ទីកន្លែង រាជរដ្ឋាភិបាល គួរតែជំរុញអោយមានការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់សង្កាត់ ឃុំ បន្ថែមទៀត ។

— **ផ្ដល់កញ្ចប់ថវិការ មធ្យោបាយ និងសម្ភារ សម្រាប់បម្រើឲ្យកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនគ្រប់ស្ថាប័នពាក់ព័ន្ធ** ៖ បញ្ហាថវិការ មធ្យោបាយ និងសម្ភារ សម្រាប់បម្រើឲ្យកិច្ច

ប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន គឺជាបញ្ហាចំបងមួយដែលស្ថាប័នពាក់ព័ន្ធទាំងអស់កំពុងជួបប្រទះបច្ចុប្បន្ន ព្រោះថានៅតាមអង្គភាពមួយចំនួន នៅមិនទាន់មានសម្ភារគ្រប់គ្រាន់ក្នុងការធ្វើការពិសោធន៍នូវសារធាតុញៀននៅឡើយ ឧទាហរណ៍៖ មន្ទីរប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ។ បច្ចុប្បន្ននេះ យើងមានតែមន្ទីរពិសោធន៍ នៅអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀនទេ ដែលអាចធ្វើការពិសោធន៍អំពីកម្រិតភាពសុទ្ធនៃសារធាតុញៀនបាន ។ ដូច្នេះ ដំណើរការស៊ើបអង្កេតបទល្មើសគ្រឿងញៀនរបស់អង្គភាពនៅតាមក្រុង-ខេត្តនានា ត្រូវចំណាយពេលច្រើន ព្រោះថាអាជ្ញាធរត្រូវផ្ញើនូវសារធាតុញៀនដែលចាប់បានទាំងនោះមកធ្វើការពិសោធន៍នៅមន្ទីរពិសោធន៍អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន រាជធានីភ្នំពេញ ។ ដូច្នេះ ដើម្បីដោះស្រាយនូវបញ្ហាខាងលើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ គួរតែធ្វើការអនុញ្ញាតឲ្យធ្វើការចាត់ចែងតាមរយៈការលក់នូវទ្រព្យសម្បត្តិដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស និងទ្រព្យសម្បត្តិដែលកើតចេញពីបទល្មើសគ្រឿងញៀន ដោយពុំចាំបាច់មានសេចក្តីសម្រេចជាស្ថាពរទេ ។

# ឯកសារយោង

## ច្បាប់

- ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។
- ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៦ មិថុនា ២០១៣។
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, លេខ នស/រកម/០១១២/០០១, ០២ មករា ២០១២។

## ព្រះរាជក្រឹត្យ

- ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, លេខ នស/រកត/០៩៩៥/៦៥, ០៧ កញ្ញា ១៩៩៥។
- ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, លេខ នស/រកត/០៥០៩/៦០៨, ៣០ ឧសភា ២០០៩។

## អនុក្រឹត្យ

- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, លេខ ១៣ អនក្រ.បក, ២២ កុម្ភៈ ២០០៧។
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ, លេខ ១០៩ អនក្រ.បក, ១៩ សីហា ២០១៥។

## សេចក្តីសម្រេច

- សេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀនរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលចូលជាធរមានថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០១២។
- សេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀនលេខ ៣៤ កយ.សសរ/១៧ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៧ របស់ទីស្តីការក្រសួងយុត្តិធម៌។

## ប្រកាស

- ប្រកាសរួមស្តីពីការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន, លេខ ៥៧៦ សហវ.ប្រក, ១៦ ឧសភា ២០១៦។
- ប្រកាសរួមស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីការបង្ក្រាបបទល្មើសគ្រឿងញៀន, លេខ ៥៧៧ សហវ.ប្រក, ១៦ ឧសភា ២០១៦។
- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត, លេខ ១៣៣០០ ប្រក, ២៩ វិច្ឆិកា ២០១៦។
- ប្រកាសស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់ដោយខុសច្បាប់, លេខ ០៩.កយ.ប្រក/០៦, ០៨ កុម្ភៈ ២០០៦។

## បទបញ្ជា

- បញ្ជាស្តីពីការពង្រឹងវិធានប្រយុទ្ធប្រឆាំងគ្រឿងញៀន, លេខ ០១បប, ០២ កុម្ភៈ ២០១៦។

## ផែនការ

- ផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ រយៈពេល៦ខែ (ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧), លេខ ០១ផក, ១៣ ធ្នូ ២០១៦។

## របាយការណ៍

- របាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០១៦ និងទិសដៅការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០១៧ (ថ្ងៃទី០១ ខែធ្នូ ២០១៥ ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦), លេខ ០០៧ របក អ.ជ.ប.គ.ញ, ២៧ មេសា ឆ្នាំ ២០១៧។

## សៀវភៅ


- កញ្ញា អ៊ី ម៉ាណូកា. ២០១៦. ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន. (សីហា): ៥។

– ឧត្តមសេនីយឯក វេជ្ជ.មាស វិរិទ្ធ. ការយល់ដឹងពីលក្ខណៈបច្ចេកទេសទាក់ទងនឹងបទល្មើសគ្រឿងញៀន។
– កុយ នាម, *ដំណើរការក្តីនៅក្នុងតុលាការ* (ភ្នំពេញ, ១៩៩៨)។
– អំណោយស្ថានទូតបារាំង, *នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល* (២០០៩)។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការ
អមសាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ:
ចុះថ្ងៃទី ខែ ឆ្នាំ
លេខ៖ ... ប.វ.ត

## កំណត់ហេតុទទួលវត្ថុចាប់យក(១)

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែកុម្ភៈ ថ្ងៃទីដប់ វេលាម៉ោង ប្រាំបួន និងសូន្យ នាទីព្រឹកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានីភ្នំពេញ។

យើង ក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក ជាអ្នកទទួល

លោក ជាមន្ត្រីនគរបាលយុត្តិធម៌ មន្ទីរប្រឆាំងគ្រឿងញៀន ជាអ្នកប្រគល់

ដោយមានការចូលរួមពីជនសង្ស័យឈ្មោះ ភេទប្រុស អាយុ ២៦ឆ្នាំ និងឈ្មោះ បញ្ញា ភេទប្រុស អាយុ ២០ឆ្នាំ ។

ពាក់ព័ន្ធករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃ ។

បានពិនិត្យផ្ទៀងផ្ទាត់វត្ថុចាប់យកតាមកំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី ខែ ឆ្នាំ របស់សមត្ថកិច្ច ដែលទាក់ទងនិងសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ ឃើញដូចខាងក្រោម៖

☐អចលនវត្ថុ ☐ប្រាក់ ☐ គ្រឿងញៀន ☐ អាវុធ/គ្រឿងផ្ទុះ
☐ រថយន្ត ☐ម៉ូតូ ☐ កុំព្យូទ័រ/ទូរទស្សន៍ ☐ ទូរស័ព្ទ ☐ ផ្សេងៗ

១-ស្រោមសំបុត្រពណ៌សបិទជិត សរសេរថា ក្រាមពណ៌សថ្លា ទម្ងន់ ០,៤៨ក្រាម មានស្នាមមេដៃឈ្មោះ និងឈ្មោះ និងហត្ថលេខារបស់សមត្ថកិច្ចចូលរួម ។

២-ទូរស័ព្ទដៃម៉ាកណូគាចំនួន ០១ ចាស់ ។

៣-ឧបករណ៍សម្រាប់ជក់គ្រឿងញៀនមួយចំនួន ។

យើងធ្វើកំណត់ហេតុនេះ ដើម្បីទុកជាសំអាងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃ ខែ ឆ្នាំ២០១៧ តាមផ្លូវច្បាប់តទៅ។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង ប្រាំបួន និងដប់ម្ភៃ នាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល។

អ្នកប្រគល់ ក្រឡាបញ្ជី ជនសង្ស័យ

ឧ.ព្រះរាជអាជ្ញា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី ខែ ឆ្នាំ

# កំណត់ហេតុសួរចម្លើយ

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែកុម្ភៈ ថ្ងៃទី ដប់ វេលាម៉ោង ដប់ និងសូន្យនាទី

**យើង តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

ដោយមានលោក ជាក្រឡាបញ្ជីអមផងបានសួរកត់យកចម្លើយរបស់ឈ្មោះ ជា ជនសង្ស័យ ដោយមិនមានជាមេធាវីការពារក្តីទេ។

សួរ/ឆ្លើយ ៖ ខ្ញុំបាទឈ្មោះ អាយុ ២៦ឆ្នាំ (១៩៩១) ជនជាតិ ខ្មែរ , កើតនៅភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌមានជ័យ ក្រុងភ្នំពេញ , ទីលំនៅបច្ចុប្បន្ននៅភូមិមិត្តភាព សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ , មុខរបរ , ឪពុកឈ្មោះ "រស់" , ម្តាយឈ្មោះ "រស់" , នៅលីវ , ជានីតិជន , ទោសពីមុនគ្មាន។

សួរ/ឆ្លើយ៖ ខ្ញុំបាទសូមជម្រាបជូនលោកព្រះរាជអាជ្ញាមេត្តាជ្រាបថា ខ្ញុំសូមទទួលស្គាល់ចម្លើយរបស់ខ្ញុំនៅសមត្ថកិច្ចចុះថ្ងៃទី ខែ ឆ្នាំ ទាំងស្រុង។ ខ្ញុំទើបតែជួយលក់គ្រឿងញៀនឈ្មោះ បានមួយអាទិត្យប៉ុណ្ណោះ ហើយមួយថ្ងៃឈ្មោះ អោយប្រាក់ខ្ញុំចំនួន មួយម៉ឺនរៀលទេ។ ខ្ញុំចេះប្រើប្រាស់គ្រឿងញៀន។

សួរ/ឆ្លើយ៖ ខ្ញុំសុំសំណូមពរលោកព្រះរាជអាជ្ញាវងមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំផង ហើយខ្ញុំសន្យាថានឹងឈប់លក់គ្រឿងញៀនហើយ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានឲ្យស្តាប់ សាមីខ្លួនឆ្លើយថាត្រឹមត្រូវហើយៗ សុខចិត្តចុះហត្ថលេខាឬផ្តិតម្រាមដៃជាមួយយើង។

**អ្នកឆ្លើយ ក្រឡាបញ្ជី ព្រះរាជអាជ្ញារង**

L.10

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុស្តាប់ចម្លើយជនត្រូវចោទ

សំណុំរឿងព្រហ្មទណ្ឌ

លេខ

ចុះថ្ងៃទី

សំណុំរឿងស៊ើបសួរ

លេខ

ចុះថ្ងៃទី

(មាត្រា ១៤៥ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែកុម្ភៈ ថ្ងៃទីដប់ វេលាម៉ោង ដប់ប្រាំ នឹងសាមសិបនាទី។

លោក ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

បានមកបង្ហាញខ្លួនក្នុងនាមជនត្រូវចោទនៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើងជនដែលមានសញ្ញាណ ដូចខាងក្រោម៖

ឈ្មោះ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ រកកៀន ស្វាយ ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ ម្តាយឈ្មោះ នៅលើវ ជាអនីតិជន ។

អនីតិជន☐ បុនីតិជន☑

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

ប្រវត្តិការផ្តន្ទាទោសដោយតុលាការ .....គ្មាន......

☑ជននេះ៖ ☑ចេះនិយាយ ☑ចេះអាន ☑ចេះសរសេរអក្សរខ្មែរ

☐ជននេះ៖ ☐មិនចេះនិយាយ ☐មិនេចះអាន ☐មិនេចះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ចុះថ្ងៃទី ខែ ឆ្នាំ

ដែលជាហេតុនាំឲ្យជននេះ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ និង ☐ការឃុំខ្លួនបណ្តោះអាសន្នតាមដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ....................ចុះថ្ងៃទី..........................................................។

ជនត្រូវចោទអមដោយលោកមេធាវី .................. ជាមេធាវីការពារសិទ្ធិ។

យើងបានសួរចម្លើយឈ្មោះនេះ ហើយឈ្មោះនេះបានឆ្លើយប្រាប់យើងដូចខាងក្រោមថា៖

សួរ ៖ តើលោកយល់អំពីសិទ្ធិទាំងឡាយជុំវិញការចោទប្រកាន់លើរូបលោក ដែលយើងបានរៀបរាប់ប្រាប់ទាំងអស់នេះដែរ ឬទេ?

ឆ្លើយ៖ ខ្ញុំយល់អំពីសិទ្ធិទាំងអស់នេះ ហើយចម្លើយដែលខ្ញុំឆ្លើយនៅអយ្យការនោះ គឺខ្ញុំរក្សាទុកជាបានការដដែល។

កាលពីថ្ងៃទី ខែ ឆ្នាំ ខ្ញុំបាទមិនបានជួញដូរគ្រឿងញៀនទេ គឺខ្ញុំបាទកំពុងតែដេកក៏ឮសំឡេងឡូឡាខ្ញុំក៏ចុះពីផ្ទះមកក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនខ្ញុំតែម្តង រួចខាងសមត្ថកិច្ចក៏បានចូលឆែកឆេរនៅក្នុងផ្ទះរបស់ខ្ញុំរកមិនឃើញអ្វីនោះទេ។ ខ្ញុំបាទចេះប្រើប្រាស់គ្រឿងញៀនរយៈពេល០៤ខែមកហើយ ចំពោះថ្នាំញៀនខ្ញុំបាទទិញពីឈ្មោះ ដែលរស់នៅភូ

បញ្ចប់កំណត់ហេតុនៅម៉ោង ដប់ប្រាំមួយ នឹងហាសិបប្រាំនាទី ថ្ងៃ ខែ ឆ្នាំដដែល។

☐យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

☒បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើងក្រឡាបញ្ជី និងអ្នកបកប្រែ។

**ជនត្រូវចោទ** **មេធាវី** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុស្តីពី
# ការបង្ហាញខ្លួនលើកដំបូង

សំណុំរឿងព្រហ្មទណ្ឌ
លេខ
ចុះថ្ងៃទី
សំណុំរឿងស៊ើបសួរ
លេខ
ចុះថ្ងៃទី

(មាត្រា ១៤៣ មាត្រា ១៤៤ មាត្រា ២៤០ និងមាត្រា ២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែមករា ថ្ងៃទីដប់ វេលាម៉ោង ដប់ប្រាំមួយ នឹងសូន្យនាទី។

លោក ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅ

ទីលំនៅបច្ចុប្បន្ននៅ ឪពុកឈ្មោះ

ម្តាយឈ្មោះ **នៅលើវ** ជាអនីតិជន ។

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

ប្រវត្តការផ្តន្ទាទោសដោយតុលាការ ..................គ្មាន................

☑ជននេះ ☑ចេះនិយាយ ☑ចេះអាន ☑ចេះសរសេរអក្សរ

☐ជននេះ មិនចេះនិយាយ ☐មិនចេះអាន ☐មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលជាហេតុនាំឲ្យមានការបង្ហាញជននេះនៅចំពោះមុខយើង ព្រមទាំងប្រាប់ជននេះឲ្យដឹងអំពីបទចោទប្រកាន់ចំពោះ រឿងរ៉ាវដូចខាងក្រោម៖

ពីបទ *ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ និងមាត្រា ៤៥* នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ខែ ឆ្នាំ

☑យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់ជននេះឲ្យស្ថិតនៅក្រោមការពិនិត្យ

☑ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឲ្យដឹង។

☐ចំពោះតែអង្គហេតុដែលរៀបរាប់ខាងក្រោម ដែលយើងបញ្ជាក់ប្រាប់ជននេះ អំពីឈ្មោះ នៃបទល្មើសគឺបទ

.....................................................................................................................................

.....................................................................................................................................

យើងបានប្រាប់ដល់ជនត្រូវចោទអំពីសិទ្ធិក្នុងការសុំឲ្យយើងធ្វើកិច្ចស៊ើបសួរមួយ ឬច្រើន ឬក៏អាចធ្វើពាក្យប្តឹងសុំមោឃភាព នៃកិច្ចស៊ើបសួរ ដោយផ្អែកតាមមូលដ្ឋាន នៃមាត្រា ២៥៣ ប្តឹងឧទ្ធរណ៍ តាមបញ្ញត្តិមាត្រា ២៦៧ នៅក្នុងពេល នៃដំណើរការ នៃការស៊ើបសួរ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

☐យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការជ្រើសរើសមេធាវីសម្រាប់នីតិវិធីបន្ទាប់មកទៀត ហើយ

អាសយដ្ឋាននេះ ☐ អាសយដ្ឋានផ្ទាល់ខ្លួន

ប្រសិនបើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ នឹងបើសិនជាមានសំណើសុំយើងនឹងចាត់តាំងមេធាវីមួយរូបជូន(សម្រាប់តែក្នុងករណីដែលជនត្រូវចោទមិនបានជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឲ្យចាត់តាំងមេធាវីឲ្យ)។

+ជនត្រូវចោទបានប្រកាសប្រាប់ថា៖

☐ខ្ញុំជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង

☐ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ

☑ខ្ញុំបដិសេធជំនួយពីមេធាវី

☑យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់អាចសុំឲ្យបិទការស៊ើបសួរបាននៅក្រោយពេលផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

☑យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះយើងសម្រេចឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន។

យើងបានជូនដំណឹងដល់ជននេះថា យើងគ្រោងនឹងដាក់ជននេះឲ្យនៅក្រោមការត្រួតពិនិត្យ ចំពោះរឿងរ៉ាវដែលយើងទើបនឹងរៀបរាប់ឲ្យជននេះដឹងយ៉ាងច្បាស់។

☐លោក ......... ជាមេធាវី នៃជនត្រូវចោទដែលត្រូវបានកោះហៅ ............................ ហើយដើម្បីឲ្យលោក/លោកស្រីមេធាវី អាចត្រៀមរៀបចំ ការពារកូនក្ដីខ្លួនបាន។

☑យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើសពឹងមេធាវីដោយខ្លួនឯង ឬអាចសុំឲ្យគេចាត់តាំងមេធាវីណាម្នាក់ឲ្យរូបគាត់។

☑យើងបានប្រាប់ផងដែរដល់ជននេះថា ប្រសិនបើមិនធ្វើការជ្រើសរើសពឹងមេធាវីដោយខ្លួនឯងទេ មេធាវីមួយរូប នឹងត្រូវចាត់តាំងដោយឯកឯង ដោយសារតែជននេះជាអនីតិជន។

+ជននេះបានប្រកាសប្រាប់ថា៖

☐ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☐ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ

☑ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្ដល់ចម្លើយក៏បាន ឬអាចធ្វើសេចក្ដីប្រកាសផ្សេងៗ ឬអាចឲ្យយើងសួរចម្លើយក៏បាន។

ជននេះ បានប្រកាសប្រាប់ថា *ខ្ញុំបាទអាចឆ្លើយរឿងហេតុជូនតុលាការបាន*។

លោកមេធាវី .......... បានផ្ដល់សេចក្ដីកត់សម្គាល់ការពារថា .......................................... ។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះយើងសម្រេចដាក់គាត់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងប្រាប់ឲ្យគាត់ដឹងអំពីកាតព្វកិច្ចទាំងឡាយដែលគាត់ត្រូវគោរព។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចមិនខ្លួន(ឲ្យនៅក្រៅឃុំ)។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា៖

គាត់ត្រូវប្រកាសប្រាប់ពីអាសយដ្ឋានដែលអាចជាអាសយដ្ឋានផ្ទាល់ខ្លួន ឬជាអាសយដ្ឋានរបស់តតិយជនណាម្នាក់ ដែលទទួលបន្ទុកទទួលយកលិខិត ដែលបញ្ជូនទៅឲ្យគាត់ ប្រសិនបើគាត់អាចផ្ដល់ឲ្យភ្ជាប់នូវការព្រមព្រៀងជាលាយល័ក្ខណ៍អក្សររបស់តតិយជននោះ។

-អាសយដ្ឋានដែលត្រូវប្រកាសប្រាប់ត្រូវមាន..............................។

ជនត្រូវចោទបានប្រកាសអាសយដ្ឋានដូចខាងក្រោម៖

អាសយដ្ឋាននេះ: ☐ អាសយដ្ឋានផ្ទាល់ខ្លួន

សាលាដំបូងរាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុស្តីពី
# ការពិភាក្សាដេញដោលចំពោះមុខ

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

សំណុំរឿងព្រហ្មទណ្ឌ
លេខ
ចុះថ្ងៃទី
សំណុំរឿងស៊ើបសួរ
លេខ
ចុះថ្ងៃទី

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែកុម្ភៈ ថ្ងៃទីដប់ វេលាម៉ោង ដប់ប្រាំមួយ នឹងដប់ប្រាំនាទី។

លោក ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ចុះថ្ងៃទី ខែ ឆ្នាំ

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិមិត្តភាព ឃុំព្រែកឯង ស្រុកគៀនស្វាយ ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ ម្តាយឈ្មោះ នៅលីវ ជាអនីតិជន។

☑ ជននេះប្រកាសប្រាប់ថា ចេះអាន និងចេះសរសេរភាសាខ្មែរ។

☐ ជននេះប្រកាសប្រាប់ថា មិនចេះអាន និងមិនចេះសរសេរភាសាខ្មែរ។

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ *ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ និងមាត្រា ៤៥* នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ខែ ឆ្នាំ

☐ដោយមានលោកមេធាវី ...........ដែលជនត្រូវចោទបានជ្រើសរើសពឹងពាក់ដោយខ្លួនឯង ឬដែលត្រូវបានចាត់តាំងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានមកបង្ហាញនៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះមើលសំណុំរឿង និងបានធ្វើទំនាក់ទំនងដោយសេរីជាមួយ នឹងជនត្រូវចោទ នៅពេលបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខយើង។

យើងបានប្រាប់ដល់ជនត្រូវចោទថា៖

☑-យើងមានបំណងសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន។

☑-ជនត្រូវចោទអាចស្នើសុំពន្យាពេល ដើម្បីរៀបចំការពារខ្លួន។

☑-យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃនេះ។

☐-ជនត្រូវចោទមិនទាន់មានជំនួយពីមេធាវីនៅឡើយ ហើយយើងបានបញ្ជាក់ប្រាប់ថាជនត្រូវចោទមានសិទ្ធិទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯង ឬមេធាវី តាមការចាត់តាំង។

+ជនត្រូវចោទបានប្រកាសប្រាប់ថា៖

☑ ខ្ញុំបដិសេធជំនួយពីមេធាវី

☐ ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ

☐ ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☐ លោកមេធាវី .............. ត្រូវបានជូនដំណឹងដោយសាលាដំបូងរាជធានីភ្នំពេញអាចពិគ្រោះមើលសំណុំរឿងដែលទុកឲ្យគាត់ពិនិត្យ និងអាចសន្ទនាដោយសេរីជាមួយកូនក្តីរបស់គាត់។

ការពិភាក្សាដេញដោលចំពោះមុខទាក់ទង និងការឃុំខ្លួនបណ្ដោះអាសន្ន៖

☐ត្រូវបានធ្វើ

☐ត្រូវបានលើកទៅថ្ងៃទី.... ខែ.......ឆ្នាំ...........តាមសំណូមពររបស់.......................................

**តំណាងអយ្យការបានបង្ហាញនូវសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោម៖**

*តំណាងអយ្យការស្នើសុំឃុំខ្លួនជនត្រូវចោទរូបនេះជាបណ្ដោះអាសន្ន ដើម្បីបង្កា ឬបង្ក្រាបបទល្មើសកុំឲ្យកើតមានឡើងជាថ្មី និងធានារក្សាទុកជនត្រូវចោទជូនតុលាការ ចាត់ការតាមនីតិវិធី។*

**ជនត្រូវចោទបង្ហាញសេចក្តីសង្កេតរបស់ខ្លួន ដូចខាងក្រោម៖**

*សុំកុំឲ្យតុលាការធ្វើការឃុំខ្លួនខ្ញុំដោយហេតុ ខ្ញុំបាទមិនប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ខ្ញុំបានទីលំច្បាស់លាស់ មានមុខរបរច្បាស់ ។*

**លោកមេធាវី ................. បានបង្ហាញសេចក្តីសន្និដ្ឋានការពារកូនក្តីដូចខាងក្រោម៖**

☐យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន ដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួននៅថ្ងៃនេះ។

☑យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ជាមួយយើង និងក្រឡាបញ្ជី។

☐យើងបានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើងក្រឡាបញ្ជី និងអ្នកបកប្រែ។

| | | | | |
|---|---|---|---|---|
| **ជនត្រូវចោទ** | **មេធាវី** | **ក្រឡាបញ្ជី** | **តំណាងអយ្យការ** | **ចៅក្រមស៊ើបសួរ** |

ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ

# ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន[1]

ដោយ កញ្ញា អ៊ី ម៉ាណូកា [*]

## ចំណាប់អារម្មណ៍

*************

ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរនូវគ្រឿងញៀន គឺជាបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន[2] ដែលកំពុងតែរីករាលដាល និងកំពុងតែកកើតមានយ៉ាងច្រើន។ បទល្មើសនេះ បានបង្ក និងជម្រុញឲ្យមានអំពើល្មើសផ្សេងៗជាច្រើន ដូចជាអំពើលួច ឃាតកម្ម ជាដើម។[3] ជាតួលេខសិក្សាច្បាស់លាស់បានបង្ហាញឲ្យឃើញថា ឆ្នាំ២០១៦ នគរបាល និងកងរាជអាវុធហត្ថបង្ក្រាបបាន ៤.១៩១ករណី(បទល្មើសប្រើប្រាស់១.១១២ករណី) ចាប់ជនសង្ស័យសរុប៩.៨០២ករណី (អ្នកប្រើប្រាស់គ្រឿងញៀន ៣.៦១១នាក់)[4]។

បទល្មើសពិសេសនេះ ជាបទល្មើសដែលមានលក្ខណៈស្មុគស្មាញ និងដំណើរការនីតិវិធីច្រើនលំអិតមុនអាចចាប់បានអ្នកប្រព្រឹត្តអំពើល្មើស ប្រសិនជាប្រៀបធៀបជាមួយនឹងបទល្មើសធម្មតាដទៃទៀត។ លើសពីនេះ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនរបស់កម្ពុជា ត្រូវបានធ្វើវិសោធនកម្មជាច្រើនដងផងដែរ ដើម្បីគ្រប់គ្រង និងបង្ក្រាបជនល្មើស។ នាពេលថ្មីៗនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

---

[1] និយមន័យ៖ ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរនូវគ្រឿងញៀន។

[*] កញ្ញា **អ៊ី ម៉ាណូកា** សមាជិកនៃសមាគមសាលាត្រាជូ "**ចំណាត់ការបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**", *ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ*, ខែ មករា ឆ្នាំ២០១៧។

[2] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ២០១២ មាត្រា៤ ត្រង់ទំព័រ៤

[3] UNITED NATIOAS CONVENTIONS ON DRUGS ប្រវត្តិនៃការកកើតអនុសញ្ញាអន្តរជាតិស្តីពីគ្រឿងញៀន

[4] **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានចេញផែនការស្តីពី "យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី១ រយៈពេល៦ខែ (ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនាឆ្នាំ២០១៧) " ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ។

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

បានចេញផែនការស្តីពី "**យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី១ រយៈពេល៦ខែ (ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនាឆ្នាំ២០១៧)**" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីអនុវត្តឲ្យបានប្រសិទ្ធិភាព នូវច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីចូលរួម ខិតខំ ទប់ស្កាត់មិនឲ្យគ្រឿងញៀនបង្កឥទ្ធិពលក្នុងសង្គមជាតិកម្ពុជា ដោយសម្រេចប្តេជ្ញាចិត្តថា៖ **កម្ពុជាជាប្រទេសគ្មានគ្រឿងញៀន និងរក្សាគ្រួសារនីមួយៗជា គ្រួសារស្អាតស្អំគ្មានគ្រឿងញៀន** តាមទស្សវិស័យ "***ចូលរួមទាំងអស់គ្នាដើម្បីជីវិត និងសហគមន៍គ្មានគ្រឿងញៀន***" ដែលបានផ្តោតលើវិធានការសំខាន់ៗដូចជា៖

**ទី១៖ វិធានការអប់រំ**

**ទី២៖ វិធានការរដ្ឋបាល**

**ទី៣៖ វិធានការអនុវត្តច្បាប់**

**ទី៤៖វិធានការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម**

**ទី៥៖ កិច្ចសហប្រតិបត្តិការអន្តរជាតិ**

បន្ថែមពីនេះក្រោមកិច្ចដឹកនាំរបស់ក្រសួងយុត្តិធម៌ និងស្ថាប័នតុលាការ និងស្ថាប័នពាក់ព័ន្ធ បានធ្វើការប្រជុំផ្សព្វផ្សាយអំពីយុទ្ធនាការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ផងដែរ។

ជារួមទៅ ប្រធានបទនេះ ជាការចែករំលែក និងការចូលរួមអបអរសាទរ ដល់ផែនការលើកទី១ ក្នុងការបង្ក្រាប និងបង្ការបទល្មើសគ្រឿងញៀនខុសច្បាប់ក្នុងឆ្នាំ២០១៧នេះ។ ដោយសារជនល្មើសប្រព្រឹត្តសកម្មភាពជួញដូរ ហើយចរាចរថ្នាំញៀនពេញប្រទេស មិនថានៅទីក្រុង និងជនបទនោះទេ ហើយអាចបង្កឲ្យមានអ្នកប្រើប្រាស់ជាច្រើន និងបទល្មើសនានាកើតចេញពីអំពើនេះ។ ដូច្នោះក្នុងនាមជាអ្នកសិក្សា និងស្រាវជ្រាវមួយរូប សូមចូលរួមក្នុងការចែករំលែកក្នុងអត្ថបទខ្លីហើយក្នុងក្របខ័ណ្ឌអ្នកច្បាប់ និងមិនមានចេតនាក្នុងការរិះគន់លើស្ថាប័នណាមួយនោះទេ ប៉ុន្តែម្ចាស់អត្ថបទសង្ឃឹមជឿជាក់ថា ជនគ្រប់រូបធ្វើការយល់ដឹងពីដំណើរការចំណាត់ការបទល្មើសនេះ និងការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលទាំងអស់គ្នា " **ចូលរួមទាំងអស់គ្នាដើម្បីជីវិត និងសហគមន៍គ្មានគ្រឿងញៀន** " ចាប់ពីថ្ងៃនេះតទៅ។

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

# មាតិកាសង្ខេប

ទំព័រ

**ជំពូក១៖ សកម្មភាពប្រតិបត្តិការបទល្មើស**.............................................៤

ផ្នែកទី១៖ការចាប់យកបទល្មើសគ្រឿងញៀន.............................................៤

ផ្នែកទី២៖ការឆែកឆេរ.............................................................................១២

ផ្នែកទី៣ ៖ការធ្វើតេស្ត និងការវេចខ្ចប់...................................................១៦

ផ្នែកទី៤៖ ការដកសំណាក......................................................................២០

**ជំពូកទី២៖ ការចាត់ចែងក្រោយការបង្ក្រាបបទល្មើស**.................................. ២៥

ផ្នែកទី១៖ ការអនុវត្តទោស......................................................................២៥

ផ្នែកទី២៖ ការចាត់ចែងចំពោះវត្ថុរឹបអូសពាក់ព័ន្ធនឹងបទល្មើស........................២៨

**ឯកសារយោង**.......................................................................................................៣២

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាគ្រាជ្ញ

# ជំពូកទី១៖ សកម្មភាពប្រតិបត្តិការបទល្មើស

បទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន[5] ជាបទល្មើសមានចរិតលក្ខណៈគ្រោះថ្នាក់ធ្ងន់ធ្ងរ និងបង្កព្យសនកម្មដ៏ធំធេងសម្រាប់សង្គម ពីព្រោះថាបទល្មើសនេះ ត្រូវបានច្បាប់ហាមឃាត់ និងបង្កការលំបាកជាច្រើនដល់ប្រទេសជាតិទាំងមូល។ សកម្មភាពក្នុងការទិញ-លក់គ្រឿងញៀនកំពុងតែរីករាលដាល និងត្រូវបានជនល្មើសប្រព្រឹត្តយ៉ាងសកម្ម ដែលអំពើនេះទាមទារឲ្យមានចំណាត់ការយ៉ាងសកម្មពីស្ថាប័នតុលាការ និងស្ថាប័នពាក់ព័ន្ធ។

## ផ្នែកទី១៖ ការចាប់យកបទល្មើសគ្រឿងញៀន

ជនល្មើសបានប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រកបដោយល្បិចកលខ្ពស់ និងធ្វើសកម្មភាពក្រោមរូបភាពខុសប្លែកៗគ្នាជាច្រើន។ សកម្មភាពទាំងនេះប្រព្រឹត្តក្រោមរូបភាពជាបទល្មើសជាក់ស្តែង និងមិនជាក់ស្តែង ដែលទាមទារឲ្យមានការសហការ និងការបំពេញបេសកម្មយ៉ាងសកម្ម។

### កថាភាគទី១៖ បទល្មើសជាក់ស្តែង

បទល្មើសដែលបានប្រព្រឹត្តតែងតែមានមានសកម្មភាពដោយផ្ទាល់ និងសកម្ម ដែលត្រូវបាននគរបាលយុត្តិធម៌ចាប់ក្រោមរូបភាពជាបទល្មើសជាក់ស្តែង។

#### ចំណុចទី១៖ .លក្ខខណ្ឌ

បទល្មើសខាងក្រោមនេះជាបទល្មើសជាក់ស្តែង[6] ដែលត្រូវបានអាជ្ញាធរមានសមត្ថកិច្ចចុះបង្ក្រាបដើម្បីចាប់គ្រឿងញៀនដែលខុសច្បាប់ដូចជា៖

- បទល្មើសដែលកំពុងប្រព្រឹត្ត
- បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម
- ជនសង្ស័យត្រូវបានសាធារណជនស្រែកដេញប្រផាប់ចាប់ប្រកឹង
- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីចង្វាក់ផ្សេងទៀតដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមបទល្មើស។

[5] សារធាតុញៀន សំដៅដល់សារធាតុដែលបង្កឲ្យញៀន ជាអាទិ៍ សារធាតុណាកូទិក សារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលបានមកពីការផលិត ការធ្វើសំយោគ ឬពាក់កណ្តាលសំយោគ ដូចមានចុះក្នុងតារាងទី១ តារាងទី២ និងតារាងទី៣ ដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ត្រង់មាត្រា៨៦ និងមាត្រា៨៨

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្ជ

– បទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។

### ចំណុចទី២៖ នីតិវិធី

ដើម្បីអាចស្វែងរកជនល្មើស និងចាប់បាននូវការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មន្ទីរប្រឆាំងគ្រឿងញៀននៃអគ្គស្នងការនគរបាលនៃក្រសួងមហាផ្ទៃ ប្រមូលផ្តុំព័ត៌មានទាំងអស់ដែលអាចសម្រួលក្នុងការស្រាវជ្រាវរក និងបង្ក្រាបបទល្មើសគ្រឿងញៀនខុសច្បាប់ ហើយសម្របសម្រួលប្រតិបត្តិការទាំងអស់ក្នុងផ្ទៃប្រទេស ដើម្បីបង្ក្រាបគ្រឿងញៀន។[7]

### កថាភាគទី២៖ ការប្រើប្រាស់កម្លាំងសម្ងាត់

ការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាបទល្មើសដែលពិបាកនឹងធ្វើការបង្ក្រាប ដើម្បីឈានទៅរកចាប់បានទាំងជនល្មើស និងគ្រឿងញៀន ដោយសារតែមានករណីជាច្រើនបទល្មើសនេះមិនអាចចាប់បានដោយនគរបាលប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអាជ្ញាធរដែលមានសមត្ថកិច្ច។ កត្តាទាំងនេះ បណ្តាលឲ្យមានការបង្កើតជាបទបញ្ញត្តិពិសេស ដែលអនុញ្ញាតឲ្យមានការប្រើប្រាស់កម្លាំងសម្ងាត់ ដើម្បីជាជំនួយការក្នុងការស៊ើបអង្កេត និងចាប់បាននូវបទល្មើសនេះ។

### ចំណុចទី១. ការកំណត់អត្តសញ្ញាណនៃកម្លាំងសម្ងាត់

ដើម្បីអាចក្លាយខ្លួនជាកម្លាំងសម្ងាត់ វាទាមទារឲ្យកំណត់ឲ្យបានច្បាស់លាស់ពីអត្តសញ្ញាណ នៃការចូលជាសមាជិកឲ្យបានច្បាស់លាស់ ពីព្រោះថាជនដែលត្រូវបានប្រើប្រាស់ជាកម្លាំងសម្ងាត់ត្រូវតែជាមនុស្សដែលអាចទុកចិត្តបាន និងការពារកុំឲ្យមានការប្រើប្រាស់កម្លាំងសម្ងាត់ដោយខុសច្បាប់ ឬការអនុវត្តខុសព្រំដែនកំណត់ដែលបានកំណត់ដោយច្បាប់។

#### ក.ពាក្យស្នើសុំ

ជនជាមុខសញ្ញាដែលត្រូវបានជ្រើសរើសឲ្យក្លាយជាកម្លាំងសម្ងាត់ ទាមទារឲ្យមានការដាក់ពាក្យស្នើសុំចូលរួមក្នុងនាមជាភ្នាក់ងារផ្តល់ព័ត៌មាន។ ចំពោះពាក្យស្នើសុំនេះ វាទាមទារឱមានការបំពេញឲ្យបានត្រឹមត្រូវ

[7] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ២០១២ មាត្រា៨

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

ដើម្បីទុកជាឯកសារសម្រាប់តុលាការ និងជាការបញ្ជាក់ពីភាពស្របច្បាប់ក្នុងការអនុវត្តបទល្មើសនេះដោយស្របច្បាប់។

**ក១. ការចូលជាភ្នាក់ងារផ្តល់ព័ត៌មាន**

ជនជាកម្លាំងសម្ងាត់ ត្រូវដាក់ពាក្យស្នើសុំចូលជាភ្នាក់ងារផ្តល់ព័ត៌មាន ដែលមានទំរង់ត្រូវបានកំណត់ដោយប្រកាសស្តីពី នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងញុះញង់ឲ្យលក់ដោយខុសច្បាប់។[8]

ជាទូទៅក្នុងទម្រង់នៃការស្នើសុំចូលជាភ្នាក់ងារផ្តល់ពត៌មាន ត្រូវមានរួមបញ្ចូលនូវចំណុចសំខាន់ដូចជា[9]៖

១. ឈ្មោះ ថ្ងៃខែឆ្នាំកំណើត មុខរបរ និង អាស័យដ្ឋាន

២.កម្មវត្ថុ៖ស្តីពីការស្នើសុំចូលបំរើការងារ ជាភ្នាក់ងារផ្តល់ពត៌មានរបស់អង្គភាព.....

៣.ខនៃការសន្យា៖ ដែលមាន៥ចំណុចដូចជា

ក.សោះត្រង់ចំពោះ ជាតិ សាសនា ព្រះមហាក្សត្រ

ខ.អនុវត្តដាច់ខាតនូវការណែនាំរបស់សមត្ថកិច្ចដឹកនាំដែលជាមន្រ្តីនគរបាលយុត្តិធម៌ក្នុងការអនុវត្តតាមច្បាប់បានកំណត់

គ.មិនស្តាប់ការអូសទាញរបស់ជនល្មើស និងមិនប្រព្រឹត្តដាច់ខាតនូវអំពើណា ដែលផ្ទុយនឹងច្បាប់រដ្ឋ

ឃ.មានភារកិច្ចរាយការណ៍ករណីបន្ទាន់ បណ្តាមុខសញ្ញាជួញដូរគ្រឿងញៀនខុសច្បាប់ និងមុខសញ្ញាប្រព្រឹត្តបទល្មើសប្រឆាំងនឹងច្បាប់

ង.ក្នុងពេលដែលខ្ញុំបាទ នាងខ្ញុំ ត្រូវបានប្រើប្រាស់ជាភ្នាក់ងារផ្តល់ពត៌មាន ដើម្បីចូលជ្រៅក្នុងករណីកំពុងតស៊ូ ខ្ញុំបាទ ឬនាងខ្ញុំ សូមសន្យាថា នឹងយកចិត្តទុកដាក់ ខិតខំបំពេញភារកិច្ចនេះ ឈានទៅបង្ក្រាបទទួលបានលទ្ធផលជោគជ័យ។

**ក២ .ការប្រើប្រាស់ភ្នាក់ងារផ្តល់ព័ត៌មាន**

ទោះបីជាមានពាក្យស្នើសុំចូលជាភ្នាក់ងារពត៌មាន ក៏មន្រ្តីនគរបាលប្រឆាំងគ្រឿងញៀនមិនទាន់មានសិទ្ធិស្របច្បាប់ ដើម្បីប្រើប្រាស់កម្លាំងសម្ងាត់នោះទេ តែវាទាមទារឲ្យមានពាក្យស្នើសុំប្រើប្រាស់ភ្នាក់ងារផ្តល់ពត៌មានជាមុនសិន ដើម្បីស្នើសុំការអនុញ្ញាតពីនាយកមន្ទីរប្រឆាំងគ្រឿងញៀន។

---

[8] ប្រកាសស្តីពី នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំលើ និងញុះញង់ឲ្យលក់ដោយខុសច្បាប់ ចូលជាធរមានថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៦

[9]ប្រកាសស្តីពី នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំលើ និងញុះញង់ឲ្យលក់ដោយខុសច្បាប់ ចូលជាធរមានថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៦

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

### ខ.ប្រវត្តិរូប និង ទំនាក់ទំនង

ភ្នាក់ងារផ្តល់ព័ត៌មាន ត្រូវតែបញ្ជាក់ពីប្រវត្តិរូបឲ្យបានត្រឹមត្រូវ ពីព្រោះថា វាជាឯកសារដែលគេទុកសម្រាប់តម្កល់ទុកជាឯកសារ និងត្រូវតែបង្ហាញពីទំនាក់ទំនងជិតដិតជាមួយមុខសញ្ញាដទៃទៀតដែលកំពុងតែប្រព្រឹត្តបទល្មើស ដែលសមត្ថកិច្ចកំពុងតែស្វែងរក និងចុះបង្ក្រាប។[10]

ប្រវត្តិរូបរបស់ភ្នាក់ងារជាចំណុចសំខាន់ ដែលត្រូវតែរក្សាទុកឲ្យបានល្អ ពីព្រោះថាវាជាប្រភពឯកសារដែលបញ្ជាក់ពីការសម្គាល់បុគ្គលនីមួយៗដែលបានចូលជាភ្នាក់ងារ។ ប្រវត្តិរូបនេះ ត្រូវតែធ្វើការសរសេរ និងរៀបរាប់ពីព័ត៌មានផ្ទៃក្នុងគ្រួសារ សមាជិក និង ប្រវត្តិរបស់គ្រួសារ។ ជាពិសេស ក្នុងប្រវត្តិរូបនេះ ត្រូវបានផ្តល់ឲ្យនូវលេខសម្ងាត់សម្រាប់បុគ្គលនីមួយៗដែលត្រូវបានផ្តល់ដោយនគរបាល ដើម្បីធ្វើការកត់សម្គាល់ និងងាយស្រួលក្នុងការទំនាក់ទំនង ដើម្បីកុំឲ្យមានការបែកធ្លាយពត៏មាន។

## ចំណុចទី២៖.របាយការណ៍ចុះបេសកកម្ម

ដើម្បីជាភស្តុតាង ក្នុងការបញ្ជាក់ថា ជនទោះពិតជាអាចផ្តល់នូវព័ត៌មានមួយដ៏គួរឲ្យជឿជាក់នោះ វាទាមទារឲ្យមានរបាយការណ៍ផ្តល់ព័ត៌មានរបស់ភ្នាក់ងារផ្តល់ពត៌មាន។

### ក.របាយការណ៍ព័ត៌មាន

នៅពេលដែលភ្នាក់ងារផ្តល់ព័ត៌មាន ក្តាប់បាននូវមុខសញ្ញាសង្ស័យរកស៊ីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ត្រូវធ្វើរបាយការណ៍ទៅកាន់មន្ទីរប្រឆាំងគ្រឿងញៀន ពីអត្តសញ្ញាណ និងបញ្ជាក់ទីតាំងដែលអាចឲ្យសមត្ថកិច្ចចុះតាមដាន និងស៊ើបអង្កេតស្រាវជ្រាវបន្ថែមដើម្បីចាប់ជនល្មើសបាន។[11]

### ខ. លទ្ធផល ការស្រាវជ្រាវ ស៊ើបអង្កេត

[10] ប្រកាសស្តីពី នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំលើ និងញុះញង់ឲ្យលក់ដោយខុសច្បាប់ ចូលជាធរមានថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៦ ៖ ប្រវត្តិរូបភ្នាក់ងារផ្តល់ពត៏មាន លេខ 2B A0002

[11] ប្រកាសស្តីពី នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំលើ និងញុះញង់ឲ្យលក់ដោយខុសច្បាប់ ចូលជាធរមានថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៦ ៖ របាយការណ៍ ព័ត៌មានរបស់ភ្នាក់ងារផ្តល់ព័ត៌មាន 2B A0004

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

នាយការិយាល័យនៃមន្ទីរប្រឆាំងគ្រឿងញៀន ត្រូវធ្វើរបាយការណ៍ ពីលទ្ធផល ការស្រាវជ្រាវ និងស៊ើបអង្កេត ដើម្បីដាក់ជូនទៅ នាយកមន្ទីរប្រឆាំងគ្រឿងញៀន ពីលទ្ធផលនៃការចុះស៊ើបអង្កេតបញ្ជាក់បំភ្លឺពីករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

## ចំណុចទី៣៖ វិធានការប្រគល់

ជនល្មើសដែលបានប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀនមួយចំនួនពិបាករកមុខសញ្ញា និងមិនងាយអាចចាប់បាននោះទេ ប្រសិនជាមិនមានការប្រើល្បិចកលដោយមានការញុះញង់ឲ្យមានការទិញ និងលក់គ្រឿងញៀនទាំងនោះ។ ដូច្នេះដើម្បីអាចស្វែងរកមុខសញ្ញាឃើញ វិធានការប្រគល់ គឺជាចំណុចដែលសំខាន់ សម្រាប់យកមកអនុវត្តដើម្បីឲ្យជនល្មើសប្រគល់គ្រឿងញៀន។

### ក.ការប្រគល់ដោយមានការឃ្លាំមើល

ការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់ដោយខុសច្បាប់ គឺជាវិធានការពិសេស ដែលអនុញ្ញាតឲ្យមានការប្រើប្រាស់កម្លាំងសម្ងាត់ សម្រាប់ធ្វើជាផ្ទាក់ចាប់បានជនល្មើសដែលប្រព្រឹត្តបទល្មើស។

#### ក១. ការរៀបចំគំរោង និង អន្ទាក់

នគរបាលជាតិនៃក្រសួងមហាផ្ទៃ ជាអ្នកដែលជួយក្នុងការរៀបចំគំរោង និងអន្ទាក់សម្រាប់ការចុះអនុវត្តបេសកម្មចាប់គ្រឿងញៀនដែលជាមុខសញ្ញាប្រព្រឹត្តបទល្មើស។ ក្នុងការរៀបចំគំរោងមុនពេលដែលចុះបំពេញបេសកម្ម វាទាមទារឲ្យមានការប្រុងប្រយ័ត្ន និងមានភាពច្បាស់លាស់។

#### ក២. ការដឹកនាំការឃ្លាំមើល

ដើម្បីអាចអនុវត្តការប្រគល់ដោយការឃ្លាំមើលបាន អាជ្ញាធរមានសមត្ថកិច្ចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ដូចជា៖[12]

- គ្រឿងញៀនដែលមានចែងក្នុងមាត្រា១[13] នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

[12] ប្រកាសស្តីពី នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងញុះញង់ឲ្យលក់ដោយខុសច្បាប់ ចូលជាធរមានថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៦ ត្រង់ប្រការ៣

[13] ច្បាប់នេះមានគោលបំណងបង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ត្រួតពិនិត្យរាល់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងធានាការអនុវត្តកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាដែលជាភាគីនៃអនុសញ្ញា និងពិធីសាររបស់អង្គការសហប្រជាជាតិដែលទាក់ទងនឹងគ្រឿងញៀន

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

- ឧបករណ៍ បរិក្ខារ ឬសម្ភារៈដទៃទៀតផ្សេងទៀតដែលជនល្មើសប៉ុនប៉ងយកទៅប្រើប្រាស់ ឬកំពុងប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស
- មូនិធិ ឬវត្ថុមានតម្លៃដទៃផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនឹងបទល្មើសណាមួយនោះ

ក្រៅពីនេះ ដើម្បីចុះអនុវត្តវិធានការប្រគល់ដោយឃ្លាំមើលបាន មន្ត្រីមានសមត្ថកិច្ចត្រូវតែកំណត់ពីតួនាទីរបស់ខ្លួន ក៏ដូចជាសិទ្ធិអំណាចសម្រាប់អនុវត្តពេលចុះបំពេញបេសកម្មដូចជា៖

- ចាំបាច់ត្រូវតែធ្វើសេចក្តីរាយការណ៍ជូនដំណឹងអំពីសេចក្តីសម្រេចឲ្យប្រើប្រាស់ការប្រគល់ដោយមានការឃ្លាំមើលទៅព្រះរាជអាជ្ញានៃទីកន្លែងដែលបានអនុវត្តសេចក្តីសម្រេចនេះ។
- អាចបញ្ជាឲ្យធ្វើអន្តរាគមន៍នៅគ្រប់ដំណាក់កាលទាំងអស់នៃប្រត្តិបត្តិការរបស់ខ្លួន

ប្រសិនបើត្រូវការទប់ស្កាត់អសន្តិសុខភ្លាមៗ ឬមានការផ្លាស់ប្តូរទិសដៅនៃការបញ្ជូនដែលមិនបានរំពឹងទុកជាមុន ឬ មានកាលៈទេសៈផ្សេងៗទៀតដែលជាឧបសគ្គដល់ការរឹបអូសវត្ថុបញ្ជូន ឬ

- ឲ្យធ្វើសកម្មភាពស្របច្បាប់ណាមួយសម្រាប់តទល់នឹងជនល្មើស

### ខ. ការញុះញង់ឲ្យលក់ដោយខុសច្បាប់

ការប្រើប្រាស់វិធីខាងលើនេះ គឺក្នុងគោលបំណងដើម្បីសម្រួលការស៊ើបអង្កេតឲ្យមានប្រសិទ្ធិភាព ដោយអនុញ្ញាតឲ្យ មន្ត្រីមានសមត្ថកិច្ចចូលរួមក្នុងបទល្មើសទាំងឡាយដូចជា ការទំនាក់ទំនង ការឃុបឃិត ការប៉ុនប៉ង ឬការសមគំនិត ជាមួយជនល្មើសក្នុងអំពើណាមួយ ដើម្បីកំណត់ឲ្យបានច្បាស់អំពីបទល្មើសនោះ នឹងជនពាក់ព័ន្ធដែលត្រូវធ្វើការចោទប្រកាន់។

#### ខ១.លក្ខខណ្ឌ

អាជ្ញាធរអាចសម្រេចប្រគល់សិទ្ធិដល់ មន្ត្រីអនុវត្តច្បាប់ណាមួយ ឲ្យធ្វើការញុះញង់ជនទាំងឡាយណាដែលមានមូលហេតុធួនល្មមសង្ស័យថា បានប្រព្រឹត្ត ឬរៀបចំប្រព្រឹត្តបទល្មើសទាក់ទងនឹងគ្រឿងញៀន ដើម្បីឲ្យជននោះលក់ដោយខុសច្បាប់នូវ[14]៖

[14] ប្រកាសស្តីពី នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់ដោយខុសច្បាប់ ចូលជាធរមាន០៨ ខែកុម្ភៈ ឆ្នាំ២០០៦ ត្រង់ប្រការ៤

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្

- គ្រឿងញៀន ឬសារធាតុដទៃផ្សេងៗទៀត ដូចមានចែងក្នុងមាត្រា១នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ឧបករណ៍ បរិក្ខារ ឬសម្ភារៈដទៃផ្សេងទៀត ដែលជនល្មើសមានចេតនាយកទៅប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស។

សូមបញ្ជាក់ថា នៅពេលសម្រេចឲ្យប្រើប្រាស់វិធីនេះ អាជ្ញាធរត្រូវពិចារណាឲ្យបានហ្មត់ចត់ មួយផ្នែកទៅលើភស្តុតាងដែលបានប្រមូល និងមួយផ្នែកទៀតទៅលើលទ្ធផលផ្សេងៗ ដែលជាការប្រថុយប្រថានទៅនឹងគ្រោះថ្នាក់របស់បុគ្គលដែលមានការពាក់ព័ន្ធក្នុងសកម្មភាពល្មើស ដែលតាមធម្មតា ប្រសិនជាយើងមិនញុះញង់ទេ គេពុំធ្វើដូច្នោះឡើយ។

## ខ២. កម្មវត្ថុ និង ទម្រង់ស្នើសុំ[15]

ទម្រង់ដែលកំណត់ចំពោះការស្នើសុំចុះបង្ក្រាបបទល្មើសនេះ ត្រូវតែមានភាពច្បាស់លាស់ និងភ្ជាប់ជាមួយឯកសារយោងជាក់លាក់ ទើបអាចឈានទៅរកការចុះបំពេញបេសកម្មបាន។ ក្នុងពាក្យស្នើសុំនេះ ត្រូវបញ្ជាក់ពីកម្មវត្ថុក្នុងការស្នើសុំ និងយោងតាមប្រភពឯកសារចាំបាច់ដែលទាមទារឲ្យមាន ដោយបញ្ជាក់ពីមុខសញ្ញាដែលបានធ្វើសកម្មភាព ទៅលើប្រភេទគ្រឿងញៀនបែបណា។

## ខ៣.ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

ទាំងបុគ្គលឯកជនធម្មតាក្រោមបញ្ជា និងក្រោមការត្រួតពិនិត្យផ្ទាល់របស់មន្ត្រីអនុវត្តច្បាប់ដែលបានចាត់តាំង អាចអនុវត្តបាននូវវិធានការញុះញង់ខាងលើបាន។ ជាពិសេស មន្ត្រីអនុវត្តច្បាប់ ឬបុគ្គលធម្មតាដែលបានទទួលការចាត់តាំងឲ្យអនុវត្តវិធីញុះញង់ឲ្យលក់ដោយខុសច្បាប់ស្របទៅតាមលក្ខខណ្ឌនៃប្រការនេះ មិនត្រូវទទួលនូវការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ការដាក់ទណ្ឌកម្មផ្នែករដ្ឋបាល ឬផ្នែករដ្ឋប្បវេណី ចំពោះសកម្មភាពទាំងឡាយដែលខ្លួនបានធ្វើក្នុងរង្វង់សិទ្ធិដែលបានអនុញ្ញាតនោះទេ[16] ប៉ុន្តែប្រសិនជាជនទាំងនេះ បានប្រព្រឹត្តខុសពីកម្មវត្ថុដែលបានធ្វើ នោះជនទាំងនោះត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ដូចជាជនល្មើសដទៃទៀត។

---

[15] ប្រកាសស្តីពី នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំលើ និងញុះញង់ឲ្យលក់ដោយខុសច្បាប់ ចូលជាធរមានថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៦ ៖ ការស្នើសុំអនុវត្តវិធានញុះញង់ 2B A0008

[16] ប្រកាសស្តីពី នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់ដោយខុសច្បាប់ ចូលជាធរមាន០៨ ខែកុម្ភៈ ឆ្នាំ២០០៦ ត្រង់ប្រការ៤

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ

### គ.ដីកាសម្រេចទទួលស្គាល់កម្លាំង

គ្រប់ពាក្យស្នើសុំបង្ក្រាបតាមវិធានញុះញង់ ឱ្យលក់ដោយខុសច្បាប់នូវគ្រឿងញៀន មិនមែនសុទ្ធសឹងតែអាចត្រូវយកទៅអនុវត្ត ឬបំពេញបេសកម្មបាននោះភ្លាមទេ តែវាទាមទារឱ្យមានដីកាសម្រេចក្នុងការទទួលស្គាល់កម្លាំងសម្ងាត់។ សេចក្តីសម្រេចរបស់អាជ្ញាធរដែលអនុញ្ញាតឱ្យប្រើប្រាស់វិធីញុះញង់ឱ្យលក់ដោយខុសច្បាប់ ត្រូវជូនដំណឹងភ្លាមទៅព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចលើទីកន្លែងដែលអាចសន្មត់ថាការលក់ត្រូវធ្វើឡើង។

ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ធ្វើសេចក្តីសម្រេចនេះ ដោយផ្អែកលើរបាយការណ៍ និងការស្នើសុំរបស់មន្ទីរប្រឆាំងគ្រឿងញៀននៃក្រសួងមហាផ្ទៃ ដែលបានស្នើសុំបង្ក្រាបករណីជួញដូរគ្រឿងញៀនតាមវិធានញុះញង់ ឱ្យលក់គ្រឿងញៀនដោយខុសច្បាប់ និង ការស្នើសុំប្រើប្រាស់ភ្នាក់ងារសម្ងាត់។ ដីកាសម្រេចនេះនឹងបញ្ជាក់ពីការទទួលស្គាល់ភ្នាក់ងារព័ត៌មាន នឹងអនុញ្ញាតស្របច្បាប់ឱ្យជនរូបនេះធ្វើសកម្មភាពក្នុងនីតិវិធីប្រគល់ ដោយមានការឃ្លាំមើល ឬការញុះញង់ឱ្យលក់ដោយខុសច្បាប់ក្នុងបទល្មើសគ្រឿងញៀន ដើម្បីកំណត់ឱ្យបានច្បាស់អំពីបទល្មើស និងជនពាក់ព័ន្ធ ដែលនឹងត្រូវធ្វើការឃាត់ខ្លួន និងផ្តើមការចោទប្រកាន់តាមនីតិវិធី។

ការចេញដីកាសម្រេចនេះ មានឆន្ទៈចម្បងដើម្បីសម្រួលដល់ការស៊ើបអង្កេតរបស់សមត្ថកិច្ចឱ្យមានប្រសិទ្ធិភាព។ ក្រៅពីនេះសេចក្តីសម្រេចនេះ ទាមទារឱ្យធ្វើសេចក្តីចម្លងទៅអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ដើម្បីជូនជ្រាបជាផ្លូវការផងដែរ។

#### គ១.កម្លាំងចាស់

ករណីដែលភ្នាក់ងារជាកម្លាំងចាស់ ដែលធ្លាប់បានអនុវត្ត និងចាប់បានបទល្មើសពីមុនមក ពុំចាំបាច់ទាមទារ ឱ្យមានដីកាសម្រេចថ្មីនោះទេ ប៉ុន្តែលុះត្រាតែ ភ្នាក់ងារសម្ងាត់នោះជាកម្លាំងចាស់ ដែលមិនទាន់ផុតថេរវេលាកំណត់សម្រាប់បំពេញបេសកម្ម ឬត្រូវបានបញ្ឈប់សកម្មភាពតែប៉ុណ្ណោះ។

#### គ២.កម្លាំងថ្មី

កម្លាំងសម្ងាត់ដែលទើបតែបានស្នើសុំ នឹងមិនដែលបានបំរើការងារពីមុនមក ឬផុតកំណត់រយៈពេលនៃការអនុវត្តនោះ វាទាមទារឱ្យមានដីកាសម្រេចទទួលស្គាល់កម្លាំង។ ដីកានេះ នឹងបញ្ជាក់ពីការទទួលស្គាល់ឈ្មោះបុគ្គលដែលជាកម្លាំងសម្ងាត់ ក្នុងការអនុញ្ញាតឱ្យធ្វើសកម្មភាពក្នុងនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល ឬការញុះញង់ឱ្យលក់ដោយខុសច្បាប់ ដើម្បីកំណត់ឱ្យបានច្បាស់អំពីបទល្មើស និងជនពាក់ព័ន្ធដែលត្រូវធ្វើការឃាត់ខ្លួន និងផ្តើមចោទប្រកាន់តាមនីតិវិធី។

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

### ឃ. លុយជាផ្លាក់សម្រាប់អនុវត្ត

លុយជាប្រភព ដ៏សំខាន់ដើម្បីអាចអនុវត្តវិធានញុះញង់ ដោយមានការការឃ្លាំមើល និងប្រគល់ការលក់ដោយខុសច្បាប់នូវសារធាតុញៀន ពីព្រោះថាប្រសិនជាមិនមានលុយនោះទេ សមត្ថកិច្ច និងភ្នាក់ងារសម្ងាត់មិនអាចឈានទៅរកការកំណត់អត្តសញ្ញាណនៃភ្នាក់ងារសម្ងាត់បាននោះទេ។

## កថាភាគទី៣៖ ការរៀបចំកម្លាំង និង ការបែងចែកមុខព្រួញចុះប្រតិបត្តិ

ការចុះអនុវត្តបំពេញបេសកម្ម មិនអាចធ្វើឡើងដោយមិនបានរៀបចំទិសដៅមួយច្បាស់លាស់នោះទេ តែវាទាមទារឲ្យមានការសហការ និងរៀបចំគំរោងច្បាស់លាស់ក្នុងការដឹកនាំកម្លាំង ដើម្បីស្វែងរក និងចាប់មុខសញ្ញាដែលបានប្រព្រឹត្តបទល្មើសដោយខុសច្បាប់។

### ចំណុចទី១៖ វិធីសាស្ត្រដឹកនាំការបែងចែកកម្លាំង

ការចុះបង្ក្រាបបទល្មើសនេះ មានទ្រង់ទ្រាយខុសៗគ្នា ដែលខ្លះវាគ្រាន់តែជាប្រភេទបទល្មើសដែលមានកម្រិតជួញដូរតូចតាច ហើយករណីខ្លះអំពើប្រព្រឹត្តមានលក្ខណៈធំ និងអាចមានកម្លាំងតបតកើតមានឡើងនៅពេលដែលចុះប្រតិបត្តិការ។ កត្តាទាំងនេះ វាទាមទារឲ្យមានការត្រៀមរៀបចំយុទ្ធសាស្ត្រសម្រាប់បែងចែកនូវកម្លាំង នៅពេលចុះទៅអនុវត្តឲ្យបានចំទិសដៅ។

❖ **ការរៀបចំកម្លាំងតាមយុទ្ធសាស្ត្រ**

ជាគោលការណ៍ ប្រសិនជាយល់ឃើញថាមានភាពចាំបាច់ មន្ត្រីអនុវត្តអាចធ្វើជាលិខិតស្នើសុំទៅនាយកមន្ទីរប្រឆាំងគ្រឿងញៀន ស្តីពីការស្នើសុំអនុញ្ញាតប្រើប្រាស់អាវុធ ដើម្បីចុះបង្ក្រាបបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ ការធ្វើសំនើរនេះ ត្រូវមានភ្ជាប់នឹងឯកសារយោងរបស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តព្រះសីហនុ និងមានចំណារឯកភាពយល់ព្រម។

### ចំណុចទី២៖ ប្លង់ទីតាំងគោលត្រូវចុះបង្ក្រាប

មន្ទីរប្រឆាំងគ្រឿងញៀន ត្រូវបញ្ជាក់ពីប្លង់ទីតាំងគោលដៅត្រូវចុះបង្ក្រាបបទល្មើស និងដើម្បីបំពេញបេសកម្មរបស់ខ្លួន។ ប្លង់ទីតាំងគោលនេះ វាជាជំនួយមួយច្បាស់លាស់ សម្រាប់ឲ្យមន្ត្រីនគរបាលយុត្តិធម៌មានភាពច្បាស់លាស់ និងបែងចែកកម្លាំងសម្រាប់ចុះទៅចាប់មុខសញ្ញាច្បាស់លាស់។

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាគ្រាជ្ញ

# ផ្នែកទី២៖ ការឆែកឆេរ

បន្ទាប់ពីបានដឹងមុខសញ្ញា និងចុះបំពេញបេសកម្មបានសម្រេចនៅទីកន្លែងកើតហេតុ មន្ត្រីនគរបាលយុត្តិធម៌ រួមជាមួយស្ថាប័នអយ្យការ នឹងដឹកនាំធ្វើការឆែកឆេរទីតាំងដែលជនល្មើសបានប្រព្រឹត្តបទល្មើស ឬនាំជនល្មើសទៅរកទីកន្លែងដែលបានលាក់ទុកគ្រឿងញៀន។

## កថាភាគទី១៖កម្មវត្ថុនៃការឆែកឆេរ

ការចុះឆែកឆេរបទល្មើស ត្រូវតែកំណត់ពីកម្មវត្ថុដែលត្រូវតែធ្វើការឆែកឆេរ ឲ្យបានច្បាស់លាស់ ពីព្រោះថាមិនមែនគ្រប់វត្ថុដែលចុះបង្ក្រាប និងបំពេញបេសកម្មសុទ្ធសឹងតែត្រូវបានចាប់យកនោះទេ បន្ទាប់ពីបានចុះឆែកឆេរនោះទេ។

### ចំណុចទី១៖តើអ្វីខ្លះជាកម្មវត្ថុត្រូវបានឆែកឆេរ?

នៅពេលដែលចុះទៅដល់កន្លែងកើតហេតុ មានវត្ថុជាច្រើនត្រូវស្រាវជ្រាវ និងឆែកឆេរដើម្បីស្វែងរកភស្តុតាងដែលមានការពាក់ព័ន្ធនឹងបទល្មើស។ជាទូទៅ វត្ថុ០៣ប្រភេទត្រូវតែបែងចែកឲ្យបានច្បាស់លាស់ នៅពេលដែលចុះទៅឆែកឆេរ គឺ វត្ថុដែលជាកម្មវត្ថុគ្រឿងញៀន, វត្ថុផ្ទាល់ខ្លួន និងវត្ថុកើតចេញពីផលបទល្មើស។

#### ក.វត្ថុដែលជាកម្មវត្ថុគ្រឿងញៀន

វត្ថុដែលជាកម្មវត្ថុនៃការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាសារធាតុដែលបង្កឲ្យឲ្យញៀនជាអាទិ៍ សារធាតុណាកូទិក សារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលបានមកពីការផលិត ការសំយោគ ឬពាក់កណ្តាលសំយោគ ដូចមានក្នុងតារាងឧបសម្ព័ន្ធនៃតារាងទី១ តារាងទី២ និងតារាងទី៣។[17]

#### ខ.វត្ថុផ្ទាល់ខ្លួន

ក្រៅពីគ្រឿងញៀនដែលបានឆែកឆេរ មន្ត្រីមានសមត្ថកិច្ចអាចធ្វើការឆែកឆេរ និងចាប់យកវត្ថុផ្ទាល់ខ្លួនរបស់ជនល្មើស ករណីដែលវត្ថុនោះមានមន្ទិលសង្ស័យជាប់ពាក់ព័ន្ធនឹងបទល្មើសនេះ។ជាទូទៅវត្ថុផ្ទាល់ខ្លួនរបស់ជនល្មើសដែលត្រូវបានឆែកឆេរ និងចាប់យកមានដូចជាទូរស័ព្ទ ឬលុយកាក់ដែលមាននៅជាប់ខ្លួន។ បន្ថែមលើសពីនេះ ករណីខ្លះ សូម្បីតែគ្រឿងអលង្ការដែលពាក់ជាប់ខ្លួនក៏ត្រូវបានដកទុក និង សម្ភារៈដទៃទៀតដែលមានក្នុងទូដែក ឬហិបណាមួយ ក៏ត្រូវបានគាស់ទំលុះទំលាយ នឹងធ្វើការរឹបអូសជាបណ្តោះអាសន្នផងដែរ។

[17] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២៖ តារាងឧបសម្ព័ន្ធ ថ្នាំញៀន និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ និងសារធាតុសម្រាប់ផលិតគ្រឿងញៀន

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

### គ.វត្ថុកើតចេញពីផលបទល្មើស

ក្រៅពីកម្មវត្ថុទាំងពីរខាងលើនេះ វត្ថុដែលកើតចេញពីផលបទល្មើស ក៏ជាកម្មវត្ថុសម្រាប់ធ្វើការឆែកឆេរ និងចាប់យកផងដែរ។ ជាក់ស្តែង វត្ថុទាំងនោះអាចមាន រថយន្ត ម៉ូតូ សម្ភារៈអេឡិចត្រូនិច និងគ្រឿងសង្ហារឹមជាដើម។ មូលហេតុដែលឆែកឆេរ វត្ថុទាំងនោះ ដោយសារតែ វាមានសារសំខាន់ដើម្បីស្វែងរកថាជនល្មើសបានកែច្នៃទិញសម្ភារៈទាំងនោះ បន្ទាប់ពីបានប្រព្រឹត្តបទល្មើសទាំងនោះ។ជាពិសេស ប្រសិនជា វត្ថុទាំងនោះ មិនជាប់ពាក់ព័ន្ធ បន្ទាប់ពីធ្វើការត្រួតពិនិត្យ និងមានសេចក្តីសម្រេចពីតុលាការរួចហើយ នោះវត្ថុទាំងនោះនឹងត្រូវបានប្រគល់ត្រឡប់មកវិញ។

## កថាភាគទី២៖ ដំណើរការឆែកឆេរ

ការចុះឆែកឆេរដើម្បីស្វែងរកបទល្មើស គឺមានលក្ខណៈស្មុគស្មាញ និងត្រូវតែរៀបចំដំណើរការឲ្យបានត្រឹមត្រូវ និងគោរពតាមនីតិវិធីដែលបានកំណត់។

### ចំណុចទី១៖ លក្ខខណ្ឌនៃការឆែកឆេរ

បទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀនជាបទល្មើសពិសេស ហើយវាជាបដិបញ្ញត្តិនឹងលក្ខខណ្ឌទូទៅនៃការឆែកឆេរ ដោយមិនទាមទារឲ្យគោរពនៅនឹងលក្ខខណ្ឌពេលវេលានៃការចុះឆែកឆេរនោះទេ។

ចំណុចនេះ គឺមានន័យថា មន្ត្រីមានសមត្ថកិច្ចអាចចុះធ្វើការឆែកឆេរនៅពេលណាក៏បាន ដោយអាចធ្វើការឆែកឆេរមុនម៉ោង៦ព្រឹក និងក្រោយម៉ោង៦ល្ងាច [18] ដែលវាជាមានលក្ខណៈខុសប្លែកពីបទល្មើសទូទៅ ដែលទាមទារឲ្យធ្វើការគោរពពេលវេលានៃការឆែកឆេរ ខាងលើនេះ ដោយសារថា បទល្មើសពិសេសនេះ ប្រសិនជាទាមទារឲ្យគោរពពេលវេលានៃការឆែកឆេរ នោះតម្រុយនៃភស្តុតាងនឹងអាចបាត់បង់។ យើងដឹងហើយថាគ្រឿងញៀន ជាប្រភេទថ្នាំដែលអាចងាយស្រួល បំបាត់តម្រុយពិរុទ្ធភាព និងអាយយកទៅលាក់បំភាន់ភ្នែក ដូច្នេះទើបបទល្មើសពិសេសនេះ មិនទាមទារឲ្យគោរពពីពេលវេលានៃការឆែកឆេរនោះទេ។

### ចំណុចទី២៖. នីតិវិធីនៃការចុះឆែកឆេរ

ជាគោលការណ៍ ការដឹកនាំការឆែកឆេរ អាចធ្វើបានតាមរយៈការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបឋម ដោយមានការប្រើប្រាស់ភ្នាក់ងារសម្ងាត់។ ក្នុងករណីបទល្មើសជាក់ស្តែងមន្ត្រីនគរបាល

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៩១ កថាខណ្ឌទី៣

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

យុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងតែទទួលបាននូវការអនុញ្ញាតពីព្រះរាជអាជ្ញា បើទោះបីជាមានការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។[19] ការឆែកឆេរ ត្រូវធ្វើនៅចំពោះអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវតែចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលសាក្សីនោះមិនអាចជា នគរបាល ឬ ក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះទេ។

រីឯការឆែកឆេរ ចំពោះករណីបទល្មើសមិនជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចឆែកឆេរបាន លុះត្រាតែមានការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង។[20]

ករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឲ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា ត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ។ ការឆែកឆេរ ត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។សាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា ដែលមិនអាចជានគរបាលយ ឬកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរឡើយ។

បន្ទាប់ពីបានធ្វើការឆែកឆេររួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលនៅក្នុងនោះត្រូវមានចុះដូចជា[21]៖

- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាត
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ

**ចំណុចទី៣៖ ក្រុមប្រតិបត្តិការណ៍ចូលរួម**

ការចុះ ឆែកឆេរ ដែលដឹកនាំដោយព្រះរាជអាជ្ញា តែងតែមានការចូលរួមពីអាជ្ញាធរដែលមានជាប់ពាក់ព័ន្ធ ដែលជាទូទៅមានដូចជា៖

- អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន
- នាយការិយាល័យផ្សព្វផ្សាយអប់រំ
- អធិការរងនគរបាល

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៩១

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា២២៣

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៩១ កថាខណ្ឌ៤

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាគ្រាជ្

- ចៅសង្កាត់
- នាយប៉ុស្តិ៍នគរបាល
- មេភូមិ

# ផ្នែកទី៣៖ ការធ្វើតេស្ត និង ការវេចខ្ចប់

គ្រឿងញៀនដែលបានចាប់បាន ត្រូវតែធ្វើតែធ្វើការវេចខ្ចប់ឲ្យបានត្រឹមត្រូវ ដើម្បីការពារកុំឲ្យខូចខាតនូវទ្រង់ទ្រាយ និងសារធាតុរបស់វា។ បន្ទាប់ពីវេចខ្ចប់រួច និងចាប់ផ្តើមឈានទៅរកធ្វើតេស្ត ដើម្បីអាចកំណត់បានថាតើវាពិតជាប្រភេទគ្រឿងញៀនពិតប្រាកដមែនដែរឬទេ?

## កថាភាគទី១៖ ការធ្វើតេស្តបឋម

ដើម្បីដឹងថាវត្ថុតាងដែលចាប់បានជាគ្រឿងញៀននោះ វាទាមទារឲ្យធ្វើតេស្តពីលទ្ធផលនៃគ្រឿងញៀន ហើយទើបអាចបន្តនីតិវិធីតាមផ្លូវច្បាប់បន្តទៀត។

### ចំណុចទី១៖ គណៈកម្មការចូលរួម

គ្រឿងញៀនដែលចាប់បាន ទាមទារឲ្យការត្រួតពិនិត្យបច្ចេកទេស ឬវិទ្យាស្រាស្ត្រដែលមិនអាចបង្អង់បានដើម្បីធ្វើការត្រួតពិនិត្យ ដែលជាទូទៅសមាសភាពដែលបានចូលរួមជាទូទៅមានដូចជា៖

- នាយការិយាល័យវិទ្យាស្រាស្ត
- នាយការិយាល័យស្រាវជ្រាវប្រឆាំងគ្រឿញញៀន
- នាយរងការិយាល័យស្រាវជ្រាវគ្រឿងញៀន
- ជំនួយការនានា

### ចំណុចទី២៖ តេស្តពណ៌សម្រាប់ជំហានដំបូង

ដំណាក់កាលដំបូង ដើម្បីស្វែងរកតម្រុយពិរុទ្ធភាពចំពោះបទល្មើសដែលមានសារធាតុញៀន ឬអត់នោះ វាទាមទារឲ្យធ្វើការធ្វើតេស្តពណ៌សម្រាប់ជំហានដំបូងបំផុត នៅពេលដែលសមត្ថកិច្ចចាប់វត្ថុតាងបាន។

ជាទូទៅវត្ថុតាងដែលចាប់បាន ត្រូវបានយកទៅធ្វើតេស្តនៅការិយាល័យកណ្តាលប្រឆាំងគ្រឿងញៀន ហើយចាប់ផ្តើមធ្វើតេស្តជំហានដំបូងនោះទៅកន្លែងធ្វើតេស្តគ្រឿងញៀន។[22]

**ក. ពណ៌សម្រាប់ធ្វើតេស្ត**

តេស្តពណ៌ ដែលមន្ត្រីអនុវត្តច្បាប់ប្រើសម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជាជំហានដំបូងមានដូចជា[23]៖

- ម៉ាគី តេស្ត(Marquis)
- ស៊ីម៉ុន តេស្ត(Simon)
- ស្កុត តេស្ត(Scott test)
- ហ្វាសប្លូ ប៊ីសាល៏ តេស្ត(Fast Blue B Salt)
- ចិនកាវ តេស្ត(Chenkao)

**ខ.លទ្ធផលជាបឋម**

ការធ្វើ តេស្តជំហានដំបូងមិនស្មុគស្មាញ និងមិនចាំបាច់ចំណាយពេលវេលាយូរផងដែរ ដោយការធ្វើតេស្តនេះអាចដឹងបានលទ្ធផលភ្លាមៗ។

ដើម្បីអាចទទួលបានលទ្ធផលធ្វើតេស្តជំហានដំបូង លើសារធាតុសង្ស័យជាគ្រឿងញៀន ត្រូវតែធ្វើលិខិតស្នើសុំតាមគំរូដែលបានកំណត់ ដើម្បីធ្វើការអនុញ្ញាតឲ្យផ្នែកជំនាញពិនិត្យធ្វើតេស្តបឋម ដើម្បីសន្និដ្ឋាន ឲ្យបានច្បាស់លាស់ នូវប្រភេទសារធាតុសង្ស័យគ្រឿងញៀន។[24]

ចំពោះលទ្ធផលធ្វើតេស្តជំហានដំបូង លើសារធាតុសង្ស័យគ្រឿងញៀននឹងធ្វើការបញ្ជាក់ពីការិយាល័យនគរបាលប្រឆាំងគ្រឿងញៀន ដោយបញ្ជាក់ពីប្រភេទនៃសារធាតុធ្វើតេស្ត និងធ្វើសេចក្តីសន្និដ្ឋានចំពោះផលវិជ្ជមាន។

ឧទាហរណ៍៖ លទ្ធផលតេស្តជំហានដំបូងចំពោះថ្នាំមេតាំហ្វេតាមីន(ប្រភេទសារធាតុធ្វើតេស្ត Marquis Test ដែលមានពណ៌ឈាមជ្រូក លទ្ធផលវិជ្ជមាន គឺជាមេតាំហ្វេតាមីន)។

[23] ឧត្តមសេនីយឯក វេជ្ជ.មាស វិរិទ្ធ ៖ ការយល់ដឹងពីលក្ខណៈបច្ចេកទេសទាក់ទងនឹងបទល្មើសគ្រឿងញៀន ទំព័រ៩

[24] លិខិតស្នើសុំធ្វើតេស្តជំហានដំបូងលើសារធាតុសង្ស័យគ្រឿងញៀន 2B A006 និង លិខិតរបស់ស្នងការនគរបាលខេត្តព្រះសីហនុស្តីពីលិខិតស្នើសុំធ្វើតេស្តជំហានដំបូងលើសារធាតុសង្ស័យគ្រឿងញៀន

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្ញ

### ខ១.វិធីយកសំណាកសម្រាប់ធ្វើតេស្តពណ៌[25]

ការដកសំណាកសម្រាប់ការធ្វើតេស្តជំហានដំបូង អាចធ្វើក្រោមរូបភាពដូចខាងក្រោមនេះ៖

**១.ចំពោះសំណាកជាម្សៅ៖**

យកសំណាកយ៉ាងតិចបំផុត ដាក់ក្នុងចានវិភាគ សម្រាប់ធ្វើតេស្តពណ៌ ប៉ុន្តែករណីដែលចង់ធ្វើម្តងទៀត ត្រូវបង្កើនបរិមាណឲ្យបានប៉ុនក្បាលឈើគូស។

**២.ចំពោះសំណាកជាគ្រាប់ ឬជាវត្ថុធាតុរឹង ឬជាដុំរឹង៖**

ត្រូវកាត់វាជាដុំតូចៗ រួចកិនឲ្យម៉ត់ ហើយយកបរិមាណយ៉ាងតិចបំផុត ដាក់ក្នុងចានវិភាគសម្រាប់ធ្វើតេស្តពណ៌។

**៣.ចំពោះសំណាកជាថ្នាំគ្រាប់មានស្រោបពីក្រៅ៖**

ត្រូវដកសំបកគ្រាប់ថ្នាំថ្មមៗ រួចយកម្សៅនៅខាងក្នុងនោះ យ៉ាងតិចបំផុត ដាក់ក្នុងចានវិភាគសម្រាប់ធ្វើតេស្តពណ៌។

**៤.ចំពោះសំណាកជារុក្ខជាតិ៖**

ត្រូវកាត់យកតែចំណែកតូច រួចកិន ឬបុកឲ្យម៉ត់ ហើយយកកំទេចរុក្ខជាតិនោះយ៉ាងតិចបំផុត ដាក់ក្នុងចានវិភាគសម្រាប់ធ្វើតេស្តពណ៌។

**៥.ចំពោះសំណាកជាបារី៖**

ត្រូវហែកក្រដាសស្រោបបារីនោះចេញ រួចយកស្លឹកថ្នាំនោះបន្តិចទៅកិន ឬបុកឲ្យម៉ត់ ហើយយកកំទេចនោះយ៉ាងតិចបំផុត ដាក់ក្នុងចានវិភាគសម្រាប់ធ្វើតេស្តពណ៌។

### ខ២.របៀបធ្វើតេស្តពណ៌

ដើម្បីអាចដឹងជាលទ្ធផលនៃប្រភេទសារធាតុញៀនណាមួយ អ្នកបច្ចេកទេស នឹងចាប់ផ្តើមធ្វើតេស្ត ដោយដាក់សំណាកបន្តិចទៅក្នុងចានវិភាគ អោយចំកណ្តាល ដោយត្រូវដកយកសំបកចេញសិន ឬ បើសិនជាគ្រាប់ ឬដុំម្សៅរឹង ឬដុំជ័រ ត្រូវខ្ចប់នឹងក្រដាសស្អាតហើយបុកឲ្យបានម៉ត់។[26]

[25] ឧត្តមសេនីយឯក វេជ្ជ.មាស វិរិទ្ធ ៖ ការយល់ដឹងពីលក្ខណៈបច្ចេកទេសទាក់ទងនឹងបទល្មើសគ្រឿងញៀន ទំព័រ១២

[26] ឧត្តមសេនីយឯក វេជ្ជ.មាស វិរិទ្ធ ៖ ការយល់ដឹងពីលក្ខណៈបច្ចេកទេសទាក់ទងនឹងបទល្មើសគ្រឿងញៀន ទំព័រ១៣

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

## កថាភាគទី២៖ ការវេចខ្ចប់

វត្ថុតាងដែលចាប់បាន មិនមែនអាចយកទៅទុកដាក់ ឬ ទុកចោល បាននោះទេ វាទាមទារឲ្យមានការរៀបចំទុកដាក់ឲ្យបានល្អត្រឹមត្រូវ ដើម្បីរក្សាទុកនូវគុណភាព និងរក្សាការដកហូតវត្ថុតាងដែលជាសារធាតុញៀនទាំងនោះនៅដំណាក់កាលចៅក្រមស៊ើបសួរបន្តទៀត។

### ចំណុចទី១៖ របៀបនៃលក្ខណៈវេចខ្ចប់

គ្រឿងញៀនដែលចាប់បាន ត្រូវបានវេចខ្ចប់ទៅតាមប្រភេទរបស់វា គឺមានន័យថាប្រសិនជាប្រភេទគ្រាប់ ត្រូវវេចខ្ចប់ក្នុងមួយកញ្ចប់របស់វា ហើយប្រសិនជាប្រភេទម្សៅ ត្រូវតែរក្សាទុកតាមប្រភេទរបស់វា។

ការបែងចែក ប្រភេទវេចខ្ចប់ទៅតាមចំណាត់ថ្នាក់របស់វា ជាការងាយស្រួលក្នុងការ រក្សាទុកគុណភាព និងងាយស្រួលចាត់ចែងទៅតាមប្រភេទរបស់វា នៅពេលដែលធ្វើការត្រួតពិនិត្យ។

ការវេចខ្ចប់គ្រឿងញៀនទាំងនោះ ត្រូវតែដាក់ក្នុងស្រោមសំបុត្រឲ្យបានត្រឹមត្រូវ និងមានចុះហត្ថលេខារបស់គណៈកម្មការដែលបានចូលរួម និងជៀសវាងការបើកផ្តេសផ្តាសនៅពេលដែលធ្វើការវេចខ្ចប់រួច ដើម្បីការពារកុំឲ្យបាត់បង់ ឬធ្វើការដកហូតផ្តេសផ្តាស ដែលនាំឲ្យប៉ះពាល់ដល់វត្ថុតាងសម្រាប់ដំណើរការស៊ើបអង្កេត។

### ចំណុចទី២៖ កំណត់ហេតុ

នៅពេលដែលវេចខ្ចប់គ្រឿងញៀន ត្រូវតែធ្វើកំណត់ហេតុដើម្បីបញ្ជាក់ពីភស្តុតាងដែលចាប់យក ដោយមានការចុះហត្ថលេខាដើម្បីធ្វើជាសាក្សីធ្វើការដឹងលឺ។ ក្នុងកំណត់ហេតុនេះត្រូវបញ្ជាក់ពីកាលបរិច្ឆេទការដកហូតគ្រឿងញៀន និងអត្តសញ្ញាណនៃជនល្មើសដែលចាប់យក។

## កថាភាគទី៣៖ ការបិទស្លាក និង ការថែរក្សាវត្ថុតាង

វត្ថុតាងដែលចាប់បានជាគ្រឿងញៀន ត្រូវតែធ្វើការបិទស្លាកឲ្យបានត្រឹមត្រូវ ដើម្បីរក្សាទុកឲ្យស្ថាប័នតុលាការចំណាត់ការទៅតាមនីតិវិធីរបស់តុលាការ។

### ចំណុចទី១៖ នរណាមានតួនាទីថែរក្សា?

រដ្ឋបាលតុលាការ ជាអ្នកទទួលទុកគ្រឿងញៀន និងរក្សាទុកឲ្យបានត្រឹម បន្ទាប់ពីបានធ្វើការដកយកទៅធ្វើតេស្តជាបឋមរួចហើយ។

### ចំណុចទី២៖ ការការពារកុំឲ្យបាត់បង់

ដើម្បីការការពារកុំឲ្យបាត់បង់វត្ថុតាងដែលចាប់បានពីមន្ត្រីនគរបាលយុត្តិធម៌ ក្រឡាបញ្ជីត្រូវតែធ្វើកំណត់ហេតុទទួលវត្ថុតាង។

កំណត់ហេតុនេះ ជាការបញ្ជាក់ពីការត្រួតពិនិត្យពីភិនភាគវត្ថុតាងដែលទាក់ទិននឹងសំណុំរឿងព្រហ្មទណ្ឌដែលបានទទួលទាំងគ្រឿងញៀន ឬវត្ថុដែលពាក់ព័ន្ធដទៃទៀតដែលត្រូវចាប់បាន។

## ផ្នែកទី៤៖ ការដកសំណាក

ដើម្បីឈានទៅរកស្វែងការពិត ថាតើវត្ថុតាងដែលចាប់បានពីការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ជាប្រភេទគ្រឿងញៀនពិតប្រាកដដែរឬទេនោះ វាទាមទារឲ្យធ្វើការដកសំណាកពីព្រោះថាការធ្វើតេស្តជាបឋមមិនទាមទារឲ្យមានភាពជឿជាក់ និងច្បាស់លាស់ទាំងអស់នោះទេ។

### កថាភាគទី១៖ នរណាខ្លះមានសិទ្ធិចូលរួមដកសំណាក?

ការដកសំណាកគ្រឿងញៀនដែលបានចាប់យក និងសង្ស័យថាជាថ្នាំញៀនអាចធ្វើបាន លុះត្រាតែមានការចូលរួមពីស្ថាប័នសំខាន់ៗដែលមានការពាក់ព័ន្ធ។

### ចំណុចទោល៖ ភាគីពាក់ព័ន្ធ

សមាសភាពចូលរួមក្នុងការដកសំណាកវត្ថុចាប់យក ត្រូវមានការចូលរួមពីអ្នកដែលពាក់ព័ន្ធដែលមានដូចជា៖

- ចៅក្រមស៊ើបសួរ
- ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង
- នាយកក្រឡាបញ្ជី និងក្រឡាបញ្ជី
- មន្ត្រីនគរបាលយុត្តិធម៌ស្នងការដ្ឋាននគរបាល ឬមន្ត្រីផ្នែកការិយាល័យស្រាវជ្រាវនិងប្រឆាំងគ្រឿងញៀន
- ជនត្រូវចោទ

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

## កថាភាគទី២៖ នីតិវិធីដកសំណាក

គ្រឿងញៀនដែលចាប់បាន ត្រូវបានយកទៅធ្វើការដកសំណាកក្រោមការដឹកនាំរបស់ចៅក្រមស៊ើបសួរ ក្នុងគោលដៅស្វែងរកការពិតថាតើវត្ថុតាងដែលសង្ស័យថាជាសារធាតុញៀននោះជាគ្រឿងញៀនពិតប្រាកដឬទេ?

### ចំណុចទី១៖ វិធីយកសំណាកសម្រាប់ធ្វើតេស្ត

ការដកសំណាកមិនមែនចេះតែដកនោះទេ តែវាចាំបាច់ត្រូវតែកំណត់ពីបរិមាណ និងចំនួនត្រឹមត្រូវសម្រាប់ដកយកទៅធ្វើកោសល្យវិច័យ និងលក្ខណៈបច្ចេកទេស ដើម្បីឈានទៅរកការធ្វើកោសល្យវិច័យ។

ការដកសំណាកជាទូទៅ ធ្វើដោយមានការចូលរួមពីគណៈកម្មការដែលពាក់ព័ន្ធ ដោយដកចេញពីការវេចខ្ចប់វត្ថុតាងដែលបានប្រគល់ពីមន្ត្រីនគរបាលយុត្តិធម៌ បន្ទាប់មកចៅក្រមស៊ើបសួរនឹងអនុញ្ញាតឲ្យធ្វើការថ្លឹងសារធាតុញៀនទាំងនោះ និងឲ្យក្រឡាបញ្ជីធ្វើកំណត់ត្រាពីការដកហូត។

### ចំណុចទី២៖ ការបញ្ចប់នីតិវិធី?

មុនបញ្ចប់កិច្ចនីតវិធីនៃការដកហូតសំណាក ក្រឡាបញ្ជីត្រូវតែធ្វើកំណត់ហេតុស្តីពីការដកហូតសំណាកវត្ថុចាប់យកដែលសង្ស័យថាជាថ្នាំញៀន។ កំណត់ហេតុនេះ នឹងបញ្ជាក់ពីនីតិវិធីនៃការដកហូត ចំនួនដែលត្រូវដកយកពីបរិមាណសរុប និងការធ្វើការបិទវេចខ្ចប់។ បន្ទាប់ពីបានធ្វើរួចរាល់ ត្រូវមានការចុះហត្ថលេខារបស់ជនទាំងនោះដែលបានចូលរួម។

ជារួមទៅ បន្ទាប់ពីបានបញ្ចប់នីតវិធីនៃការដកសំណាក ត្រូវតែវេចខ្ចប់សកំណាកបញ្ជូនមកធ្វើកោសលវិច័យដូចខាងក្រោម[27]៖

- ត្រូវដាក់សំណាកទៅក្នុងថង់ផ្លាស្ទិចតូចរួចខ្ចប់ក្នុងស្រោមសំបុត្រតូច ហើយបិទជិតដោយមានហត្ថលេខាអ្នកចូលរួម និងស្នាមមេដៃរបស់ជនល្មើស ដោយធ្វើបែបនេះឲ្យបានបីកញ្ចប់ ដែលកញ្ចប់នីមួយៗត្រូវតែមានតម្លៃស្មើៗគ្នាទាំងបរិមាណ និងទាំងលក្ខណៈរូប។
- បន្ទាប់មកច្រកកញ្ចប់ទាំង០៣កញ្ចប់ ទៅក្នុងស្រោមសំបុត្ររក្សាវត្ថុតាង របស់អគ្គលេខាធិការដ្ឋាន[28] ដែលបានផ្តល់ជូន ដោយបំពេញព័ត៌មាននៅលើស្រោមសំបុត្រនោះឲ្យបានគ្រប់ និងមានហត្ថលេខាអ្នកចូលរួម និងស្នាមមេដៃរបស់ជនល្មើស។

---

[27] ឧត្តមសេនីយឯក វេជ្ជ.មាស វីរិទ្ធ ៖ ការយល់ដឹងពីលក្ខណៈបច្ចេកទេសទាក់ទងនឹងបទល្មើសគ្រឿងញៀន ទំព័រ២១

[28] អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន៖កញ្ចប់រក្សាវត្ថុតាង

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

វត្ថុតាងដែលបានវេចខ្ចប់ និងបិទជិតរួច ត្រូវបានបញ្ជូនទៅធ្វើកោសល្យវិច័យនិងបញ្ជូនទៅធ្វើតេស្តនៅអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀននៅរាជធានីភ្នំពេញ។

## កថាភាគទី៣៖ ចរិតលក្ខណៈ និង សមាសភាពមិនសុទ្ធនៃគ្រឿងញៀន

ការធ្វើកោសលវិច័យជាបច្ចេកទេសផ្នែកវិទ្យាសាស្ត្រជឿនលឿនដែលអាចទទួលបាននូវលទ្ធផលមួយជាក់លាក់ នឹងអាចបញ្ជាក់បានពីចរិតលក្ខណៈ និងសមាសភាពសុទ្ធ ឬមិនសុទ្ធនៃគ្រឿងញៀនដែលចាប់បានពីបទល្មើស។

### ចំណុចទី១៖កោសលវិច័យ

ការធ្វើកោសល្យវិច័យជាសមត្ថកិច្ចរបស់អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលនឹងចាត់តាំងអ្នកជំនាញសម្រាប់ធ្វើកោសល្យវិច័យ។

#### ក.អ្នកជំនាញធ្វើកោសល្យវិច័យ

ចៅក្រមស៊ើបសួរ ត្រូវធ្វើសំណើរចាត់តាំងអ្នកជំនាញខាងថ្នាំញៀន ធ្វើកោសលវិច័យដែលបានដកសំណាកចេញពីកញ្ចប់វត្ថុតាងទៅកាន់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ជាគោលការណ៍ចៅក្រមស៊ើបសួរគ្រាន់តែជាអ្នកធ្វើសំណើរសុំចាត់តាំងអ្នកជំនាញតែប៉ុណ្ណោះ រីឯការកំណត់ថានរណាជាអ្នកដែលមានសមត្ថកិច្ចនោះ គឺត្រូវបានកំណត់ដោយសេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀន របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជ្រើសរើសមន្ត្រីជំនាញដែលកំពុងតែបំរើការនៅមន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ ដែលការទទួលស្គាល់នេះមានរយៈពេល០១ឆ្នាំ ហើយអាចបន្តជាថ្មីបាន តាមការស្នើសុំដែលការស្នើសុំនេះបន្តជាថ្មី ត្រូវធ្វើយ៉ាងណាយឺតបំផុត០១ខែមុនអស់សុពលភាពនៃការទទួលស្គាល់។

ការទទួលស្គាល់នេះអាចត្រូវដកហូតវិញ ក្នុងករណីសាមីខ្លួនមិនបានបំពេញលក្ខខ័ណ្ឌសមត្ថភាពវិជ្ជាជីវៈសំភារៈបច្ចេកទេសការងារ អព្យាក្រិតភាព និងសីលធម៌ ដូចដែលមានកំណត់ដោយស្មារតីនៃកិច្ចប្រជុំអន្តរក្រសួងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការទទួលស្គាល់អ្នកជំនាញធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀន។[29]

[29] សេចក្តីសម្រេចស្តីពី៖ការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀន របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចូលជាធរមានថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ គ្រង់ប្រការ២

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

ឧទាហរណ៍៖ សេចក្តីសម្រេច ឆ្នាំ២០១៥ ទទួលស្គាល់អ្នកជំនាញ៖[30]

១.ឯកឧត្តម ឧត្តមសេនីយ៍ទោ វេជ្ជបណ្ឌិត **មាស វិរិទ្ធ** ប្រធានមន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

២.លោកស្រី វិស្វករគីមី **ឈឹម សិទ្ធិបុណ្យរិទ្ធ** អនុប្រធានមន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

៣.លោក វេជ្ជបណ្ឌិត **ជុន ហុងពាន** ប្រធានការិយាល័យបច្ចេកទេស មន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

៤.លោក ឱសថការីឧត្តម **ង៉ែត មោនីនោ** មន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

អ្នកជំនាញអាចបំបែកស្លាកបិទ ដើម្បីធ្វើកោសលវិច័យបាន ហើយប្រសិនបើកោសលវិច័យនេះអាចធ្វើឲ្យខូចខាត ឬវិនាសដល់វត្ថុដែលចាប់បាននោះ អ្នកជំនាញត្រូវជូនពត៌មានមកដល់ចៅក្រមស៊ើបសួរ និងសុំការអនុញ្ញាតពីចៅក្រមនេះ មុននឹងចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន។[31]

## ខ.លទ្ធផលនៃកោសលវិច័យ

អ្នកជំនាញបំពេញបេសកម្មរបស់ខ្លួន ក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ ហើយអ្នកជំនាញត្រូវជូនពត៌មានដល់ចៅក្រមស៊ើបសួរ អំពីការប្រព្រឹត្តទៅនៃបេសកម្មរបស់ខ្លួនដូចជាករណីការលំបាកដែលបានជួបប្រទះជាដើម។[32] ប្រសិនជាអ្នកជំនាញមិនគោរពរយៈពេលដែលកំណត់របស់ចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរចាត់អ្នកជំនាញផ្សេងទៀតជំនួសអ្នកជំនាញនោះ ប៉ុន្តែប្រសិនជាកាលៈទេសៈតម្រូវនោះ ចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមដីកាសម្រេចឲ្យធ្វើការពន្យារពេលបាន។[33]

នៅពេលដែលការធ្វើកោសល្យវិច័យបានបញ្ចប់ អ្នកជំនាញធ្វើរបាយការណ៍ដែលក្នុងនោះ ត្រូវរៀបរាប់យ៉ាងច្បាស់លាស់អំពីប្រតិបត្តិការ និងការធ្វើសេចក្តីសន្និដ្ឋាន។ ករណីដែលអ្នកជំនាញ បំបែកស្លាកដើម្បីពិនិត្យវត្ថុដែលចាប់យក អ្នកជំនាញត្រូវចុះនិទ្ទេសអំពីបញ្ហាក្នុងរបាយការណ៍។ ក្រៅពីនេះកាលណាអ្នកជំនាញប្រគល់

[30] សេចក្តីសម្រេចស្តីពី៖ការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀន របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចូលជាធរមានថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ ត្រង់ប្រការ១

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៦៥ កថាខណ្ឌ៣

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៦៦ កថាខណ្ឌ១

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៦៦ កថាខណ្ឌ២

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ

របាយការណ៍នោះ ត្រូវតែប្រគល់ដល់ចៅក្រមស៊ើបសួរវិញនូវវត្ថុដែលចាប់យក។ ចំពោះករណីដែល ស្លាកត្រូវបានបំបែក ចៅក្រមស៊ើបសួរត្រូវបិទស្លាកជាថ្មីលើវត្ថុនោះ ចៅក្រមស៊ើបសួរត្រូវតែធ្វើកំណត់ហេតុប្រគល់សងនូវវត្ថុ និងការបិទស្លាកជាថ្មីលើវត្ថុនោះ។[34]

ជាគោលការណ៍ កោសលវិច័យតាមបច្ចេកទេសវិទ្យាសាស្ត្រដោយអ្នកជំនាញ ដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌ ដើម្បីឲ្យបានដឹងអំពីប្រភេទធាតុផ្សំ និងកម្រិតធាតុសកម្មរបស់គ្រឿងញៀន ដែលបានដកយកត្រូវធ្វើឲ្យបានឆាប់រហ័សបន្ទាប់ពីដកយក ដើម្បីជៀសវាងការខូចខាត និងការថយចុះនូវសារធាតុ រូបវត្ថុ និងជាតិគីមីនៃវត្ថុនោះ។ ជាពិសេស អ្នកជំនាញត្រូវតែបញ្ជាក់ក្នុងរបាយការណ៍របស់ខ្លួននូវចំនួនសំណាកដែលគេបានប្រគល់ឲ្យអំពីប្រភេទ និងទម្ងន់នៃគ្រឿងញៀនដែលមាននៅក្នុងសំណាកនីមួយៗ ចំនួនសំណាកដែលបានប្រើប្រាស់ធ្វើកោសល្យវិច័យ ហើយប្រសិនបើមាន ត្រូវបញ្ជាក់ចំនួនសំណាកដែលបានប្រមូលមកវិញសល់ពីការធ្វើកោសល្យវិច័យ និងការប្រែប្រួលទៅលើសំណាកទាំងនោះ។[35]

### គ.ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសល្យវិច័យ

នៅពេលដែលរបាយការណ៍កោសលវិច័យត្រូវបានធ្វើរួចហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា រីឯរបាយការណ៍កោលវិច័យត្រូវបានដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ។[36]ចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ និងមេធាវី ឬ អាចហៅដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីប្រាប់ឲ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ។

ក្រៅពីនេះ ចៅក្រមស៊ើបសួរអាចកំណត់រយៈពេល មិនតិចជាង១០ថ្ងៃ ដើម្បីទទួលការដាក់ពាក្យសុំធ្វើកោសល្យ វិច័យបន្ថែម ឬប្រតិកោសលវិច័យ ពីសំណាក់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ប៉ុន្តែចៅក្រមស៊ើបសួរក៏មានសិទ្ធិក្នុងការ បដិសេធតាមពាក្យសុំខាងលើនេះ ដោយត្រូវធ្វើការសម្រេចតាមដីកាដោយមានសំអាងហេតុ ដែលត្រូវសម្រេចក្នុងរយៈពេល០៥ថ្ងៃសម្រាប់ព្រះរាជអាជ្ញា និង១ខែសម្រាប់ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

### ចំណុចទី២៖ ការសិក្សាពីលក្ខណៈនៃគ្រឿងញៀន

គ្រឿងញៀនដែលបានធ្វើកោសល្យវិច័យរួច នឹងបង្ហាញពីលទ្ធផលវិជ្ជមាន ឬអវិជ្ជមានដើម្បីអាចបញ្ជាក់ពីពិរុទ្ធភាពរបស់ជនល្មើស។ក្រៅពីការចង់បាននូវលទ្ធផលពីការធ្វើកោសលវិច័យ វាចាំបាច់ណាស់ដែលអាជ្ញាធរ

34 ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៦៨

35 ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ ត្រង់ប្រការ៨៣

36 ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៧០

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្ញ

ប្រយុទ្ធប្រឆាំងគ្រឿងញៀន សិក្សាពីលក្ខណៈគ្រឿងញៀន ដើម្បីអាចស្វែងរកមុខសញ្ញាដទៃទៀតដែលមានទំនាក់ទំនងគ្នាជាមួយនឹងគ្រឿងញៀនដែលបានធ្វើកោសលវិច័យ។

**ក. តើសំណាកទាំងនោះមានទំនាក់ទំនងគ្នាឬទេ?**

សំណាកដែលបានធ្វើកោសលវិច័យសុទ្ធសឹងតែមានសញ្ញាណពិសេសអាចសម្គាល់បានពីប្រភពរបស់វា និងទំនាក់ទំនងផ្សេងទៀត។

អ្នកជំនាញត្រូវតែសិក្សាថា តើសំណាកគ្រឿងញៀនពីរ ឬច្រើនមានជាប់ទាក់ទងគ្នាឬទេ?

ឧទាហរណ៍៖ តើទំនាក់ទំនងនេះផ្តល់នូវចំណងសម្ព័ន្ធភាពរវាងអ្នកចែកចាយណាមួយ និងអ្នកប្រើប្រាស់គ្រឿងញៀនណាម្នាក់ឬទេ?

**ខ.ការផ្តល់ព័ត៌មានដ៏មានប្រយោជន៍**

ការធ្វើសំណាកនេះ អាចផ្តល់នូវព័ត៌មានដែលមានប្រយោជន៍ជាច្រើនដូចខាងក្រោមនេះ៖

- បង្កើតនូវទំនាក់ទំនងច្បាស់លាស់រវាងសំណាកពីរ ឬច្រើន
- ធ្វើចំណាត់ថ្នាក់នូវសំណាកដែលបានមកពីការរឹបអូសផ្សេងៗគ្នាទៅជាក្រុមនៃសំណាក ដែលមានការទាក់ទងគ្នា ដែលបង្កើតជាបណ្តាញចែកចាយ។
- ប្រាប់ពីប្រភពរួមមានទាំងទីតាំងភូមិសាស្ត្រនៃប្រភពដើមរបស់សំណាក ដែលពត៌មាននេះអាចត្រូវបានប្រើ ធ្វើជាភស្តុតាង ឬអាចត្រូវបានប្រើជាប្រភពមួយសមរម្យអាចស៊ើបយកពត៌មានសំងាត់ដើម្បីបញ្ជាក់សំណាកដែលមានប្រវត្តិរូបមួយ(ដូចគ្នា)
- ការសិក្សានូវលក្ខណៈគ្រឿងញៀន គឺដើម្បីតាមដាន និងកំណត់រកវិធីសាស្ត្រដែលគេបានប្រើក្នុងការផលិតគ្រឿងញៀនដោយលួចលាក់ និងសារធាតុគីមីដែលយកមក។

# ជំពូកទី២៖ ការចាត់ចែងក្រោយការបង្ក្រាបបទល្មើស

បន្ទាប់ពីចៅក្រមស៊ើបសួរធ្វើចំណាត់ការនីតិវិធីរួចរាល់ នោះសំណុំរឿងត្រូវបានបញ្ជូនទៅឲ្យចៅក្រមជំនុំជម្រះ ដើម្បីធ្វើសេចក្តីសម្រេចក្នុងការផ្តន្ទាទោស និងការចាត់ចែងគ្រឿងញៀន ថាតើត្រូវបំផ្លាញចោល ឬចំណាត់ការបែបណា។

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្ជ

# ផ្នែកទី១៖ ការអនុវត្តទោស

ចៅក្រមជំនុំជម្រះនឹងធ្វើការសម្រេចពីទោសដែលត្រូវអនុវត្តចំពោះពិរុទ្ធជន ថាតើប្រភេទទោសណាមួយ ដែលត្រូវយកមកដាក់ឲ្យសមតាមកម្រិតនៃសារធាតុញៀនដែលបានប្រព្រឹត្ត និងជួញដូរដោយខុសច្បាប់។

## កថាខណ្ឌទី១៖ ពន្ធនាគារ និងពិន័យ

ការអនុវត្តទោសចំពោះបទល្មើសនេះវាគឺជា បទល្មើសដែលមានលក្ខណៈពិសេស ហើយចៅក្រមត្រូវសម្រេចទោសដែលមានលក្ខណៈខុសប្លែកពីការអនុវត្តទោសនៃបទល្មើសធម្មតា។

### ចំណុចទី១.ការកម្រិតទោស

ចៅក្រមមានឆន្ទានុសិទ្ធិក្នុងការសម្រេចការដាក់ទោស ហើយតុលាការប្រកាសទោសផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស, ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ, ទៅលើសភាពផ្លូវចិត្ត, ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុ និងព្រមទាំងទៅលើកិរិយាមាយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស។[37] ចៅក្រមជំនុំជម្រះខ្លះ ដាក់ទោសទាំងទោសពន្ធនាគារផង ទោសពិន័យជាប្រាក់ផង ហើយករណីខ្លះចៅក្រមក៏ធ្វើការព្យួរទោសផងដែរ ដែលការសម្រេចទាំងនេះអាស្រ័យទៅលើព្យសនកម្មនៃបទល្មើស និងកម្រិតនៃការប្រព្រឹត្តបទល្មើស។

ខាងក្រោមនេះជា ចំនួនទោសដែលត្រូវផ្តន្ទាទោសត្រូវបានកំណត់ដោយបទបញ្ញត្តិដែលចែងក្នុងមាត្រា ៤០កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៖

| **១.ពន្ធនាគារ** | **២.ពិន័យប្រាក់** |
|---|---|
| ២ឆ្នាំ-៥ឆ្នាំ | ៤.000.000រ-១0.000.000រ |
| ៥ឆ្នាំ-១0ឆ្នាំ | ១0.000.000រ-២0.000.000រ- |
| ១0ឆ្នាំ-២0ឆ្នាំ | ២0.000.000រ-៤0.000.000រ |
| ២0ឆ្នាំ-៣0ឆ្នាំឬអស់មួយជិវិត | ៤0.000.000រ-១00.000.000រ |
| | |

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ត្រង់មាត្រា៩៦

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

### ចំណុចទី២.ការប្រកាសមូលទោស

ជាទូទៅការប្រកាសរបបមូលទោស ត្រូវបានដាក់ទោសទៅលើបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង ឬអាចដាក់ទោសទាំងពីរ ដែលតុលាការអាចប្រកាសដូចជា៖[38]

- ទោសដាក់ពន្ធនាគារ **និង**ទោសពិន័យជាមួយគ្នា ឬ
- ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ
- ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ

### ចំណុចទី៣.ការបង្ក្រាបបទល្មើសតាមបែបការសងសឹក

ការដាក់ទណ្ឌកម្មក្នុងកម្រិតអតិបរិមាខ្ពស់បំផុតនោះ វាមិនមែនជាវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាឲ្យសង្គម និងជាការអប់រំសម្រាប់ទណ្ឌិតនោះទេ ប៉ុន្តែករណីដែលកម្រិតដាក់ទោសដែលមានលក្ខណៈច្រើនហួសពីអំពើដែលទណ្ឌិតបានប្រព្រឹត្ត វាអាចប្រែក្លាយការជំរុញឲ្យមានការគុំគួន និងការសងសឹកនៅពេលដែលជនល្មើសបានចេញពីពន្ធនាគារ។

កត្តាទាំងនេះ ចៅក្រមដែលមានអំណាចឆន្ទានុសិទ្ធិក្នុងការសម្រេចដាក់ទោសជនណាម្នាក់ ត្រូវតែរិះគិត និងពិចារណាឲ្យបានល្អិតល្អន់ ដើម្បីកុំឲ្យពន្ធនាគារប្រែក្លាយទៅជាកន្លែងប្រែក្លាយជនល្មើសឲ្យប្រព្រឹត្តបទល្មើសកាន់តែធ្ងន់ធ្ងរ និងប្រមូលផ្តុំបក្សពួកក្រោយពេលចេញពីពន្ធនាគារ។

## កថាខណ្ឌទី២៖ ការហាមឃាត់មិនឱ្យប្រើទោសជំនួស និងទោសបន្ថែមជំនួស ឱ្យមូលទោស

មូលទោសចំពោះបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មិនអាចត្រូវបានជំនួសដោយទោសជំនួស ឬទោសបន្ថែម ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌដែលអាចអនុវត្តបានដូចបទល្មើសធម្មតានោះទេ។[39]

### ចំណុចទី១.ការប្រើប្រាស់ទោសជំនួស

ជាទូទៅ ទោសការងារសហគមន៍ត្រូវបានយកមកអនុវត្តជំនួសឲ្យមូលទោសបាន ហើយតុលាការដែលបានប្រកាសទោសការងារសហគមន៍ គឺមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ។ រីការស្តីបន្ទោសដែលតុលាការបានជំនួសឲ្យមូលទោស ក៏មិនអាចប្រកាសទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់បានទេ។[40]

---

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ត្រង់មាត្រា៩៧

[39] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចូលជាធរមានថ្ងៃទី ត្រង់មាត្រា២៧ និងមាត្រា២៨ កថាខណ្ឌទី២

[40] ក្រមព្រហ្មទណ្ឌ ចូលធរមានឆ្នាំ ត្រង់មាត្រា៩៨

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

ប៉ុន្តែចំពោះបទល្មើសពិសេសនេះ គោលការណ៍ខាងលើមិនត្រូវបានយកមកអនុញ្ញាតឲ្យជំនួសដោយទោសជំនួសបាននោះទេ ដោយសារតែថាបទល្មើសគ្រឿងញៀនជាបទល្មើសដែលមានការបង្ករឲ្យមានព្យសនកម្មដ៏ធំធេង។

### ចំណុចទី២.ការអនុវត្តទោសបន្ថែមជំនួសឲ្យមូលទោស

ចំពោះបទល្មើសទូទៅ ករណីដែលបទល្មើសដែលត្រូវបានផ្តន្ទាទោស ដោយទោសបន្ថែមមួយ ឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស ។[41] យ៉ាងណាមិញ ចំពោះបទល្មើសពិសេសនេះ បទបញ្ញាត្តិខាងលើនេះមិនអាចយកមកអនុវត្តបាននោះទេ ពីព្រោះថាមូលទោសចំពោះបទល្មើសនេះ មិនអាចត្រូវជំនួសដោយទោសបន្ថែមតាមលក្ខខ័ណ្ឌចែងក្នុងក្រមព្រហ្មទណ្ឌបានទេ។[42]

ជារួមទៅ នីតិករមានឆន្ទៈមិនចង់ឲ្យយកទាំងទោសបន្ថែម ឬទោសជំនួស មកអនុវត្តជំនួសឲ្យមូលទោសបានដូចបទល្មើសទូទៅនោះទេ ដោយសារថាបទល្មើសនេះជាបទល្មើសដែលបំផ្លាញមិនត្រឹមតែបុគ្គលដែលប្រើប្រាស់គ្រឿងញៀនផ្ទាល់ ប៉ុន្តែបទល្មើសនេះបង្កនូវព្យសនកម្មដ៏ធំសម្រាប់សង្គមជាតិទាំងមូល។

### ចំណុចទី៣៖ អញ្ញត្តិកម្មពិសេស

ថ្វីត្បិតតែមានការចែងច្បាស់លាស់ពីការមិនអាចជំនួយទោសបន្ថែមទៅលើមូលទោសបានក្តី ប៉ុន្តែក៏មានការបដិបញ្ញាត្តិទៅនឹងលក្ខខណ្ឌនៃការប្រកាសទោសបន្ថែមខាងលើនេះ ដោយផ្អែកតាមក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសពិសេសនេះ ដោយតុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន បាន។[43]ត្រង់ចំណុចនេះមានន័យថា ចៅក្រមមានសិទ្ធិក្នុងការបន្ថែមទោសបន្ថែមទៅលើមូលទោសដូចបទបទល្មើសទូទៅផងដែរ។

## ផ្នែកទី២៖ ការចាត់ចែងចំពោះវត្ថុរឹបអូសដែលពាក់ព័ន្ធនឹងបទល្មើស

វត្ថុតាងដែលជាគ្រឿងញៀន ឬវត្ថុតាងដែលមិនមានការពាក់ព័ន្ធ នឹងត្រូវបានយកទៅចាត់ចែងតាមនីតិវិធីច្បាប់ បន្ទាប់ពីដំណើរការជំនុំជម្រះក្តីត្រូវបានបញ្ចប់ និងចូលជាស្ថាពរនូវសាលក្រម។

---

[41] ក្រមព្រហ្មទណ្ឌ ចូលធរមានឆ្នាំ ត្រង់មាត្រា៩៩

[42] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ត្រង់មាត្រា២៨

[43] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ត្រង់មាត្រា៣៤

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

### កថាខណ្ឌទី១៖ ការរឹបអូសបំផ្លាញចោល

រដ្ឋអាចរឹបអូសបំផ្លាញចោលវត្ថុដែលជាគ្រឿងញៀន ដើម្បីបំផ្លាញចោលបានបន្ទាប់ពីចៅក្រមជំនុំជម្រះបានចេញសេចក្តីសម្រេច ប្រកាសថាទ្រព្យសម្បត្តិដែលត្រូវរឹបអូសបំផ្លាញចោល។

#### ចំណុចទី១៖ កម្មវត្ថុដែលរឹបអូសបំផ្លាញចោល

ចៅក្រមជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចថាប្រភេទវត្ថុតាងអ្វីខ្លះដែលត្រូវបានបំផ្លាញចោល ដែលជាទូទៅវាជាប្រភេទគ្រឿងញៀនដែលត្រូវបានរក្សាទុកជាមួយស្ថាប័នអយ្យការដែលមានដូចជា៖

ថ្នាំញៀនដែលចាប់បាន, សម្ភារៈសម្រាប់ប្រើប្រាស់គ្រឿងញៀនដែលមានដូចជា ស្បោងវេចខ្ចប់,ដបថ្នាំសម្រាប់ដក់,ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន និងឧបករណ៍សម្រាប់រៀបចំទុកជួញដូរជាដើម។

#### ចំណុចទី២៖ នរណាខ្លះចូលរួម?

ការដុតបំផ្លាញចោលវត្ថុតាងដែលបានរឹបអូសមកជាសម្បត្តិរបស់រដ្ឋ ត្រូវតែមានការចូលរួមស្របច្បាប់ពីភាគីដែលមានការពាក់ព័ន្ធ។

**. អ្នកមានសិទ្ធិពាក់ព័ន្ធ**

ការរឹបអូសដើម្បីប្រគល់ ឬបំផ្លាញចោល ជាសមត្ថកិច្ចរបស់ភាគីអ្នកដែលមានដូចជា[44]៖

- ព្រះរាជអាជ្ញា នៅក្នុងដំណាក់កាលស៊ើបអង្កេត
- យុត្តាធិការស៊ើបសួរ នៅក្នុងដំណាក់កាលស៊ើបសួរ
- យុត្តាធិការជំនុំជម្រះ នៅដំណាក់កាលជំនុំជម្រះ

ការបំផ្លាញចោលនូវគ្រឿងញៀនដែលគ្មានប្រយោជន៍ក្នុងការប្រើប្រាស់ ត្រូវតែធ្វើឡើងឲ្យបានឆាប់រហ័ស និងតាមមធ្យោបាយសមស្របបំផុត នៅចំពោះមុខគណៈកម្មការដែលត្រូវបង្កើតឡើង ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។[45]

---

[44] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ចូលជាធរមាន ត្រង់មាត្រា៨៤ កថាខណ្ឌទី២

[45] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ចូលជាធរមាន ត្រង់មាត្រា៨៤ កថាខណ្ឌទី១ ចំណុចទី៣

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្

## កថាខណ្ឌទី២៖ ការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ

ចៅក្រមនឹងចេញសេចក្ដីសម្រេចមួយ ដើម្បីបញ្ជាក់ពីប្រភេទវត្ថុតាងដែលអាចរឹបអូសចូលជាសម្បត្តិរបស់រដ្ឋបាន កាលបើការរឹបអូសក្លាយជាស្ថាពរ វត្ថុដែលរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋ[46]។

### ចំណុចទី១៖ វត្ថុដែលមិនពាក់ព័ន្ធនឹងបទល្មើស

វត្ថុតាងមួយចំនួនដែលមិនមានការជាប់ពាក់ព័ន្ធនឹងបទល្មើស អាចក្លាយទៅជាកម្មវត្ថុនៃការរឹបអូសដើម្បីអាចក្លាយទៅជាសម្បត្តិរបស់រដ្ឋ។

### ចំណុចទី២៖ ផលនៃគ្រឿងញៀន

គ្រឿងញៀនដែលបានរឹបអូស អាចជាផលនៃគ្រឿងញៀនដែលបានបំផ្លែងចេញពីលុយគ្រឿងញៀនដោយជនល្មើសបានយកថវិកានោះទិញជាសម្ភារៈដូចជា រថយន្ត ម៉ូតូ គ្រឿងសង្ហារិម និង សម្ភារៈដទៃទៀតជាច្រើន។

### ចំណុចទី៣៖ ការបញ្ចូលទៅក្នុងបេឡាមូនិធិ

ទ្រព្យ និងវត្ថុដទៃទៀត ដែលបានមកដោយការអនុវត្តសេចក្ដីសម្រេចរឹបអូសរបស់តុលាការពីជំនួញគ្រឿងញៀនខុសច្បាប់ អាចត្រូវបានបញ្ចូលទៅក្នុងបេឡាមូលនិធិនៃអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន។[47]

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អនុម័តការប្រើប្រាស់មូលនិធិរបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ និងត្រួតពិនិត្យការប្រើប្រាស់ថវិការបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ព្រមទាំងមានសិទ្ធិចាត់ចែងថវិកា និងទ្រព្យសម្បត្តិដែលបានបញ្ចូលទៅក្នុបេឡាមូលនិធិ។[48]

---

[46] ក្រមព្រហ្មទណ្ឌ ចូលធរមានឆ្នាំ ត្រង់មាត្រា១៧៨

[47] ព្រះរាជក្រិតស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចូលធរមានថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ត្រង់មាត្រា១០

[48] ព្រះរាជក្រិតស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចូលធរមានថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ត្រង់មាត្រា១២

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

## កថាខណ្ឌទី៣៖ ការប្រគល់វត្ថុដែលរឹបអូសបាន

វត្ថុតាងដែលចាប់បាន និងមិនមានការពាក់ព័ន្ធត្រូវតែធ្វើការប្រគល់ឲ្យទៅម្ចាស់ដើមវិញ ដើម្បីអាចយកទៅប្រើប្រាស់ និងចាត់ចែងចំពោះសិទ្ធិលើវត្ថុដែលមាន។

### ចំណុចទី១៖ លក្ខខណ្ឌនៃការប្រគល់

វត្ថុតាងដែលពុំមានពាក់ព័ន្ធនៅក្នុងបទល្មើស តុលាការនឹងធ្វើសេចក្ដីសម្រេចប្រគល់ឲ្យម្ចាស់កម្មសិទ្ធិយកទៅប្រើប្រាស់វិញ។ ជាទូទៅវត្ថុដែលត្រូវបានប្រគល់ត្រឡប់មកវិញ លុះត្រាតែមានការស្នើសុំពីម្ចាស់ដើម ឬករណីដែលមានការស្នើសុំពីតតីយជនដែលមានការពាក់ព័ន្ធ ទើបតុលាការធ្វើសេចក្ដីសម្រេចក្នុងការប្រគល់ឲ្យត្រឡប់ទៅវិញ។

### ចំណុចទី២៖ នីតិវិធីនៃការប្រគល់

ចៅក្រមត្រូវតែចេញសេចក្ដីសម្រេចថាប្រគល់វត្ថុតាង ដែលមិនមានការពាក់ព័ន្ធនឹងបទល្មើសប្រគល់ជូនម្ចាស់កម្មសិទ្ធិវិញ ក្នុងសាលក្រមតែប៉ុណ្ណោះ ។

ឧទាហរណ៍៖ ករណីទណ្ឌិតក្នុងពន្ធនាគារ នោះលិខិតឆ្លងដែនត្រូវបាន សម្រេចប្រគល់ឲ្យម្ចាស់ទ្រព្យវិញ ប៉ុន្តែត្រូវសម្រេចប្រគល់ឲ្យស្ថានទូតនៃប្រទេសរបស់ជនជាប់ចោទនីមួយៗជាអ្នកគ្រប់គ្រងជំនួស។

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

# ឯកសារយោង

## I. ក្រម

– ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧

– អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖វិធានផ្ទៃក្នុង

## II. ព្រះរាជក្រឹត

– ព្រះរាជក្រិតស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចូលធរមានថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩

## III. ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងលិខិតរដ្ឋាភិបាល

– ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៥

– សេចក្តីសម្រេចស្តីពី៖ការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀន របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចូលជាធរមានថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២

– **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានចេញផែនការស្តីពី “យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី១ រយៈពេល៦ខែ (ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនាឆ្នាំ២០១៧) ” ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ។

## IV. ប្រកាសអន្តរក្រសួង

– ប្រកាសស្តីពី នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងញុះញង់ឲ្យលក់ដោយខុសច្បាប់ ចូលជាធរមានថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៦

## V. សៀវភៅ

– សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អ.វ.ត.ក និងអន្តរជាតិសម្រាំង បោះពុម្ពផ្សាយលើកទី១ នៅខែមិនា ឆ្នាំ២០១៤

## VI. បឋកថា និង មេរៀន

– ឧត្តមសេនីយឯក វេជ្ជ.មាស វិរិទ្ធ ៖ បទបង្ហាញមេរៀនស្តីពីការយល់ដឹងពីលក្ខណៈបច្ចេកទេសទាក់ទងនឹងបទល្មើសគ្រឿងញៀន

– United Nations Conventions On Drugs ៖ ប្រវត្តិនៃការកកើតអនុសញ្ញាស្តីពីគ្រឿងញៀន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ

ចុះថ្ងៃទី ខែ ឆ្នាំ

លេខ៖.... ..............អ.យ.

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

**យើង** **ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ របាយការណ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់មន្ទីរប្រឆាំងគ្រឿងញៀន នៃក្រសួងមហាផ្ទៃ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្និដ្ឋានបានថា

១-នាម-គោត្តនាម ភេទប្រុស អាយុ ២៦ឆ្នាំ(ឆ្នាំ១៩៩១) ជនជាតិខ្មែរ , ទីកន្លែងកំណើត , សាសនាព្រះពុទ្ធ , ទីលំនៅបច្ចុប្បន្ន , មុខរបរ , ឪពុកឈ្មោះ ម្តាយឈ្មោះ "រស់" , នៅលីវ , ទោសពីមុនគ្មាន , ជានីតិជន ។ (ឃាត់ខ្លួន)

២-នាម-គោត្តនាម ភេទប្រុស អាយុ ២០ឆ្នាំ(ឆ្នាំ១៩៩៧) ជនជាតិខ្មែរ , ទីកន្លែងកំណើត , សាសនាព្រះពុទ្ធ , ទីលំនៅបច្ចុប្បន្ន , មុខរបរ , ឪពុកឈ្មោះ "រស់" , ម្តាយឈ្មោះ "រស់" , នៅលីវ , ទោសពីមុនគ្មាន , ជានីតិជន ។ (ឃាត់ខ្លួន)

៣-នាម-គោត្តនាម ភេទប្រុស អាយុប្រហែល២៣ឆ្នាំ នៅរ (គេចខ្លួនគ្មានសាវតាជាតិ)។

បានប្រព្រឹត្តអំពើដូចតទៅ៖ កាលពីថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង១៥និង០៥នាទី កម្លាំងសមត្ថកិច្ចនគរបាលការិយាល័យបច្ចេកទេស បានបង្ក្រាបករណី ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដោយឃាត់ខ្លួនបានជនសង្ស័យ០២នាក់ ឈ្មោះ ភេទប្រុស អាយុ២៦ឆ្នាំ និងឈ្មោះ ភេទប្រុស អាយុ២០ឆ្នាំ និងឆែកឆេរឃើញមានក្រាមពណ៌សចំនួន០១កញ្ចប់ និងឧបករណ៍សម្រាប់ជក់គ្រឿងញៀនមួយចំនួន។ ក្រោយមកសមត្ថកិច្ចបានសាកសួរជនសង្ស័យ បានសារភាពថា គ្រឿងញៀនដែលពួកខ្លួនទិញយកមកលក់បន្តនោះ គឺពួកខ្លួនទិញពីឈ្មោះ ភេទប្រុស អាយុប្រហែល២៣ឆ្នាំ។ សមត្ថកិច្ចបានធ្វើតេស្តទឹកនោមលើជនសង្ស័យឈ្មោះ និងឈ្មោះ ឃើញមានសារធាតុញៀន បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿង ដើម្បីបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធី ។

អំពើខាងលើរបស់ឈ្មោះ និងឈ្មោះ ជាបទល្មើស៖ **ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារ

ត្រួតពិនិត្យគ្រឿងញៀន។

អំពើខាងលើរបស់ឈ្មោះ ជាបទល្មើសៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ខែ ឆ្នាំ តាមបញ្ញត្តិមាត្រា ៤០ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ ក្រមនីតិវិធីព្រហ្មទណ្ឌ។

**<u>សម្រេចៈ</u>**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង

☑ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យៈ

១-ឈ្មោះ ភេទប្រុស អាយុ ២៦ឆ្នាំ (ឃាត់ខ្លួន)។

២-ឈ្មោះ ភេទប្រុស អាយុ ២០ឆ្នាំ (ឃាត់ខ្លួន)។

ពីបទៈ **ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ខែ ឆ្នាំ តាមបញ្ញត្តិមាត្រា ៤០ និង ៤៥ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ឈ្មោះ ភេទប្រុស អាយុប្រហែល២៣ឆ្នាំ (គេចខ្លួនគ្មានសារតាជាតិ)។

ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ខែ ឆ្នាំ តាមបញ្ញត្តិមាត្រា ៤០ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

☑ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នៈ លើឈ្មោះខាងលើ ដើម្បីបង្ការ ឬបញ្ចប់បទល្មើសកុំឲ្យកើតឡើងជាថ្មី និង ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ជ.ព្រះរាជអាជ្ញា**

(4)

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

— —

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ

ចុះថ្ងៃទី ខែ ឆ្នាំ

## <u>ដីកាសន្និដ្ឋានសុំឲ្យឃុំខ្លួនបណ្ដោះអាសន្ន</u>

**យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

☑ បានឃើញសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ អ.យ ចុះថ្ងៃទី ដែលបើកការស៊ើបសួរពីបទ៖ **ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។**

☐ បានឃើញដីកាបញ្ជូនឲ្យឆ្លើយរបស់ចៅក្រមស៊ើបសួរចុះថ្ងៃទី ........ ខែ......... ឆ្នាំ..............

☐ បានឃើញមាត្រា ២០៣ , ២០៥ និង២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ដោយហេតុថា ការឃុំខ្លួនបណ្ដោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី**

☑ បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី

☑ រារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការ ត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

☐ រក្សាភស្ដុតាង ឬតម្រុយជាសម្ភារៈ

☑ ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

☑ ការពារសន្តិសុខឲ្យជនត្រូវចោទ

☑ ធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស

**<u>យល់ឃើញថា៖</u>**

ការឃុំខ្លួនបណ្ដោះអាសន្នជាមធ្យោបាយសំរាប់បញ្ចប់ភាពចលាចលធ្ងន់ធ្ងរ និងយូរអង្វែងចំពោះសណ្ដាប់ធ្នាប់សាធារណៈ ដោយមូលហេតុ៖

☑ ភាពធ្ងន់ធ្ងរនៃបទល្មើស

☐ កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស

☑ ទំហំនៃព្យសនកម្មដែលបង្កឡើងដោយបទល្មើស

**ប្ដឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នលើ**

១-នាម-គោត្តនាម ភេទប្រុស អាយុ ២៦ឆ្នាំ(ឆ្នាំ១៩៩១) ជនជាតិខ្មែរ , ទីកន្លែងកំណើត , សាសនាព្រះពុទ្ធ , ទីលំនៅបច្ចុប្បន្ន , មុខរបរ , ឪពុកឈ្មោះ រស់ , ម្ដាយឈ្មោះ រស់ , នៅលីវ , ទោសពីមុនគ្មាន , ជានីតិជន ។ (ឃាត់ខ្លួន)

២-នាម-គោត្តនាម ភេទប្រុស អាយុ ២០ឆ្នាំ(ឆ្នាំ១៩៩៧) ជនជាតិខ្មែរ , ទីកន្លែងកំណើត , សាសនាព្រះពុទ្ធ , ទីលំនៅបច្ចុប្បន្ន , មុខរបរ , ឪពុកឈ្មោះ រស់ , ម្ដាយឈ្មោះ រស់ , នៅលីវ , ទោសពីមុនគ្មាន , ជានីតិជន ។ (ឃាត់ខ្លួន)

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ខែ ឆ្នាំ

**ជ.ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ:
ចុះថ្ងៃទី ខែ ឆ្នាំ
លេខ:........... .........អ.យ.

# ដីកាសន្និដ្ឋានស្ថាពរ

**យើង** **ព្រះរាជអាជ្ញារងនៃអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ , របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: អ.យ. ចុះថ្ងៃទី ខែ ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី ខែ ឆ្នាំ , របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាបញ្ជូនឲ្យឆ្លើយដើម្បីបញ្ចប់ការស៊ើបសួរលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាបញ្ជូនសំណុំរឿងពិនិត្យលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា៖**

១-នាម-គោត្តនាម ភេទប្រុស អាយុ ២៦ឆ្នាំ (ឆ្នាំកំណើត ១៩៩១) ជនជាតិខ្មែរ , មានទីកន្លែងកំណើត សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ននៅ មុខរបរ , ឪពុកឈ្មោះ ម្តាយឈ្មោះ ,នៅលីវ , ទោសពីមុនគ្មាន , ជានីតិជន។(ឃាត់ខ្លួន)

២-នាម-គោត្តនាម ភេទប្រុស អាយុ ២០ឆ្នាំ (ឆ្នាំកំណើត ១៩៩៧) ជនជាតិខ្មែរ , មានទីកន្លែងកំណើត. , មុខរបរ , សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ននៅ , ឪពុកឈ្មោះ ម្តាយឈ្មោះ ,នៅលីវ , ទោសពីមុនគ្មាន , ជានីតិជន។(ឃាត់ខ្លួន)

ត្រូវបានដាក់ក្រោមការពិនិត្យពីបទ ៖ **ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៦

ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង ១៥ និង ០៥នាទី តាមបញ្ញត្តិមាត្រា ៤០, និង ៤៥ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-នាម-គោត្តនាម ភេទប្រុស អាយុប្រហែល ២៣ឆ្នាំ ,

។(គេចខ្លួនគ្មានសវតាជាតិ)

ត្រូវបានដាក់ក្រោមការពិនិត្យពីបទ ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ខែ : ឆ្នាំ វេលាម៉ោង ១៥ និង ០៥នាទី តាមបញ្ញត្តិមាត្រា ៤០ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ឃើញថា**:កាលពីថ្ងៃទី ខែ ឆ្នាំ , វេលាម៉ោង ១៥ និង ០៥នាទី កម្លាំងសមត្ថកិច្ចរបស់នគរបាលការិយាល័យបច្ចេកទេស បានចុះបង្ក្រាបករណី ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដោយឃាត់ខ្លួនបានជនសង្ស័យ០២នាក់ ឈ្មោះ , និងឈ្មោះ , និងឆែកឆេរឃើញមានក្រាមពណ៌សចំនួន០១កញ្ចប់ និងឧបករណ៍សម្រាប់ជក់គ្រឿងញៀនមួយចំនួន។ ក្រោយមកសមត្ថកិច្ចបានសាកសួរជនសង្ស័យ បានឆ្លើយសារភាពថា គ្រឿងញៀនដែលពួកខ្លួនទិញយកមកលក់បន្តនោះ គឺពួកខ្លួនទិញពីឈ្មោះ ភេទប្រុស អាយុប្រហែល២៣ឆ្នាំ។ សមត្ថកិច្ចបានធ្វើតេស្តទឹកនោមលើជនសង្ស័យឈ្មោះ និងឈ្មោះ ឃើញមានសារធាតុញៀន បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿង ដើម្បីបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី។

**បានឃើញ**

-របាយការណ៍សំយោគលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់មន្ទីរប្រឆាំងគ្រឿងញៀន នៃក្រសួងមហាផ្ទៃ បានសន្និដ្ឋានថា ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន , ឈ្មោះ ភេទប្រុស ពិតជាបានប្រព្រឹត្ត បទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន ។

-ចម្លើយរបស់ឈ្មោះ ជាជនត្រូវចោទ បានឆ្លើយនៅសមត្ថកិច្ច និងនៅចៅក្រមស៊ើបសួរដែលមានន័យប្រហាក់ប្រហែលគ្នាថា នៅថ្ងៃ , ខែ ឆ្នាំ វេលាម៉ោង ១៥ និង ០៥នាទី ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនខ្ញុំ ខ្ញុំបានរកស៊ីលក់គ្រឿងញៀនបានមួយអាទិត្យហើយ ថ្នាំញៀនដែលគេទិញយកមកលក់បន្តនេះគឺទិញពីឈ្មោះ ក្នុងមួយថ្ងៃលក់ទៅអោយអ្នកទិញពីដប់ទៅម្ភៃនាក់ភាគច្រើនអ្នកដែលទិញយកមកប្រើគឺជាអ្នកភូមិ និង សិស្សសាលា ។ ក្នុងមួយថ្ងៃខ្លួន បានទទួលកំរៃពីការលក់ថ្នាំញៀនអោយឈ្មោះ ពី ៣០០០០រៀល ទៅ ៥០០០០រៀល ។ លុះដល់ថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង១៥និង០៥នាទី បានធ្វើសកម្មភាពលក់ចែកចាយគ្រឿងញៀនទៅលក់អោយម៉ូយក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួន រួមទាំងវត្ថុតាងគ្រឿងញៀនតែម្តង។

-ចម្លើយរបស់ឈ្មោះ ជាជនត្រូវចោទ បានឆ្លើយនៅសមត្ថកិច្ច និងនៅចៅក្រមស៊ើបសួរដែលមានន័យប្រហាក់ប្រហែលគ្នាថា នៅថ្ងៃ ខែ ឆ្នាំ វេលាម៉ោង ១៥ និង ០៥នាទី ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនខ្ញុំ ខ្ញុំធ្លាប់ប្រើប្រាស់ចំនួនពីរទៅបីដងដំបូងបានស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល២២ ឆ្នាំបានចូលលុយគ្នាចំនួន២០០០០រៀល ដើម្បីទៅទិញថ្នាំពីឈ្មោះ រួចយកមកជក់នៅ

លុះដល់ថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង១៥និង០៥នាទី ខ្លួនកំពុងដេកក្នុងផ្ទះរបស់ខ្លួនក៏ត្រូវសមត្ថកិច្ចមន្ទីរប្រឆាំងគ្រឿងញៀន ធ្វើការឃាត់ខ្លួនជាមួយឧបករណ៍ជក់ និងថ្នាំញៀនជាច្រើន។

-ដីកាសម្រេចអោយឃុំខ្លួនបណ្តោះអាសន្នលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ

-ដីកាសម្រេចអោយឃុំខ្លួនបណ្តោះអាសន្នលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ភេទ ប្រុស អាយុ ២០ឆ្នាំ។

-ដីកាចាត់អោយស៊ើបសួរជំនួសលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ប្រគល់សិទ្ធិជូន ឯកឧត្តម នាយកមន្ទីរប្រឆាំងគ្រឿងញៀនដើម្បីបំពេញកិច្ចស៊ើបសួររកអត្តសញ្ញាណជនត្រូវចោទ ឲ្យស្រាវជ្រាវសាវតាជាតិឈ្មោះ ភេទ ប្រុស អាយុប្រហែល២៣ឆ្នាំ។

-មិនមានរបាយការណ៍ឆ្លើយតបពីមន្ទីរប្រឆាំងគ្រឿងញៀនឆ្លើយបញ្ជាក់ថា៖ ឈ្មោះ ភេទ ប្រុស អាយុប្រហែល២៣ឆ្នាំ មានចុះបញ្ជី និងស្នាក់នៅក្នុងមូលដ្ឋាន ទេ។

-ដីកាចាត់តាំងអ្នកជំនាញលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-ឯកសារជាភស្តុតាងសំខាន់ផ្សេងៗទៀត។

**យល់ឃើញថា៖**

-ផ្អែកតាមរបាយការណ៍សំយោគលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់មន្ទីរប្រឆាំងគ្រឿងញៀន នៃក្រសួងមហាផ្ទៃ បានសន្និដ្ឋានថា ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ,ឈ្មោះ ភេទប្រុស ពិតជាបានប្រព្រឹត្ត បទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន ។

-ផ្អែកតាមចម្លើយជនត្រូវចោទឈ្មោះ ឆ្លើយនៅសមត្ថកិច្ច និងនៅចៅក្រមស៊ើបសួរ ដែលមានន័យប្រហាក់ប្រហែលគ្នាថា ជនត្រូវចោទឈ្មោះ ភេទប្រុស ពិតជាបានប្រព្រឹត្តអំពើ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រាកដមែន ។

-ផ្អែកតាមចម្លើយជនត្រូវចោទឈ្មោះ បានឆ្លើយបដិសេធគ្រប់ដំណាក់កាលថា ខ្លួនមិនបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀននោះទេ ខ្លួនគ្រាន់តែបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតែប៉ុណ្ណោះ ចម្លើយដោះសាររបស់ឈ្មោះ ខាងលើនោះតំណាងអយ្យការមិនអាចជឿបាននោះទេ ពីព្រោះឈ្មោះ ជាប្អូនបង្កើតនិងស្នាក់នៅរួមគ្នារបស់ឈ្មោះ នាំអោយអ្នកទាំងពីរនេះជាបក្ខពួកតែមួយ ហេតុដូច្នេះឈ្មោះ បានប្រព្រឹត្តអំពើ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** នាំអោយឈ្មោះ ប្រព្រឹត្តអំពើ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដូចឈ្មោះ ដែរ។ មានភស្តុតាង និងពិរុទ្ធភាពគ្រប់

គ្រាន់ដើម្បីចោទប្រកាន់ទៅលើឈ្មោះឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រាកដមែន ។

-ជនត្រូវចោទជាមនុស្សមានស្មារតីល្អ យល់ដឹងនូវអំពើនូវអំពើប្រព្រឹត្តរបស់ខ្លួនច្បាស់ និងមានចេតនាប្រព្រឹត្ត បទល្មើសខាងលើ បានសម្រេច។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីចោទប្រកាន់ទៅលើឈ្មោះ ភេទប្រុស និងឈ្មោះ ។ ភេទប្រុស ពីបទ: **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** នៅប្រព្រឹត្តនៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ខែ ឆ្នាំ តាមបញ្ញត្តិមាត្រា ៤០, និង ៤៥ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មិនមានរបាយការណ៍ឆ្លើយតបពីមន្ទីរប្រឆាំងគ្រឿងញៀនឆ្លើយបញ្ជាក់ថា៖ ឈ្មោះ ភេទប្រុស អាយុប្រហែល២៣ឆ្នាំ មានចុះបញ្ជី និងស្នាក់នៅក្នុងមូលដ្ឋាន ទេ។ គប្បីលោកចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស អាយុ ប្រហែល២៣ឆ្នាំ តាមមាត្រា ២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧កិច្ចដំណោះស្រាយនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ហេតុដូច្នេះ**

**ប្តឹងសុំឲ្យចៅក្រមស៊ើបសួរ សម្រេច**

☑ បញ្ជូនជនត្រូវចោទ

១-ឈ្មោះ ភេទប្រុស អាយុ ២៦ឆ្នាំ (ឃាត់ខ្លួន)

២-ឈ្មោះ ភេទប្រុស អាយុ ២០ឆ្នាំ (ឃាត់ខ្លួន)

ពីបទ: **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** នៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ខែ ឆ្នាំ តាមបញ្ញត្តិមាត្រា ៤០, និង ៤៥ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

☑ លើកលែងចោទ

៣-ឈ្មោះ ភេទប្រុស អាយុប្រហែល ២៣ឆ្នាំ (គេចខ្លួនគ្មានសវតាជាតិ)

ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង ១៥ និង ០៥ នាទី តាមបញ្ញត្តិមាត្រា ៤០ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

នៅរាជធានីភ្នំពេញ ថ្ងៃទី .. ខែ ឆ្នាំ

**ជ.ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៥៤៦.....សហវ.ប.ក

# ប្រកាសរួម

## ស្តីពី

## ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែង ទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន

**ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សម្រេច

**ប្រការ១.–**

ប្រកាសនេះមានគោលបំណងកំណត់យន្តការ ដើម្បីធានាប្រសិទ្ធភាពនៃការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

**ប្រការ២.–**

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសវត្ថុតាងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន តទៅហៅថា "ទ្រព្យសម្បត្តិរឹបអូស" រួមមាន ៖

១. ចលនទ្រព្យ

-បរិក្ខារផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យបច្ចេកទេសផ្សេងៗ

-យានយន្តមធ្យោបាយធ្វើដំណើរ និងគ្រឿងចក្រ

-សង្ហារឹម សម្ភារៈ

២. អចលនទ្រព្យ

- ដី

- អគារ

- ទ្រព្យសម្បត្តិដែលភ្ជាប់នឹងអគារ

៣. ទ្រព្យជារតនវត្ថុ និងទ្រព្យដទៃទៀត ដែលក្រោយពីមានសាលក្រមស្ថាពររបស់តុលាការបានបង្គាប់ជាទ្រព្យសម្បត្តិរដ្ឋ។

ដោយឡែកការចាត់ចែងគ្រឿងញៀនត្រូវអនុវត្តតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៣.–**

ត្រូវបានបង្កើត គណៈកម្មការអន្តរក្រសួងស្ថាប័នមួយ សម្រាប់រៀបចំដំណើរការពាក់ព័ន្ធនឹងការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ បានមកពីការរឹបអូសពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន តទៅហៅថា "គណៈកម្មការ"។

**ប្រការ៤.–**

គណៈកម្មការមានសមាសភាពចូលរួម ដូចខាងក្រោម៖

| | |
|---|---|
| –តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| –តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | អនុប្រធាន |
| –តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| –តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ | សមាជិក |
| –តំណាងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |

សមាសភាពជាក់ស្តែងនៃគណៈកម្មការនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គណៈកម្មការ ប្រើប្រាស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ អង្គភាពពាក់ព័ន្ធនៃក្រសួង ស្ថាប័នដូចក្នុងប្រការ ៤ នៃប្រកាសនេះជាលេខាធិការដ្ឋាន តាមការចាំបាច់។

**ប្រការ៥.–**

គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងារពាក់ព័ន្ធនឹងដំណើរការក្នុងការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ
- ធ្វើការកត់ត្រា បញ្ជីសារពើភណ្ឌ ផ្ទៀងផ្ទាត់ និងបញ្ជាក់ពីភាពត្រឹមត្រូវលើទ្រព្យសម្បត្តិរឹបអូសដែលមានការពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលបញ្ជីទ្រព្យសម្បត្តិ និងឯកសារពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- ត្រូវបញ្ជូនបញ្ជីទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ទៅប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឬ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រគល់ជូន។

**ប្រការ៦.–**

គណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានតាមការចាំបាច់។ ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានមានសិទ្ធិកោះប្រជុំតាមលិខិតប្រគល់សិទ្ធិ។

ក្នុងករណីចាំបាច់ គណៈកម្មការអាចអញ្ជើញភាគីពាក់ព័ន្ធផ្សេងទៀតចូលរួមក្នុងកិច្ចប្រជុំ និងចូលរួមបំពេញការងារជាមួយគណៈកម្មការ តាមការជាក់ស្តែង។

**ប្រការ៧.-**

ក្រោយពីមានសេចក្តីសម្រេចស្ថាពររបស់សាលាជម្រះក្តី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវលើកសំណើសុំលក់ទ្រព្យសម្បត្តិរឹបអូសមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច និង ក្នុងករណីចាំបាច់ ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាល។ នីតិវិធីនៃការលក់ទ្រព្យសម្បត្តិរឹបអូស ត្រូវអនុវត្តតាម នីតិវិធីដេញថ្លៃ ឬ នីតិវិធីពិគ្រោះថ្លៃដូចមានចែងក្នុងប្រកាសរួមនេះ។

**ប្រការ៨.-**

ក្រោយទទួលបានគោលការណ៍ គណៈកម្មការត្រូវធ្វើការសិក្សា វាយតម្លៃលើទ្រព្យសម្បត្តិរឹបអូស ដើម្បី កំណត់តម្លៃមូលដ្ឋានសម្រាប់ដាក់លក់។ ការវាយតម្លៃនៃទ្រព្យសម្បត្តិរឹបអូសត្រូវផ្អែកលើមូលដ្ឋានសំខាន់ៗ ដូចខាងក្រោម៖

១. ចលនទ្រព្យជាបរិក្ខារឧស្សាហកម្ម និងបច្ចេកទេស យានយន្ត គ្រឿងចក្រ សង្ហារឹម និងឧបករណ៍ សម្ភារៈត្រូវកំណត់តាមស្ថានភាព គុណភាព និងតម្លៃនៅសល់ជាក់ស្តែង។

២. អចលនទ្រព្យ

- ទំហំដី និង អគារ តាមប្លង់ ឬការកំណត់របស់សុរិយោដី
- ទីតាំង និងស្ថានភាពដី និងលក្ខណៈ គុណភាព អាយុកាលរបស់អគារ
- តម្លៃដី និងអគារតាមទិន្នន័យតម្លៃទីផ្សារជាក់ស្តែងប្រៀបធៀបនឹងតម្លៃរបស់ក្រុមហ៊ុនអចលនទ្រព្យ

៣. ចំពោះទ្រព្យជារតនវត្ថុ និងទ្រព្យដទៃទៀតដែលគ្មានតម្លៃទីផ្សារ គណៈកម្មការត្រូវវាយតម្លៃតាម យថាប្រភេទជាក់ស្តែងនៃទ្រព្យនោះ។

គណៈកម្មការ ត្រូវរៀបចំកំណត់ហេតុស្តីពីលទ្ធផលនៃការវាយតម្លៃនេះ ដោយមានចុះហត្ថលេខាពី គ្រប់សមាជិកចូលរួម និងដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងឯកភាព។

**ប្រការ៩.-**

គណៈកម្មការ ត្រូវរៀបចំចាត់ចែងកិច្ចដំណើរការលក់ដេញថ្លៃ ទ្រព្យសម្បត្តិរឹបអូសតាមនីតិវិធីដេញថ្លៃ ជាសាធារណៈ ចាប់ពីតម្លៃមូលដ្ឋានឡើង ដោយដាក់ក្នុងស្រោមសំបុត្រ ឬផ្ទាល់មាត់ ដែលអាស្រ័យលក្ខណៈ និងវិសាលភាព នៃទ្រព្យសម្បត្តិរឹបអូស និងតាមការជ្រើសរើសរបស់គណៈកម្មការ។

មូលដ្ឋាននៃការដេញថ្លៃត្រូវកំណត់ក្នុងសៀវភៅបន្ទុក ដែលរៀបចំដោយគណៈកម្មការ និងត្រូវមានការ ឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១០.-**

សៀវភៅបន្ទុកត្រូវមានកំណត់ច្បាស់លាស់នូវចំណុចសំខាន់ជាអាទិ៍៖

- កម្មវត្ថុនៃការដេញថ្លៃ
- កាលបរិច្ឆេទ និងទីកន្លែង
- ទ្រព្យសម្បត្តិជាកម្មវត្ថុនៃការដាក់ឱ្យដេញថ្លៃ (រូបទ្រព្យ ទីកន្លែង ចំនួន ទំហំលក្ខណៈ គុណភាព។ល។)
- តម្លៃមូលដ្ឋាន

- លក្ខខណ្ឌជ្រើសរើសអ្នកចូលរួមដេញថ្លៃ
- ការកក់ប្រាក់ធានាចំនួន ១០% (ដប់ភាគរយ) នៃតម្លៃមូលដ្ឋាន
- កម្មវិធីនៃការបង់ប្រាក់
- ការប្រគល់ទទួល
- វិធីដេញថ្លៃជាសាធារណៈ (ដោយដាក់ក្នុងស្រោមសំបុត្រ ឬផ្ទាល់មាត់)
- របៀបរបប និងបទបញ្ជាក្នុងកិច្ចដំណើរការដេញថ្លៃ
- បំរាមផ្សេងៗ (ការឃុបឃិតក្នុងបំណងបង្ខូចតម្លៃ ។ល។)
- ការរឹបអូសប្រាក់កក់
- ការផ្ទេរសិទ្ធិចូលរួមដេញថ្លៃ

**ប្រការ១១.-**

ការផ្សព្វផ្សាយសេចក្តីជូនដំណឹងពីការដេញថ្លៃ ត្រូវធ្វើតាមរយៈវិទ្យុផ្សាយសម្លេង ទូរទស្សន៍ សារព័ត៌មាន ការបិទផ្សាយនៅតាមក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងអង្គភាពនានា។

**ប្រការ១២.-**

គណៈកម្មការជាអ្នកដឹកនាំ ចាត់ចែងកិច្ចដំណើរការដេញថ្លៃទ្រព្យសម្បត្តិរឹបអូសតាមការកំណត់ក្នុងសៀវភៅបន្ទុក។ ការដេញថ្លៃចាប់ពីតម្លៃមូលដ្ឋានឡើងទៅ ដែលត្រូវដាក់តម្លៃចំនួនបីលើក ។ ការដាក់តម្លៃរបស់បេក្ខជន ត្រូវធ្វើឡើងដោយសម្ងាត់ និងមានចុះហត្ថលេខាដាក់ក្នុងស្រោមសំបុត្របិទជិតដែល

- លើកទី១ ចាប់ពីតម្លៃមូលដ្ឋានឡើងទៅ
- លើកទី២ ចាប់ពីតម្លៃនៃលទ្ធផលនៃការដេញថ្លៃលើកទី ១ ដែលត្រូវបង្កើន ១០% (ដប់ភាគរយ)
- លើកទី៣ ចាប់ពីតម្លៃនៃលទ្ធផលនៃការដេញថ្លៃលើកទី ២ ដែលត្រូវបង្កើន ១០% (ដប់ភាគរយ)

ក្នុងករណីការដេញថ្លៃចំនួន ០៣ លើករួចហើយ ប៉ុន្តែមិនទាន់ទទួលបានលទ្ធផលជាស្ថាពរនោះត្រូវដំណើរការដេញថ្លៃបន្តទៀតហូតទទួលបានលទ្ធផលឈ្នះលើការដេញថ្លៃមានតែមួយ។

ករណីដំណើរការដេញថ្លៃមិនមានភាពរលូនតាមសៀវភៅបន្ទុក ឬ មានភាពមិនប្រក្រតី ដូចជាការឃុបឃិតគ្នាបង្ខូចតម្លៃ ហើយដែលមានភស្តុតាង លទ្ធផលដេញថ្លៃត្រូវទុកជាមោឃៈ។ គណៈកម្មការត្រូវរៀបចំការដេញថ្លៃសារជាថ្មី។ បន្ទាប់ពីពិនិត្យឃើញថា ការដេញថ្លៃប្រព្រឹត្តទៅដោយប្រក្រតី តម្លាភាព និងយុត្តិធម៌ នោះគណៈកម្មការត្រូវប្រកាសលទ្ធផលនៃការដេញថ្លៃ ដោយប្រកាសរូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលហ៊ានឱ្យតម្លៃខ្ពស់ជាងគេ ។

ករណីអ្នកឈ្នះការដេញថ្លៃ បោះបង់ចោលលទ្ធផលដេញថ្លៃ នោះប្រាក់កក់ចូលដេញថ្លៃត្រូវរឹបអូស។ ករណីនេះ គណៈកម្មការត្រូវចរចាជាមួយអ្នកឈ្នះការដេញថ្លៃបន្ទាប់ពីអ្នកឈ្នះទី១ ដែលបោះបង់ចោលលទ្ធផលនៃការដេញថ្លៃ។

គណៈកម្មការត្រូវរៀបចំកំណត់ហេតុស្តីពីលទ្ធផលនៃការដេញថ្លៃ ដោយមានចុះហត្ថលេខាពីគ្រប់សមាសភាពគណៈកម្មការ ដែលបានចូលរួម និងផ្តិតមេដៃរបស់អ្នកដេញថ្លៃបាន។

កំណត់ហេតុនៃការដេញថ្លៃត្រូវដាក់សុំការពិនិត្យ និងសម្រេច ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងករណីចាំបាច់ត្រូវសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាលលើលទ្ធផលនៃការដេញថ្លៃបណ្តោះអាសន្ន និងតាមនេះ លទ្ធផលដេញថ្លៃបណ្តោះអាសន្ន ត្រូវចាត់ទុកជាលទ្ធផលស្ថាពរ។

**ប្រការ១៣.–**

នីតិវិធីពិគ្រោះថ្លៃ ដើម្បីលក់ទ្រព្យសម្បត្តិរឹបអូសត្រូវផ្អែកតាមលក្ខខណ្ឌដូចខាងក្រោម៖

- មានគោលការណ៍ពីរាជរដ្ឋាភិបាលឲ្យលក់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ
- ការដេញថ្លៃមិនទទួលបានលទ្ធផល
- មានរូបវន្តបុគ្គល ឬ នីតិបុគ្គលតែមួយដាក់ពាក្យដេញថ្លៃ
- ទ្រព្យសម្បត្តិរឹបអូសជាកម្មវត្ថុនៃការលក់ មានភ្ជាប់លក្ខខណ្ឌត្រូវដោះស្រាយដូចជា កាតព្វកិច្ចជានាទូទាត់សងបំណុលជំនួស កាតព្វកិច្ចដោះស្រាយគោលនយោបាយ ឬ កាតព្វកិច្ចមួយចំនួនទៀតដែលតម្រូវ
- ទ្រព្យសម្បត្តិរឹបអូសជាកម្មវត្ថុនៃការលក់មានលក្ខណៈពិសេស ទាមទារឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជន មានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការទទួលយក។

**ប្រការ១៤.–**

គណៈកម្មការត្រូវរៀបចំកិច្ចសន្យាលក់ជាមួយអ្នកដេញថ្លៃ ឬ អ្នកពិគ្រោះថ្លៃបាន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. លក្ខខណ្ឌនៃការទូទាត់ :

អ្នកដេញថ្លៃ ឬ អ្នកពិគ្រោះថ្លៃបានត្រូវធ្វើការបង់យ៉ាងច្រើនជាបីដំណាក់កាល ដែលដំណាក់កាលនីមួយៗត្រូវបង់យ៉ាងតិចចំនួន៣០% (សាមសិបភាគរយ)។

២. លក្ខខណ្ឌនៃការប្រគល់ទទួលៈ

ក. គណៈកម្មការចេញលិខិតប្រគល់ទ្រព្យសម្បត្តិរឹបអូសជាកម្មវត្ថុនៃការលក់ ជូនអ្នកដេញថ្លៃ ឬ អ្នកពិគ្រោះថ្លៃ បានក្នុងរយៈពេលមិនលើសពី ១៥ ថ្ងៃធ្វើការ បន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌនៃការទូទាត់ និងលក្ខខណ្ឌដទៃទៀតដែលគណៈកម្មការបានកំណត់ចប់ជាស្ថាពរ

ខ. អ្នកដេញថ្លៃបានត្រូវចុះហត្ថលេខា ឬ ផ្តិតមេដៃលើឯកសារពាក់ព័ន្ធ ដើម្បីបញ្ជាក់អំពីភាពស្របច្បាប់នៃការទទួលខុសត្រូវលើទ្រព្យសម្បត្តិដែលដេញបាន។

**ប្រការ១៥.–**

ចំពោះករណីលក់ចលនទ្រព្យ មធ្យោបាយដឹកជញ្ជូន គ្រឿងចក្រ និង ឧបករណ៍សម្ភារៈ បន្ទាប់ពីរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានចាត់ចែងការទូទាត់តម្លៃទិញ និងបំពេញកាតព្វកិច្ចនានា ដែលមានចែងនៅក្នុងសៀវភៅបន្ទុក និងកិច្ចសន្យាលក់បានចប់សព្វគ្រប់ គណៈកម្មការត្រូវប្រគល់រូបទ្រព្យទាំងនោះ ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនដើម្បីទទួលបានការកាន់កាប់តាមច្បាប់កំណត់ ។

ចំពោះករណីលក់ដី និងអគារ បន្ទាប់ពីរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានទូទាត់ថ្លៃទិញផ្តាច់ បំពេញកាតព្វកិច្ចចែងក្នុងសៀវភៅបន្ទុក កិច្ចសន្យាលក់រួចរាល់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចផ្ទេរដី និងអគារដែលលក់ផ្តាច់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជន ដើម្បីបំពេញបែបបទស្នើសុំសិទ្ធិកាន់កាប់តាមច្បាប់កំណត់។

## ប្រការ១៦.-

ចំណូលទាំងអស់ដែលបានពីទ្រព្យសម្បត្តិដែលរឹបអូស និងក្រោយធ្វើការចាត់ចែងតាមសេចក្តីសម្រេចស្ថាពររបស់សាលាជម្រះក្តី ត្រូវកត់ត្រាជាចំណូលថវិការដ្ឋ និងត្រូវបែងចែកតាមប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

## ប្រការ១៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

## ប្រការ១៨.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក និង ប្រធានអង្គភាពនានា ដែលស្ថិតក្រោមឱវាទ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អគ្គលេខាធិការ និងប្រធានអង្គភាពនានា ដែលស្ថិតក្រោមឱវាទ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងប្រធានអង្គភាពនានា នៃក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៦

ឧបនាយករដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

នាយឧត្តមសេនីយ៍ កែ_គឹមយ៉ាន

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- ដូចប្រការ ១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៥-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០៤១ ស្ដីពីការតែងតាំងឯកឧត្ដម ០២ រូប ជាឧបការី សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភានីតិកាលទី ៣ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៩៤៤

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧០ ស្ដីពីការតែងតាំងឯកឧត្ដម ០៦ រូប ជាទីប្រឹក្សា សម្ដេច **ហេង សំរិន** អនុប្រធានទី ១ រដ្ឋសភានីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ៩៤៥

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧១ ស្ដីពីការតែងតាំង ឯកឧត្ដម **ខឹន សារិន** ជា ឧកញ៉ា ៩៤៦

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧២ ស្ដីពីការតែងតាំង លោក **វ័ន្ធ សុវណ្ណារ៉ា** និង លោកឧត្ដមសេនីយ៍ត្រី **ឡាច ទ័ាន់** ជា ឧកញ៉ា ៩៤៧

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧៤ ស្ដីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០៣ រូប ក្នុងរចនាសម្ព័ន្ធក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ ៩៤៨

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧៥ ស្ដីពីការតម្លើងឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ចំនួន ០២ រូប ៩៤៩

០៩-០២-២០០៦ -ព្រះរាជក្រឹត្យនស/រកត/០២០៦/០៧៦ស្ដីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្ដមសេនីយ៍ឯក ជូនឯកឧត្ដមឧត្ដមសេនីយ៍ទោ **ហាក់ សាទុច** ៩៥០

១១-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧៩ ស្ដីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្ដម ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ៩៥១

## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០៩-០២-២០០៦ -អនុក្រឹត្យលេខ ១១១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៩៥២

០៧-០២-២០០៦ -អនុក្រឹត្យលេខ ១១២ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៥៥៣
០៧-០២-២០០៦ -អនុក្រឹត្យលេខ ១១៣ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥៥៧
១០-០២-២០០៦ -អនុក្រឹត្យលេខ ១១៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៥៥៨
១០-០២-២០០៦ -អនុក្រឹត្យលេខ ១១៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៥៦០
១៤-០២-២០០៦ -អនុក្រឹត្យលេខ ១១៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៥៦១

## III~ការងារបណ្ដាក្រសួង

### ១~ទីស្ដីការរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

០៨-០២-២០០៦ -ប្រកាសលេខ ០៩ កយ.ប្រក/០៦ ស្ដីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និង ការព្យួរញ្ចង់ឱ្យលក់ដោយខុសច្បាប់ ៥៦២

### ២~ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៩-០២-២០០៦ -ប្រកាសលេខ ១៧១ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ភ្នំពេញ សាប់ផ្លាយ ខមផេនី លីមីធីត** បង្កើតរោងចក្រ " ប្លាស្ទិក " ដែលមានឈ្មោះថា " ភ្នំពេញ សាប់ផ្លាយ ខមផេនី លីមីធីត " ៥៦៧
០៩-០២-២០០៦ -ប្រកាសលេខ ១៧២ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ហ៊ុយចៀន (ខេមបូឌា) ខប** បង្កើតរោងចក្រ " ផលិតស្បែកជើង " ដែលមានឈ្មោះថា " ហ៊ុយចៀន (ខេមបូឌា) ខប " ៥៦៩
០៩-០២-២០០៦ -ប្រកាសលេខ ១៧៣ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **អេច ២ ហ្គាមេន** បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " អេច ២ ហ្គាមេន " ៥៧១
១០-០២-២០០៦ -ប្រកាសលេខ ១៨៣ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **តាលិន ហ្គាមេន អ៊ិនដាសស្រ្ទី (ខេមបូឌា)** បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " តាលិន ហ្គាមេន អ៊ិនដាសស្រ្ទី (ខេមបូឌា) " ៥៧៣

### ៣~ទីស្ដីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

០១-០២-២០០៦ -ប្រកាសលេខ១៥៩អយក.ប្រក ស្ដីពីការពង្រីកសាលារៀនចំណេះទូទៅឯកជន "ទូនហ្វា II" ស្ថិតនៅក្នុង សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ៥៧៥
០១-០២-២០០៦ -ប្រកាសលេខ ១៦០ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ "បុសលាវ" ស្ថិតនៅក្នុង ឃុំបុសលាវ ស្រុកក្រចេះ ខេត្ត ក្រចេះ ៥៧៧

០១-០២-២០០៦ -ប្រកាសលេខ ១៦១ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ "ហ៊ុនសែន ស្នួល" ទៅជាវិទ្យាល័យ "ហ៊ុនសែន ស្នួល" ស្ថិតនៅក្នុង ឃុំស្នួល ស្រុកស្នួល ខេត្ត ក្រចេះ ៥៧៨

០១-០២-២០០៦ -ប្រកាសលេខ ១៦២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ "ខ្សាច់អណ្តែត" ស្ថិតនៅក្នុង ឃុំខ្សាច់អណ្តែត ស្រុកឆ្លូង ខេត្តក្រចេះ ៥៧៩

០១-០២-២០០៦ -ប្រកាសលេខ ១៦៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ "គោលាប់" ស្ថិតនៅក្នុង ឃុំគោលាប់ ស្រុកក្រចេះ ខេត្តក្រចេះ ៥៨០

## ៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

១៨-០១-២០០៦ -លិខិតលេខ ២៣៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ី អិន អាយ ខូ អិលធីឌី** ៥៨១

១៨-០១-២០០៦ -លិខិតលេខ ២៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **គ្រីស្តាល់ អាគ្វា** ៥៨៣

១៨-០១-២០០៦ -លិខិតលេខ ២៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខាប៊ីណេត ខនស្ត្រាក់សិន** ៥៨៥

១៨-០១-២០០៦ -លិខិតលេខ ២៣៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ទៀល គ្រីន** ៥៨៧

១៨-០១-២០០៦ -លិខិតលេខ ២៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឡូជីស ខេមបូឌាន-អ៊ិនធើណេសិនណល** ៥៨៩

១៨-០១-២០០៦ -លិខិតលេខ ២៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **យូច រ៉ក់ (ខេមបូឌា) អិនធើប្រាយ** ៥៩១

១៨-០១-២០០៦ -លិខិតលេខ ២៤៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សុខ លីញ អ៊ីមផត អិចផត** ៥៩៣

១៨-០១-២០០៦ -លិខិតលេខ ២៤៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល ស៊ី ស៊ីខេ អ៊ិនធើណេសិនណល** ៥៩៥

១៨-០១-២០០៦ -លិខិតលេខ ២៤៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាយហ្គន ឌីវេឡុបមេន គ្រុប** ៥៩៧

## ឃ


១៨-០១-២០០៦ -លិខិតលេខ ២៤៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី ដាប់ប៊ែលយូ ធី ស៊ី ឌីវេឡុបមេន** ៩៩៩

១៩-០១-២០០៦ -លិខិតលេខ ២៥១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អឹមផ្លាយហ្វូន** ១០០១

១៩-០១-២០០៦ -លិខិតលេខ ២៥៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី.ឌី.ម៉ាយ (ឌី ឌី យូ) ត្រេឌីង** ១០០៣

នស/រកត/០២០៦/០៧៦

# ព្រះរាជក្រឹត្យ

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូន

- ឯកឧត្តមឧត្តមសេនីយ៍ទោ ចាវ អ៊ំ សារុន អត្តលេខ ០០០៥១១

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល-០៦៧៤-០៨១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០០៦

លេខ ៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០២០៦/០៧៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្សីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

H.E Fumiaki TAKAHASHI

ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា

នូវ

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរណ.០២០២.០៥៤

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៦*

លេខ: ៥៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១១១...អនក្រ...ឥឃ

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៥រូប ដែលបានឧបត្ថម្ភថវិកា ជួយកសាងមន្ទីរពិសោធន៍ នៅរាជធានីភ្នំពេញ និងអគារសិក្សា ០១ខ្នង បំពាក់ដោយសម្ភារៈគ្រប់គ្រាន់ នៅវិទ្យាល័យ សុខ អាន ១ ឧសភា ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានព្រះនាម និងនាមខាងក្រោម :-

**ក. មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-លោក **ខួន វ៉ាន់ចន្ធី** | នៅក្រុងភ្នំពេញ | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ២-ព្រះតេជគុណ **ខែម សុខ** | ព្រះអនុគណស្រុកត្រាំកក់ | បច្ច័យចំនួន ១០.៥០០ ដុល្លារ |
| ៣-លោក **សេង សារ៉ុន** | នៅក្រុងភ្នំពេញ | ថវិកាចំនួន ១១.២០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-លោក **ឈឹម ផេង** | នៅខេត្តតាកែវ | ថវិកាចំនួន ៥.៧០០ ដុល្លារ |
| ២-លោក **អ៊ឹម មឿន** | នៅខេត្តតាកែវ | ថវិកាចំនួន ៥.៥០០ ដុល្លារ |

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១២ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការជូនមេដាយការងារ

៚

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ៨៩រូប នៃក្រសួងកិច្ចការនារី ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោមនេះ :-

**ក-មេដាយមាសការងារ :**

| | | |
|---|---|---|
| ១-ឯកឧត្តម | សឿ ម៉ុនហ៊ីរ | អគ្គនាយករដ្ឋបាល និងកិច្ចការទូទៅ |
| ២-លោកជំទាវ | ជូ ម៉ុនអេង | អគ្គនាយកអភិវឌ្ឍសង្គម |
| ៣-លោកស្រី | ឱក គនធឿន | អគ្គនាយករងរដ្ឋបាល និងកិច្ចការទូទៅ |
| ៤-លោកស្រី | ឌីន ស៊ីវ៉េត | អគ្គនាយករងអភិវឌ្ឍសង្គម |
| ៥-លោក | ខឹម សោភ័ណ | ប្រធាននាយកដ្ឋានរដ្ឋបាល-បុគ្គលិក |
| ៦-លោកស្រី | ខី វ៉ានី | ប្រធាននាយកដ្ឋានព័ត៌មាន |
| ៧-លោកស្រី | ហ៊ុ និរមិត្តា | ប្រធាននាយកដ្ឋានស្ត្រី និងសុខភាព |
| ៨-លោកស្រី | ញាណ សុចិត្រា | ប្រធាននាយកដ្ឋានសមភាពយេនឌ័រ |
| ៩-លោកស្រី | ឡុង និមល | ប្រធាននាយកដ្ឋានស្ត្រី និងអប់រំ |
| ១០-លោក | យឹម សាមន | អនុប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១១-លោកស្រី | អ៊ុត សន | ប្រធានមន្ទីរកិច្ចការនារី ខេត្តមណ្ឌលគិរី |
| ១២-លោកស្រី | ញឹក សារ៉ា | ប្រធានមន្ទីរកិច្ចការនារី ខេត្តបន្ទាយមានជ័យ |
| ១៣-លោកស្រី | នូច សារ៉ុម | ប្រធានមន្ទីរកិច្ចការនារី រាជធានីភ្នំពេញ |
| ១៤-លោកស្រី | ឯម ម៉ុណ្ណា | ប្រធានមន្ទីរកិច្ចការនារី ខេត្តពោធិសាត់ |

១៥-លោកស្រី ស្នួស សារ៉ាម — ប្រធានមន្ទីរកិច្ចការនារី ខេត្តកណ្តាល

១៦-លោកស្រី ឯម ផល្លា — ប្រធានមន្ទីរកិច្ចការនារី ខេត្តព្រៃវែង

១៧-លោកស្រី ស៊ីម ម៉ារី — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តបាត់ដំបង

ខ-មេដាយប្រាក់ការងារ :

១-លោក គីម សុន — អគ្គនាយករងរដ្ឋបាល និងកិច្ចការទូទៅ

២-លោកស្រី ជុំគលាច ម៉ាន់នី — អគ្គនាយករងសមភាពយេនឌ័រ និងអភិវឌ្ឍសេដ្ឋកិច្ច

៣-លោកស្រី កេត ម៉ារឌី — ប្រធាននាយកដ្ឋានការពារផ្លូវច្បាប់

៤-លោកស្រី អ៊ុក ឈានី — អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ

៥-លោកស្រី ស៊ីន វណ្ណា — អនុប្រធាននាយកដ្ឋានការពារផ្លូវច្បាប់

៦-លោកស្រី ម៉ិនឈិត វាសនា — អនុប្រធាននាយកដ្ឋានអភិវឌ្ឍសេដ្ឋកិច្ច

៧-លោកស្រី នុំ បូផារី — អនុប្រធាននាយកដ្ឋានស្ត្រី និងការអប់រំ

៨-លោកស្រី តែ ទូចលីម — អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ

៩-លោកស្រី ឡេង មោនីភាព — អនុប្រធាននាយកដ្ឋានស្ត្រី និង សុខភាព

១០-លោកស្រី ឌុក ម៉ារឡានី — ប្រធានការិយាល័យថវិកា នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់

១១-លោកស្រី ពៅ សុភាព — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តស្វាយរៀង

១២-លោកស្រី ជ្រើយ ចាន់រី — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តមណ្ឌលគិរី

១៣-លោកស្រី ឯម ផល្លាមុន្នី — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តសៀមរាប

១៤-លោកស្រី សន សុខា — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តស្ទឹងត្រែង

១៥-លោកស្រី កាន់ ឈឿង — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តរតនគិរី

១៦-លោកស្រី សៅ កាន — អនុប្រធានមន្ទីរកិច្ចការនារី ក្រុងព្រះសីហនុ

១៧-លោកស្រី សោម សាគូ — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តក្រចេះ

១៨-លោកស្រី ឡុក សុម៉ារ៉ែត — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកោះកុង

១៩-លោកស្រី យឹម តារី — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តតាកែវ

២០-លោកស្រី ឡេង រីម — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកណ្តាល

២១-លោកស្រី នង អាល័យ — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ធំ

២២-លោកស្រី ឯក សុវណ្ណនារ: — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តឧត្តរមានជ័យ

២៣-លោកស្រី វស់ សុភ័ត្រា — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ចាម

២៤-លោកស្រី ម៉ែន អេន — ប្រធានមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ ម៉ារីរណប្ញទ្ធិ ខេត្តកំពង់ឆ្នាំង

២៥-លោកស្រី នួច សាគន្ធ — ប្រធានមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ សម្តេចម៉ែ ខេត្តកំពង់ស្ពឺ

២៦-លោកស្រី ពត សុផា — ប្រធានមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ ប៊ុនរ៉ានីហ៊ុនសែន ខេត្តពោធិសាត់

២៧-លោកស្រី អ៊ុំ រី — ប្រធានមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ ព្រះកុសមៈ ខេត្តកំពង់ចាម

ខ-មេដាយសំរឹទ្ធការងារ :

១-លោក តី សុគន្ធ — អនុប្រធាននាយកដ្ឋាន សមភាពយេនឌ័រ

២-លោកស្រី ជា ហ៊ីង — អនុប្រធាននាយកដ្ឋានសមភាពយេនឌ័រ

៣-លោកស្រី ឃ្លោក ម៉េងឡុល — អនុប្រធាននាយកដ្ឋានស្ត្រី និង សុខភាព

៤-លោកស្រី ទ៉ែត ថេន — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ឆ្នាំង

៥-លោកស្រី ឆាំល់ យឿន — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ឆ្នាំង

៦-លោកស្រី ឡុង សុឃាវី — អនុប្រធានមន្ទីរកិច្ចការនារី ក្រុងប៉ៃលិន

៧-លោក ឌិន សេដ្ឋា — អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពត

| | | | |
|---|---|---|---|
| ៨-លោកស្រី | ឈឹម | ស៊ុណា | អនុប្រធានមន្ទីរកិច្ចការនារី ខេត្តពោធិសាត់ |
| ៩-លោកស្រី | គង់ | សាឡួន | អនុប្រធានមន្ទីរកិច្ចការនារី ខេត្តព្រៃវែង |
| ១០-លោកស្រី | ម៉ុង | សំអុល | អនុប្រធានមន្ទីរកិច្ចការនារី ខេត្តព្រះវិហារ |
| ១១-លោកស្រី | តិន | ចន្ធូ | អនុប្រធានមន្ទីរកិច្ចការនារី ខេត្តបន្ទាយមានជ័យ |
| ១២-លោកស្រី | ជា | ស៊ុយើត | អនុប្រធានមន្ទីរកិច្ចការនារី ខេត្តមណ្ឌលគិរី |
| ១៣-លោកស្រី | ចន | យឿន | អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ស្ពឺ |
| ១៤-លោកស្រី | អ៊ុ | សុផល | អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ស្ពឺ |
| ១៥-លោក | អ៊ុត | ឆារិន | អនុប្រធានមន្ទីរកិច្ចការនារី រាជធានីភ្នំពេញ |
| ១៦-លោកស្រី | ឡេង | សុខា | អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ចាម |
| ១៧-លោកស្រី | អ៊ុំ | ស៊ីវមេង | ប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក មន្ទីរកិច្ចការនារីក្រុងកែប |
| ១៨-លោកស្រី | ហួង | សារឿន | ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន និងអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការនារីក្រុងកែប |
| ១៩-លោកស្រី | ស្រី | ធីនី | ប្រធានការិយាល័យផ្សព្វផ្សាយ មន្ទីរកិច្ចការនារីខេត្តកណ្តាល |
| ២០-លោកស្រី | លឹម | ប៊ុនលី | ប្រធានការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ មន្ទីរកិច្ចការនារីខេត្តតាកែវ |
| ២១-លោកស្រី | អ៊ុំ | សំអួន | ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន មន្ទីរកិច្ចការនារីខេត្តបាត់ដំបង |
| ២២-លោកស្រី | អោ | អៀង | ប្រធានការិយាល័យសុខភាព មន្ទីរកិច្ចការនារីខេត្តបាត់ដំបង |
| ២៣-លោកស្រី | ម៉ារី | ឆែម | ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន មន្ទីរកិច្ចការនារីខេត្តស្វាយរៀង |
| ២៤-លោកស្រី | ជិត | ស៊ុន្ធរៈនារី | ប្រធានការិយាល័យផ្សព្វផ្សាយនិងអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការនារីក្រុងព្រះសីហនុ |
| ២៥-លោកស្រី | អោម | អេម | ប្រធានការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ មន្ទីរកិច្ចការ-នារី ខេត្តកោះកុង |
| ២៦-លោកស្រី | តាន់ | គីមច័ន្ទ | ប្រធានការិយាល័យកិច្ចការនារីស្រុកសៀមរាប មន្ទីរកិច្ចនារី ខេត្តសៀមរាប |
| ២៧-លោក | នង | សែម | ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន មន្ទីរកិច្ចការនារីខេត្តកំពង់ស្ពឺ |
| ២៨-លោកស្រី | គី | អេងឡាយ | ប្រធានការិយាល័យសុខភាព មន្ទីរកិច្ចការនារីខេត្តពោធិសាត់ |
| ២៩-លោកស្រី | កែ | អេន | ប្រធានការិយាល័យផែនការ និងស្ថិតិ មន្ទីរកិច្ចការនារីខេត្តកំពង់ចាម |
| ៣០-លោកស្រី | កែវ | សំពៅ | ប្រធានការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច មន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ |
| ៣១-លោក | ជុំ | សុហ៊ាង | ប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការ-នារី ខេត្តឧត្តរមានជ័យ |
| ៣២-លោកស្រី | ពៅ | គន្ធី | ប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការ-នារី ខេត្តកំពត |
| ៣៣-លោកស្រី | ឈឹម | មុំ | ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន មន្ទីរកិច្ចការនារី ខេត្តស្ទឹងត្រែង |
| ៣៤-លោកស្រី | កង | ណា | ប្រធានការិយាល័យសុខភាព មន្ទីរកិច្ចការនារី ខេត្តរតនគិរី |
| ៣៥-លោកស្រី | សាម៉ី | ផាន់នី | ប្រធានមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ ខេត្តបន្ទាយមានជ័យ |
| ៣៦-លោកស្រី | ឆេព | សុខហ្វ៊ាន់ | អនុប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការនារី ខេត្តកំពង់ធំ |
| ៣៧-លោកស្រី | អ៊ុង | រស្មី | អនុប្រធានការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ មន្ទីរកិច្ច-ការនារី ខេត្តបន្ទាយមានជ័យ |
| ៣៨-លោកស្រី | ហេង | ឃឹម | អនុប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការនារីខេត្តសៀមរាប |

៣៩-លោកស្រី ងឹម ភសាង អនុប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការនារីខេត្តព្រៃវែង

៤០-លោកស្រី ហ៊ាត់ វរៀងហេង មន្ត្រីការិយាល័យហិរញ្ញវត្ថុ និងផ្គត់ផ្គង់ មន្ទីរកិច្ចការនារីខេត្តរតនគីរី

៤១-លោកស្រី យូ សុភា មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់

៤២-លោក លី ពិសិដ្ឋ មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច

៤៣-លោក ជិន ចន មន្ត្រីនាយកដ្ឋានការពារផ្លូវច្បាប់

៤៤-លោកស្រី គង់ ឫទ្ធី មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់

៤៥-លោក ឌួន ចាន់វឌ្ឍ មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១១៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
